# មាតិកា

## I~ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


១៧-៥-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៥០៥/២២៤ ស្តីពី ការតែងតាំងឯកឧត្តម **ជូន សុវណ្ណ** ជាទីប្រឹក្សារបស់សម្តេច **ជា ស៊ីម** ប្រធានព្រឹទ្ធសភា មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន ៣៣២១

១៧-៥-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៥០៥/២២៥ ស្តីពីការប្រោសព្រះរាជទាន
- -គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា** ចំពោះឯកឧត្តម **អ៊ុំ សារិទ្ធ**
- -គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **សេនា** ចំពោះឯកឧត្តម **ឡោក ហ៊ួរ** ៣៣២២

២៩-៥-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៥០៥/២៣២ ស្តីពី ការតម្លើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ត្រី** នាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទចំនួន ១២ រូប ៣៣២៣

២៩-៥-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៥០៥/២៣៤ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **លី ជូងស៊ុក** (LEE JOONG SUK) ជនជាតិកូរ៉េ សញ្ជាតិ កូរ៉េ កើតនៅសាធារណរដ្ឋកូរ៉េ ដោយប្តូរឈ្មោះជា **សុខ លី** (SOK LEE ) ៣៣២៥

២៩-៥-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៥០៥/២៣៥ ស្តីពីការតែងតាំងឯកឧត្តម **អៀវ ហ៊ុនលី** ជាទីប្រឹក្សាសហប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាមានឋានៈស្មើ **រដ្ឋលេខាធិការ** ៣៣២៦

២៩-៥-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៥០៥/២៣៩ ស្តីពីការប្រោសព្រះរាជទានចំពោះលោកជំទាវ **ហូ ឈួន** នូវគ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា** ៣៣២៧


## II~រាជរដ្ឋាភិបាល

### ១~អនុក្រឹត្យ


២៧-៥-២០០៥ -អនុក្រឹត្យលេខ ៧១ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ៣៣២៨

| | | |
|---|---|---|
| ២៧-៥-២០០៥ | -អនុក្រឹត្យលេខ ៧២ អនក្រ.បក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិប្រជាជន និងការអភិវឌ្ឍន៍ | ៣៣៣០ |
| ២៧-៥-២០០៥ | -អនុក្រឹត្យលេខ ៧៣ អនក្រ.បក ស្តីពីការបង្កើតសាកលវិទ្យាល័យស្វាយរៀង | ៣៣៣៦ |
| ២៤-៥-២០០៥ | -អនុក្រឹត្យលេខ ៤៥០ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ | ៣៣៣៩ |
| ២៤-៥-២០០៥ | -អនុក្រឹត្យលេខ ៤៥១ អនក្រ.តត ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ | ៣៣៤០ |
| ២៤-៥-២០០៥ | -អនុក្រឹត្យលេខ ៤៥២ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ | ៣៣៤២ |
| ២៤-៥-២០០៥ | -អនុក្រឹត្យលេខ ៤៥៣ អនក្រ.តត ស្តីពីការបញ្ចប់អាណត្តិបេសកកម្មរបស់មន្ត្រីការទូត | ៣៣៤៣ |
| ២៤-៥-២០០៥ | -អនុក្រឹត្យលេខ ៤៥៤ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីការទូតជាន់ខ្ពស់ | ៣៣៤៤ |
| ២៤-៥-២០០៥ | -អនុក្រឹត្យលេខ ៤៥៥ អនក្រ.តត ស្តីពីការកែសំរួលមាត្រា ១ នៃអនុក្រឹត្យលេខ ២៦៨ អនក្រ.តត ចុះថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០០០ ស្តីពីការតែងតាំង និងកែសំរួលសមាសភាពគណៈកម្មការ POW/MIA កម្ពុជា | ៣៣៤៥ |
| ២៥-៥-២០០៥ | -អនុក្រឹត្យលេខ ៤៥៦ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ | ៣៣៤៧ |
| ២៥-៥-២០០៥ | -អនុក្រឹត្យលេខ ៤៥៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ៣៣៤៨ |
| ២៥-៥-២០០៥ | -អនុក្រឹត្យលេខ ៤៥៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ៣៣៤៩ |
| ២៥-៥-២០០៥ | -អនុក្រឹត្យលេខ ៤៥៩ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ៣៣៥១ |
| ២៥-៥-២០០៥ | -អនុក្រឹត្យលេខ ៤៦០ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ៣៣៥៣ |
| ២៧-៥-២០០៥ | -អនុក្រឹត្យលេខ ៤៦១ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ | ៣៣៥៤ |
| ២៧-៥-២០០៥ | -អនុក្រឹត្យលេខ ៤៦២ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ | ៣៣៥៥ |
| ៣១-៥-២០០៥ | -អនុក្រឹត្យលេខ ៤៦៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ៣៣៥៦ |
| ៣១-៥-២០០៥ | -អនុក្រឹត្យលេខ ៤៦៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ៣៣៥៧ |
| ៣១-៥-២០០៥ | -អនុក្រឹត្យលេខ ៤៦៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ៣៣៥៩ |
| ៣១-៥-២០០៥ | -អនុក្រឹត្យលេខ ៤៦៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ៣៣៦១ |
| ៣១-៥-២០០៥ | -អនុក្រឹត្យលេខ ៤៦៧ អនក្រ.តត ស្តីពីការជូនមេដាយការងារ | ៣៣៦៣ |
| ៣១-៥-២០០៥ | -អនុក្រឹត្យលេខ ៤៦៨ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី | ៣៣៦៥ |
| ៣១-៥-២០០៥ | -អនុក្រឹត្យលេខ ៤៦៩ អនក្រ.តត ស្តីពីការតម្លើងឋានន្តរស័ក្តិនាយទាហានជាន់ខ្ពស់ | ៣៣៦៦ |

៣១-៥-២០០៥ -អនុក្រឹត្យលេខ ៤៧០ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣៣៦៨

៣១-៥-២០០៥ -អនុក្រឹត្យលេខ ៤៧១ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៣៣៦៩

## ២_សេចក្តីសំរេច

២៧-៥-២០០៥ -សេចក្តីសំរេចលេខ ១៣ សសរ ស្តីពីការបង្កើតគណៈកម្មាធិការសម្របសម្រួល កិច្ចការបញ្ជូនកងកម្លាំងចូលរួមបេសកកម្មរក្សាសន្តិភាព របស់អង្គការសហប្រជាជាតិ ៣៣៧០

## ៣_សារាចរណែនាំ

២៧-៥-២០០៥ -សារាចរណែនាំលេខ ០៣ សរណន ស្តីពីការរៀបចំខួបលើកទី ៥៦ " ទិវាកុមារអន្តរជាតិ ១ មិថុនា " និងខួបលើកទី ៤ "ទិវាពិភពលោកប្រឆាំងនឹងពលកម្មកុមារ ១២ មិថុនា" ឆ្នាំ ២០០៥ ៣៣៧១ក

## III_ការងារបណ្តាក្រសួង

### ១_ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

២៤-៥-២០០៥ -ប្រកាសលេខ ២៤២សហវ.ប្រក ស្តីពីការកែសំរួលខ្លឹមសារប្រកាសលេខ ៤៦៨ សហវ.ប្រក ៣៣៧២

២៥-៥-២០០៥ -ប្រកាសលេខ ២៤៧ សហវ.ប្រក ស្តីពីការគ្រប់គ្រងអាជីវកម្មល្បែងកំសាន្តស្លុតម៉ាស៊ីនល្បែងអេឡិចត្រូនិច និងមេកានិចគ្រប់ប្រភេទ ៣៣៧៤

២៧-៥-២០០៥ -ប្រកាសលេខ ២៤៨ សហវ.ប្រក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋានពន្ធដារ ៣៣៨២

### ២_ទីស្តីការរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

២៥-៥-២០០៥ -ប្រកាសលេខ ២៤ កយ.ប្រក/០៥ ស្តីពីតួនាទី និងភារកិច្ចរបស់ខុទ្ទកាល័យ ៣៣៩៧

### ៣_ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

១១-៥-២០០៥ -លិខិតលេខ ១០៧១ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **និកថ៉រ** ៣៣៩៩

១២-៥-២០០៥ -លិខិតលេខ ១០៨៦ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **ខេមបូឌាន ហ្គែលេកស៊ី រីខ្លេម រីសេសស៍** ៣៤០១

១២-៥-២០០៥ -លិខិតលេខ ១០៨៨ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **ហេង គាង អ៊ីមផត អិចផត** ៣៤០៣

១២-៥-២០០៥ -លិខិតលេខ ១០៨៩ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **ហេង គីមសាន គ្រុប** ៣៤០៥

១២-៥-២០០៥ -លិខិតលេខ ១០៩០ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**គូលំរ ( កាំបូដហ្ស៊ )** ៣៤០៧

១២-៥-២០០៥ -លិខិតលេខ ១០៩១ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**អង្គរ ទ្រីមីច** ៣៤០៩

១២-៥-២០០៥ -លិខិតលេខ ១០៩៨ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**អែសូមិ អ៊ិនធើប្រាយ & ឌីវេឡុបមេន** ៣៤១១

១២-៥-២០០៥ -លិខិតលេខ ១០៩៩ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ស៊ី អ៊ី យូ អ៊ិនធើណេសិនណាល** ៣៤១៣

១២-៥-២០០៥ -លិខិតលេខ ១១០០ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ញូ វើលដ៍ អ៊ិនស្ទីធ្យូត** ៣៤១៥

១២-៥-២០០៥ -លិខិតលេខ ១១០៤ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ហ្គោលដេន ខញូ អ៊ិនធើណេសិនណាល** ៣៤១៧

១៧-៥-២០០៥ -លិខិតលេខ ១១០៦ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ជា ស៊ីន ខូ អិលធីឌី** ៣៤១៩

១៧-៥-២០០៥ -លិខិតលេខ ១១០៧ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ស៊ូភារាន** ៣៤២១

១៧-៥-២០០៥ -លិខិតលេខ ១១១០ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ណាម យ៉ាង (ខេមបូឌា)** ៣៤២៣

១៧-៥-២០០៥ -លិខិតលេខ ១១១១ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**អាយ.ស៊ី.ជី.ស៊ី** ៣៤២៥

១៧-៥-២០០៥ -លិខិតលេខ ១១១២ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**តេឡាហ្សូ ហ្គោមីច (ខេមបូឌា) អិលធីឌី** ៣៤២៧

១៧-៥-២០០៥ -លិខិតលេខ ១១១៤ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**មីណា ខសមេធីក ខមភេនី** ៣៤២៩

១៧-៥-២០០៥ -លិខិតលេខ ១១១៥ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ហ្គោល ឃី** ៣៤៣១

១៨-៥-២០០៥ -លិខិតលេខ ១១១៦ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ខេ ដាប់បែលយូ អ៊ី អេស អេស** ៣៤៣៣

១៨-៥-២០០៥ -លិខិតលេខ ១១២២ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ផេនថេច ខូ អិលធីឌី** ៣៤៣៥

១៨-៥-២០០៥ -លិខិតលេខ ១១២៣ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**បន្ទាយស្រី រុងរឿង** ៣៤៣៧

១៨-៥-២០០៥ -លិខិតលេខ ១១២៧ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ស៊ែល_ណេត អ៊ិនជីនារីង អ៊ិន** ៣៤៣៩

១៨-៥-២០០៥ -លិខិតលេខ ១១២៩ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ផេកស្រីរុង** ៣៤៤១

១៨-៥-២០០៥ -លិខិតលេខ ១១៣០ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**តឹង ឌីក ម៉ាញ់ & យូសុគំណ្ណ** ៣៤៤៣

១៩-៥-២០០៥ -លិខិតលេខ ១១៣២ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**សៅ អេស៊ា អ៊ិនដាស្ទ្រី** ៣៤៤៥

១៩-៥-២០០៥ -លិខិតលេខ ១១៣៣ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ញូ យ៉ក អ៊ិនធើធេនមេន គ្លឹប & ខហ្វេ** ៣៤៤៧

១៩-៥-២០០៥ -លិខិតលេខ ១១៣៥ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**គ្លូបិល ថេក ណេតវើក ស៊ីរីស** ៣៤៤៩

១៩-៥-២០០៥ -លិខិតលេខ ១១៣៦ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ទី.ធី.អិម អ៊ីមផត អិចផត & ខនស្ត្រាក់សិន** ៣៤៥១

២០-៥-២០០៥ -លិខិតលេខ ១១៤៩ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ហាវ ស៊ាន គ្រុប លីមីធីត** ៣៤៥៣

២០-៥-២០០៥ -លិខិតលេខ ១១៥០ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**(ខេមបូឌា)_ម៉ាលខម** ៣៤៥៥

២០-៥-២០០៥ -លិខិតលេខ ១១៥១ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**អល ណេសិន (ខេមបូឌា)** ៣៤៥៧

២០-៥-២០០៥ -លិខិតលេខ ១១៥២ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**យូ.ស៊ី.អ៊ិនវេសមេន គ្រុប** ៣៤៥៩

២០-៥-២០០៥ -លិខិតលេខ ១១៥៣ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ម៉ាក់_នែល (ខេមបូឌា)** ៣៤៦១

២០-៥-២០០៥ -លិខិតលេខ ១១៥៦ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ខេ អ៊ី ស៊ី គ្រុប** ៣៤៦៣

២០-៥-២០០៥ -លិខិតលេខ ១១៦០ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ឌី មីលីនែរស៍ ក្លឹប** ៣៤៦៥

២០-៥-២០០៥ -លិខិតលេខ ១១៦១ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ហ្វេនទិច អ៊ិនធើណេសិនណល (ខេមបូឌា) ខូអបភើរេសិន អិលធីឌី** ៣៤៦៧

២០-៥-២០០៥ -លិខិតលេខ ១១៦៤ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ក្សីរណា ស្តូន អង្គរ** ៣៤៦៩

២៤-៥-២០០៥ -លិខិតលេខ ១១៦៩ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ច័ន្ទ គ្រឹះស្ថា អាហ៉ារណា នីហ៉ារណា** ៣៤៧១

២៤-៥-២០០៥ -លិខិតលេខ ១១៧១ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**គីរេ ហ៊្វូដ ស៊ីបផ្លាយ ខមភេនី** ៣៤៧៣

២៤-៥-២០០៥ -លិខិតលេខ ១១៧៣ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**អេស ប៊ី អិម_ស៊ីឌី** ៣៤៧៥

២៤-៥-២០០៥ -លិខិតលេខ ១១៧៥ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**យ៉ាង ហ្វូដ អ៊ិនគ្រីឌាន អ៊ុម & អិច** ៣៤៧៧

២៤-៥-២០០៥ -លិខិតលេខ ១១៧៦ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**លីហ្ស៊ីមីនី** ៣៤៧៩

២៤-៥-២០០៥ -លិខិតលេខ ១១៧៩ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន ៣៤៨១
**យុនអ៊ីង អ៊ិនធើណេសិនណល ត្រេឌីង ស៊ែរហ្វូលឌីង**

២៧-៥-២០០៥ -ប្រកាសលេខ ១៥៥ MOC/M 2005 ស្តីពី ស្ថានភាពរោងចក្រកាត់ដេរ SUNSHINY (CAMBODIA) GARMENT MANUFACTURING CO.,LTD. ៣៤៨៣

# ព្រះរាជក្រឹត្យ

នស/រកត/០៥០៥/២២៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៩៩ ដែលប្រកាសបង្គាប់ឱ្យប្រើជាផ្លូវការ នូវច្បាប់រដ្ឋធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទិ ៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័ត នៅថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ១៩៩៩
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៤៣ ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់តែងតាំង ប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចប្រធានព្រឹទ្ធសភា

## ត្រាស់បង្គាប់

**មាត្រា ១** : តែងតាំងឯកឧត្តម ជួន សុវណ្ណ ជាទីប្រឹក្សារបស់សម្តេច ជា ស៊ីម ប្រធានព្រឹទ្ធសភា មានឋានៈស្មើរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា ២** : ប្រធានព្រឹទ្ធសភា និងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣.ស.០៥០៥.២៣៩

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០០៥*

លេខ ៖ ៣២០៤ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល
[illegible] តាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៥០៥/២៧៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា
សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា )

ប្រោសព្រះរាជទាន

- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា ចំពោះ :
  - ឯកឧត្តម អ៊ុំ សារិទ្ធ
- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា ចំពោះ :
  - ឯកឧត្តម ឡោក ហ៊ួរ

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រស.០៥១៥.២៤០

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០០៥

លេខ: ២១៣ ច.ល
ដើម្បីចម្លងចែកជូន
រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាង ឡាន់

នស/រកត/០៥០៥/២៣២

# ព្រះរាជក្រឹត្យ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែ កក្កដា ឆ្នាំ២០០១ ស្តីពីការកែសំរួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១** : តម្លើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ត្រី** នាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ដែលមានរាយនាមដូចខាងក្រោម ÷

១-វរសេនីយ៍ឯក អ៊ុន ស៊ូយ៉េត អត្តលេខ ០០២០២៥

២-វរសេនីយ៍ឯក អ៊ូ ផាន់ឌី អត្តលេខ ០០០៦១២

៣-វរសេនីយ៍ឯក អ៊ុត ហ្វូច អត្តលេខ ០០១៦៦៣

៤-វរសេនីយ៍ឯក ឡាញ់ នី អត្តលេខ ០០១៦៧៧

៥-វរសេនីយ៍ឯក និត្យ ម៉េងឡុង អត្តលេខ ០០១៤៧២

៦-វរសេនីយ៍ឯក ហាន់ សុផណ្ណ អត្តលេខ ០០១៨៧៨

៧-វរសេនីយ៍ឯក ចាន់ នន់ថិឡា អត្តលេខ ០០៣៤៥៩

៨-វរសេនីយ៍ឯក ម៉ា ចន្ថា អត្តលេខ ០០១២០៤

៩-វរសេនីយ៍ឯក ឈោម សន អត្តលេខ ០០០៨១៧

១០-វរសេនីយ៍ឯក ឈាន ឆន អត្តលេខ ០០១០០៤

១១-វរសេនីយ៍ឯក អ៊ិល សំផន អត្តលេខ ០០២៤១៧

១២-វរសេនីយ៍ឯក អ៊ុំ រតនៈ អត្តលេខ ០០៥១៤៦

មាត្រា២ ៖ សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣ ៖ ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

នស.០៥០៥.២៤៧

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០០៥*

លេខៈ ៣០៥ ច.ល
ដើម្បីចម្លងចេញ
រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល

ណាឌី តាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៥០៥/២៣៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានត្ថមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ ៖ ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **លី ជូងស៊ុក** (LEE JOONG SUK) ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ កើតថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ១៩៣៦ នៅសាធារណរដ្ឋកូរ៉េ ដោយប្តូរឈ្មោះជា **សុខ លី** (SOK LEE) ។

មាត្រា ២ ៖ សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ ៖ ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០៥

៣៤៧.០៥០៥.២៤៩

លេខ ២០៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ាវ ចាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៥០៥/២៣៥

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១:** ត្រូវបានតែងតាំងឯកឧត្តម អ៊ើរ ហ៊ុនលី ជាទីប្រឹក្សាសហប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានឋានៈស្មើ រដ្ឋលេខាធិការ ។

**មាត្រា ២:** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣:** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រស.០៥០៥.២៥០

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០០៥

លេខ: [illegible] ច.ល
ដើម្បីចម្លងចែកជូន
រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល

ណាង តាន់

2/2

# ព្រះរាជក្រឹត្យ

នស/រកត/០៥០៥/២៣៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃ រាជរដ្ឋាភិបាលកម្ពុជា )

## ប្រោសព្រះរាជទាន

ចំពោះ

លោកជំទាវ **ហូ ណួន**

នូវ

**គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា**

ព្រះហស្តលេខា និងព្រះរាជលញ្ចករ
នរោត្តម សីហមុនី

៣៦ល.០៥០៥.២៥៤

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៥

លេខ: ២០២ ចល
ដើម្បីចម្លងចែកចាយ
រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល,

ណាឌី តាន់

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ :..៧៥១...អនក្រ. បក

## អនុក្រឹត្យ

## ស្ដីពីការផ្ទេរឥណទានថវិកា

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ . ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១១៧ . ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ . ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ . ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ . ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ . ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្ដីអំពីប្រព័ន្ធ ហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្ដីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១ ន.ស ៩៤ . ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្ដីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ . ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និង ត្រូវបានកែប្រែដោយច្បាប់ស្ដីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្ដីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ . ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៤/០០២ . ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៥
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក . ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៩២ អនក្រ.បក . ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៤ ស្ដីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋ តាមជំពូកនៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៥
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

**មាត្រា១:** ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកាចំនួន ១០.០០០ លានរៀល ( ដប់ពាន់លានរៀលគត់ ) ពីជំពូក ៤០ (ចំណាយផ្សេងៗ ) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ១១ (ចំណាយដំណើរការរដ្ឋបាលសំភារៈ និង ការជួសជុលតូច )ជូនទីស្តីការគណៈរដ្ឋមន្ត្រី សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៥. ។

**មាត្រា២:** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ទូទាត់ថវិកាបុរេប្រទានការងារពិសេសរបស់រាជរដ្ឋាភិបាល ឆ្នាំ ២០០៤ និង ឆ្នាំ ២០០៥ ។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ . ថ្ងៃទី២៧ខែឧសភាឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៧២ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំ និងការប្រព្រឹត្តិទៅរបស់ អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិប្រជាជន និងការអភិវឌ្ឍ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៤/២៣៧ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៤ ស្តីពីការបង្កើតគណៈកម្មាធិការជាតិប្រជាជន និងការអភិវឌ្ឍ
- តាមសំណើរបស់ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ មានគោលដៅកំណត់បេសកកម្ម មុខងារ ភារកិច្ច និងរចនាសម្ព័ន្ធ របស់អគ្គលេខាធិការដ្ឋាន **គ.ជ.ប.អ**។

## ជំពូកទី២

## បេសកកម្ម និងភារកិច្ច

**មាត្រា ២.-**

គណៈកម្មាធិការជាតិប្រជាជន និងការអភិវឌ្ឍ សរសេរកាត់អក្សរខ្មែរ **គ.ជ.ប.អ** មានអគ្គលេខាធិការដ្ឋានមួយជាជំនួយការ។ អគ្គលេខាធិការដ្ឋាននេះដឹកនាំ និងគ្រប់គ្រងដោយអគ្គលេខាធិការមួយរូប និងអមដោយអគ្គលេខាធិការរង មួយចំនួនជាជំនួយការ ព្រមទាំងមានផ្នែកជំនាញផ្សេងៗទៀតតាមតំរូវការចាំបាច់។

**មាត្រា ៣.-**

អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិប្រជាជន និងការអភិវឌ្ឍ សរសេរកាត់អក្សរខ្មែរ **អ.គ.ជ.ប.អ** មានបេសកកម្ម និងភារកិច្ចជាជំនួយការរបស់ **គ.ជ.ប.អ** លើការងារមួយចំនួនដូចតទៅ÷

- ស្រាវជ្រាវ និងផ្សព្វផ្សាយពត៌មានស្តីពីសេចក្តីត្រូវការ និងបញ្ហាទាំងឡាយដែលពាក់ព័ន្ធនឹងប្រជាជនជូនរាជរដ្ឋាភិបាល ស្ថាប័ន និងអង្គភាពពាក់ព័ន្ធនានា
- សម្របសម្រួល និងធ្វើសហប្រតិបត្តិការជាមួយនឹងក្រសួង និងស្ថាប័នពាក់ព័ន្ធ តំណាងភ្នាក់ងារ អង្គការសហប្រជាជាតិ ជាពិសេសមូលនិធិសហប្រជាជាតិសំរាប់ប្រជាជន (UNFPA) អង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ និងសង្គមស៊ីវិល ផ្នែកឯកជន និងតំណាងវិទ្យាស្ថានស្រាវជ្រាវដែលពាក់ព័ន្ធនឹងបញ្ហាប្រជាជន និងការអភិវឌ្ឍ ដើម្បីធានានូវភាពរលូន និងភាពជាដៃគូក្នុងការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល
- សម្របសម្រួលជាមួយគណៈកម្មការនៃរដ្ឋសភា និងព្រឹទ្ធសភាក្នុងក្របខ័ណ្ឌជាតិ ដែលពាក់ព័ន្ធនឹងបញ្ហាប្រជាជន និងចូលរួមដឹកនាំសិក្ខាសាលា វគ្គបណ្តុះបណ្តាល សន្និសីទជាតិ និងអន្តរជាតិ ដើម្បីជាជំនួយក្នុងការសំរេចគោលដៅ កម្មវិធីគោលនយោបាយ និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល
- ចងក្រង និងផ្សព្វផ្សាយឯកសារគោលនយោបាយ ផែនការ កម្មវិធី និងសេចក្តីប្រកាសដែលពាក់ព័ន្ធនឹងបញ្ហាប្រជាជន និងការអភិវឌ្ឍ

- ត្រួតពិនិត្យ និងកែសម្រួលគោលនយោបាយប្រជាជន និងយុទ្ធសាស្ត្រជាតិប្រជាជនអោយកាន់តែល្អប្រសើរ តាមការវិវត្តន៍ នៃសភាពការណ៍ក្នុងតំបន់ និងពិភពលោក
- សហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសុខាភិបាល និងក្រសួងពត៌មាន ក្នុងការផ្សព្វផ្សាយ និងបញ្ចូលបញ្ហាប្រជាជនទៅក្នុងកម្មវិធីសិក្សានៅតាមគ្រឹះស្ថាននានា
- ធ្វើរបាយការណ៍ ប្រចាំត្រីមាស ឆមាស ប្រាំបួនខែ និងប្រចាំឆ្នាំ អំពីសកម្មភាពការងារតាមកាលកំណត់អោយបានទៀងទាត់ជូនប្រមុខរាជរដ្ឋាភិបាល។

មាត្រា ៤.-

**អ.គ.ជ.ប.អ.** ត្រូវធ្វើការប្រជុំការងារយ៉ាងតិចមួយដងក្នុងមួយខែ តាមការអញ្ជើញ និងការណែនាំរបស់អគ្គលេខាធិការ ។

មាត្រា ៥.-

**អ.គ.ជ.ប.អ** មានសិទ្ធិប្រើត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីបំពេញការងាររបស់ខ្លួន។

មាត្រា ៦.-

- **អ.គ.ជ.ប.អ** មានសិទ្ធិប្រើប្រាស់មន្ត្រីមុខងារសាធារណៈ និងលើកសំណើជូនប្រធាន **គ.ជ.ប.អ** ដើម្បីជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យាតាមការចាំបាច់។
- មន្ត្រីរបស់ **អ.គ.ជ.ប.អ** អាចទទួលនូវប្រាក់ឧបត្ថម្ភផ្សេងៗ ដែលបានផ្តល់មកពីក្នុង និងក្រៅប្រទេស ឬ អង្គការអន្តរជាតិនានាដែលផ្តល់ជំនួយ។

មាត្រា ៧.-

**អ.គ.ជ.ប.អ** លើកសំណើជូនប្រធាន **គ.ជ.ប.អ** លើការតែងតាំង តម្លើងឋានៈ ផ្ទេរភារកិច្ច ឬ ដកចេញពីតំណែងនូវមន្ត្រីបុគ្គលិករបស់ **អ.គ.ជ.ប.អ** ។

## ជំពូកទី៣

## រចនាសម្ព័ន្ធ

មាត្រា ៨.-

**អ.គ.ជ.ប.អ** មានរចនាសម្ព័ន្ធដូចខាងក្រោមៈ

ក. ផ្នែករដ្ឋបាលទូទៅ និងគណនេយ្យ

ខ. ផ្នែកទំនាក់ទំនង និងផ្សព្វផ្សាយ

គ. ផ្នែកវិភាគគោលនយោបាយប្រជាជន

ឃ. ផ្នែកបណ្តុះបណ្តាល និងការអភិវឌ្ឍ

អង្គការលេខរបស់ អ.គ.ជ.ប.អ ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា ៩.-**

-ផ្នែកជំនាញនីមួយៗ ត្រូវបែងចែកជាក្រុមជំនាញ។ ការបែងចែកភារកិច្ចទទួលខុសត្រូវរបស់ក្រុមជំនាញនីមួយៗ ត្រូវកំណត់ដោយប្រកាស តាមសំណើរបស់អគ្គលេខាធិការ។

**មាត្រា ១០.-**

ផ្នែកជំនាញដែលចំណុះ **អ.គ.ជ.ប.អ** ស្ថិតនៅក្រោមការដឹកនាំ និងការទទួលខុសត្រូវរបស់ប្រធានមួយរូប និងមានអនុប្រធានមួយចំនួន ជាជំនួយការតាមតម្រូវការចាំបាច់។

- ប្រធានផ្នែកជំនាញមានឋានៈស្មើប្រធាននាយកដ្ឋាន។
- អនុប្រធានផ្នែកជំនាញមានឋានៈស្មើអនុប្រធាននាយកដ្ឋាន។
- ប្រធានក្រុមជំនាញមានឋានៈស្មើប្រធានការិយាល័យ។

**មាត្រា ១១.-**

អគ្គលេខាធិការមានភារកិច្ចលើកសំណើជូនប្រធាន **គ.ជ.ប.អ** ដើម្បីពិនិត្យ និងសម្រេចលើការផ្លាស់ប្តូរ ឬ បង្កើតផ្នែកជំនាញ ក្រុមជំនាញ ផ្សេងៗទៀតតាមតម្រូវការចាំបាច់ ។

## ជំពូកទី៤
## តួនាទី និងភារកិច្ចរបស់ផ្នែក

**មាត្រា ១២.-**

**ផ្នែករដ្ឋបាលទូទៅ និងគណនេយ្យ មានតួនាទី និងភារកិច្ចៈ**

- ជាលេខាធិការដ្ឋានរបស់អគ្គលេខាធិការដ្ឋាន និងជាសេនាធិការផ្ទាល់ឱ្យអគ្គលេខាធិការ ដើម្បីសម្របសម្រួលផ្នែករដ្ឋបាល លើរាល់សកម្មភាពរបស់ផ្នែក និងក្រុមកិច្ចការទាំងអស់ក្រោមឱវាទរបស់អគ្គលេខាធិការដ្ឋាន
- គ្រប់គ្រងកិច្ចការរដ្ឋបាល និងគ្រប់គ្រងមន្ត្រី បុគ្គលិករបស់អគ្គលេខាធិការដ្ឋាន
- ប្រមូល ចងក្រងពត៌មាន និងឯកសារនានាពាក់ព័ន្ធដល់គោលនយោបាយជាតិប្រជាជន និងការអភិវឌ្ឍ
- រៀបចំតារាងថវិកា សំភារៈបរិក្ខា និងមធ្យោបាយការងារផ្សេងៗ
- រៀបចំប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យា និងបង្កើតកម្មវិធីនានា
- គ្រប់គ្រងអចលនវត្ថុ ចលនវត្ថុ និងរាល់ការចំណាយផ្សេងៗ
- ប្មូកសរុប និងធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារប្រចាំខែ ត្រីមាស ឆមាស ប្រាំបួនខែ និងប្រចាំឆ្នាំ របស់ **គ.ជ.ប.អ**
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់អគ្គលេខាធិការនៃ **គ.ជ.ប.អ**។

មាត្រា ១៣.-

**ផ្នែកទំនាក់ទំនង និងផ្សព្វផ្សាយមានតួនាទី និងភារកិច្ច :**

- ស្រាវជ្រាវ ផ្សព្វផ្សាយ និងជូនពត៌មាន ស្តីពីសេចក្តីត្រូវការ និងបញ្ហាទាំងឡាយ ដែលពាក់ព័ន្ធនឹងប្រជាជន ជូនរាជរដ្ឋាភិបាល ស្ថាប័ន និងអង្គភាពពាក់ព័ន្ធនានា
- សិក្សាស្រាវជ្រាវ និងផ្តួចផ្តើមគំនិតថ្មីៗ ដែលទាក់ទងនឹងបញ្ហាប្រជាជន ដើម្បីធ្វើការតស៊ូមតិ
- ចូលរួមរៀបចំ និងដឹកនាំសិក្ខាសាលា សន្និសីទជាតិ និងអន្តរជាតិ ដើម្បីពន្យល់ និងផ្តល់ពត៌មានអំពីគំនិត នៃ គោលនយោបាយជាតិប្រជាជន ដល់អ្នកធ្វើគោលនយោបាយ និង អ្នកធ្វើផែនការ អ្នកធ្វើការសម្រេចចិត្ត សភា និងព្រឹទ្ធសភា ដើម្បីអោយគាំទ្រ និងអនុវត្តគោលនយោបាយឱ្យមានប្រសិទ្ធភាព
- រៀបចំអត្ថបទ និងបោះពុម្ពព្រឹត្តិប័ត្រ សម្រាប់ផ្សព្វផ្សាយដល់ស្ថាប័នពាក់ព័ន្ធនានា
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់អគ្គលេខាធិការនៃ **គ.ជ.ប.អ**។

មាត្រា ១៤.-

**ផ្នែកវិភាគគោលនយោបាយប្រជាជន និងមានតួនាទី និងភារកិច្ច :**

- សិក្សាស្រាវជ្រាវ វិភាគ និងកែលំអគោលនយោបាយជាតិប្រជាជន
- សហការជាមួយគណៈកម្មការនៃសភា និងព្រឹទ្ធសភា ក្នុងក្របខ័ណ្ឌជាតិ ដែលពាក់ព័ន្ធនឹងបញ្ហាប្រជាជន និង ការអភិវឌ្ឍ ដើម្បីជាជំនួយក្នុងការអនុវត្តអោយសំរេចនូវកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល
- សហប្រតិបត្តិការជាមួយក្រសួងពាក់ព័ន្ធ អង្គការជាតិ និងអន្តរជាតិ ប្រទេសផ្តល់ជំនួយ សង្គមស៊ីវិល ផ្នែក ឯកជនដែលពាក់ព័ន្ធនឹងបញ្ហាប្រជាជន និងការអភិវឌ្ឍ ដើម្បីធានានូវភាពរលូន និងភាពជាដៃគូក្នុងការ អនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់អគ្គលេខាធិការនៃ **គ.ជ.ប.អ**។

មាត្រា ១៥.-

**ផ្នែកបណ្តុះបណ្តាល និងការអភិវឌ្ឍមានភារកិច្ច :**

- រៀបចំ និងអភិវឌ្ឍកម្មវិធីបណ្តុះបណ្តាលផ្សេងៗ
- ចូលរួមរៀបចំ និងអភិវឌ្ឍកម្មវិធីបណ្តុះបណ្តាលដល់មន្ត្រីរាជការតាមក្រសួង មន្ទីរ តាមតំបន់ និងខេត្ត ក្រុង ដើម្បីបង្កើនចំណេះដឹង និងស្វែងយល់អំពីទំនាក់ទំនងរវាងបញ្ហាប្រជាជន និងការអភិវឌ្ឍ
- សិក្សាស្រាវជ្រាវ និងរៀបចំកម្មវិធីដើម្បីបង្កើតយន្តការផ្លាស់ប្តូរបទពិសោធន៍ និងទស្សនៈជាវិជ្ជមាន និង កម្មវិធីថ្មីៗក្នុងតំបន់ ក៏ដូចជាក្រៅតំបន់ ដែលពាក់ព័ន្ធនិងបញ្ហាប្រជាជន និងការអភិវឌ្ឍ
- បំពេញភារកិច្ចផ្សេងៗ ទៀតតាមការប្រគល់ជូនរបស់អគ្គលេខាធិការនៃ **គ.ជ.ប.អ**។

## ជំពូកទី៥

## អវសានប្បញ្ញត្តិ

**មាត្រា ១៦.-**

រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ១៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ **គ.ជ.ប.អ** និងអគ្គលេខាធិការដ្ឋានរបស់ **គ.ជ.ប.អ** មានភារកិច្ចអនុវត្តអនុក្រឹត្យនេះទៅតាមភារកិច្ចរៀងៗ ខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០០៥

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

ចម្លងជូនៈ

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច និងឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១៧
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ....៧៣....អនក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# ការបង្កើតសាកលវិទ្យាល័យស្វាយរៀង

* * * * *

# រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពីការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខណវិនិច្ឆ័យ នៃការបង្កើតសាកលវិទ្យាល័យ

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាលខេត្តស្វាយរៀង

# ស ម្រេ ច

មាត្រា ១..

បង្កើតសាកលវិទ្យាល័យមួយ ស្ថិតនៅផ្លូវជាតិលេខ ១ ភូមិចំបក់ ឃុំចេក ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង ដែលមានឈ្មោះថា សាកលវិទ្យាល័យស្វាយរៀង " Svay Rieng University " ហៅកាត់ជាភាសាខ្មែរ "ស.ស.រ" និងហៅកាត់ជាភាសាអង់គ្លេស "S.R.U" ។ សាកលវិទ្យាល័យនេះ ស្ថិតនៅក្រោមឱវាទរបស់ក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា ២..

សាកលវិទ្យាល័យស្វាយរៀង មានតួនាទី ជាមជ្ឈមណ្ឌលបណ្តុះបណ្តាលធនធានមនុស្ស ស្រាវជ្រាវ វប្បធម៌ វិទ្យាសាស្ត្រ និងបច្ចេកទេស និង លើកស្ទួយអត្តសញ្ញាណជាតិ ។

មាត្រា ៣..

ចំពោះមុខសាកលវិទ្យាល័យស្វាយរៀង ធ្វើការបណ្តុះបណ្តាលកំរិតបរិញ្ញាបត្ររង និងបរិញ្ញាបត្រ។ កម្មវិធីសិក្សា ត្រូវមានការឯកភាព ពីក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា ៤..

សាកលវិទ្យាល័យស្វាយរៀងមាន ៥ មហាវិទ្យាល័យ :

១- មហាវិទ្យាល័យសិល្បៈ មនុស្សសាស្ត្រ និងភាសាបរទេស

២- មហាវិទ្យាល័យវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា

៣- មហាវិទ្យាល័យសង្គមសាស្ត្រ

៤- មហាវិទ្យាល័យគ្រប់គ្រងពាណិជ្ជកម្ម

៥- មហាវិទ្យាល័យកសិកម្ម

ទៅអនាគត សាកលវិទ្យាល័យស្វាយរៀង នឹងអាចបើកមហាវិទ្យាល័យ សាខា ឯកទេស កំរិត ឬប្រភេទបណ្តុះបណ្តាលផ្សេងទៀត ដោយរៀបចំសំណុំបែបបទ សុំការអនុញ្ញាតពីក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា ៥..

សាកលវិទ្យាល័យស្វាយរៀង មានក្រុមប្រឹក្សាភិបាលមួយ ដើម្បីពិនិត្យ និង សម្រេចលើគោលនយោបាយ ផែនការអភិវឌ្ឍន៍ និងការងារពាក់ព័ន្ធផ្សេងៗទៀត របស់សាកលវិទ្យាល័យ ។

មាត្រា ៦..

សាកលវិទ្យាល័យស្វាយរៀង ដឹកនាំដោយសាកលវិទ្យាធិការមួយរូប និង សាកលវិទ្យាធិការរង មួយរូប រឺ ច្រើនរូប ជាជំនួយការ ។

មាត្រា ៧..

តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធគ្រប់គ្រង របស់សាកលវិទ្យាល័យស្វាយរៀង ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា ៨..

ក្រសួងអប់រំ យុវជន និងកីឡា ត្រូវរៀបចំមន្ត្រីរាជការ ក្របខ័ណ្ឌមុខងារសាធារណៈ ឱ្យបំរើការនៅក្នុងសាកលវិទ្យាល័យស្វាយរៀង តាមការសម្រេចយល់ព្រម ពីទីស្តីការគណៈរដ្ឋមន្ត្រី ។

មាត្រា ៩..

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលខេត្តស្វាយរៀង ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល** :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
"ដើម្បីជ្រាបជាព័ត៌មាន"
-សាលាខេត្តស្វាយរៀង "ដើម្បីមុខការ"
-ដូចមាត្រា ៩ "ដើម្បីអនុវត្ត"
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៤៥០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន

-បានឃើញអនុក្រឹត្យលេខ ១០២ អនក្រ ចុះថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០០១ ស្តីពីការតំឡើងនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ទៅជាអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្ត ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល

-យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

## សម្រេច

**មាត្រា១ :** តែងតាំងលោក **ខាន់ មុនីនាថ** ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានបច្ចេកទេស ក្រសួងបរិស្ថាន។

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០០៥

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច និងឯកឧត្តមឧបនាយករដ្ឋមន្ត្រី
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ដូចមាត្រា២
-រាជកិច្ច ✓
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...៤៥១...អនក្រ.តត

# អនុក្រឹត្យ

## ស្តីពី

## ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ .

## សម្រេច

**មាត្រា ១ :** ត្រូវបានប្រគល់ភារកិច្ចជូនលោក **ខាវ ឃួត** ឋានន្តរសក្តិ វរសេនីយ៍ទោ នៃក្របខ័ណ្ឌមន្ត្រីកងយោធពលខេមរភូមិន្ទ អោយទទួលមុខតំណែងជាអភិបាលស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ ។

**មាត្រា ២ :** លោក **ខាត ហួត** ត្រូវបានទទួលប្រាក់បំណាច់មុខងារក្នុងមុខតំណែងថ្មីនេះ ស្របតាមព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្ដីពីបៀវត្សមូលដ្ឋាន និង ប្រាក់បន្ទាប់បន្សំ នៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល ។ ក្នុងរយៈពេលបំពេញភារកិច្ចថ្មីនេះ សាមីខ្លួនត្រូវដាក់ពាក្យសុំស្ថិតនៅក្រៅក្របខ័ណ្ឌដើម ។

**មាត្រា ៣ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៤ :** រដ្ឋមន្ត្រី ទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០០៥*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៤*
- *ឯកសារ កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤៥៧ អនក្រ.តត

# អនុក្រឹត្យ
# ស្តីពី
# ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត /០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/ នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស / រកម / ០១៩៦ / ១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រម លេខ ០៦ / នស / ៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពី សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត / ០៤០១ / ០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- យោងតាមសំណើ របស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

## សំរេច

**មាត្រា ១ :** តែងតាំងលោក **លុយ ដាវីត** បច្ចុប្បន្នជំនួយការផ្ទាល់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជាប្រធាននាយកដ្ឋានអង្គការហ្វ្រង់កូហ្វូនី នៃក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ដោយរក្សាការឡើងឋានន្តរស័ក្តិនិងថ្នាក់ ទៅតាមគោលការណ៍ដែលមានចែងក្នុងលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**កន្លែងទទួលៈ**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ** ៤៥៣ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពី
## ការបញ្ចប់អាណត្តិបេសកកម្មរបស់មន្ត្រីការទូត

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/ នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស / រកម / ០១៩៦ / ១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រម លេខ ០៦ / នស / ៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត / ០៤០១ / ០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- យោងតាមសំណើ របស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

## សំរេច

**មាត្រា ១ :** ផ្លាស់លោក **ស៊ា គុសល** បច្ចុប្បន្នអគ្គទីប្រឹក្សានៃស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំសហរដ្ឋអាមេរិក ដើម្បីអោយទទួលមុខតំណែងថ្មី នៅស្ថានបេសកកម្មអចិន្ត្រៃយ៍ នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំអង្គការសហប្រជាជាតិ ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ ឧសភា ឆ្នាំ ២០០៥*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៤៥៤ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងមន្ត្រីការទូតជាន់ខ្ពស់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត /០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/ នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស / រកម / ០១៩៦ / ១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រម លេខ ០៦ / នស / ៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពី សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត / ០៤០១ / ០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- យោងតាមសំណើ របស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

## សំរេច

**មាត្រា ១ :** តែងតាំងលោក **ណៃ ម៉េងអ៊ាង** បច្ចុប្បន្នប្រធាននាយកដ្ឋានអង្គការអន្តរជាតិ នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជាអគ្គទីប្រឹក្សា នៃស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំសហរដ្ឋអាមេរិក ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ ឧសភា ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...៤៥៥...អនក្រ.តត

# អនុក្រឹត្យ

## ស្តីពី

## ការកែសម្រួលមាត្រា១ នៃអនុក្រឹត្យលេខ ២៦៨ អនក្រ.តត ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០០ ស្តីពីការតែងតាំង និង កែសម្រួលសមាសភាពគណៈកម្មការ POW / MIA កម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ១៩១/អនក្រ.តត ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងប្រធានគណៈកម្មការ POW / MIA កម្ពុជា
- បានឃើញអនុក្រឹត្យលេខ ២៦៨/អនក្រ.តត ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពគណៈកម្មការ POW / MIA កម្ពុជា
- យោងតាមសំណើរបស់ប្រធានគណៈកម្មការ POW / MIA កម្ពុជា

## សម្រេច

**មាត្រាមួយ** : ត្រូវបានកែសម្រួលមាត្រា១ នៃអនុក្រឹត្យលេខ ២៦៨ អនក្រ.តត ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពគណៈកម្មការ POW / MIA កម្ពុជា ដូចតទៅ :

**មាត្រា១ថ្មី** : ត្រូវបានតែងតាំង និងកែសម្រួលសមាសភាពគណៈកម្មការ POW / MIA កម្ពុជា សំរាប់ស្រាវជ្រាវ រុករកអដ្ឋិធាតុទាហានអាមេរិកបាត់ខ្លួននៅកម្ពុជា ដូចមានរាយនាមខាងក្រោម :

១- ឯកឧត្តមនាយឧត្តមសេនីយ៍ផ្កាយមាស៤ ម៉ុល **សាមឿន** អគ្គមេបញ្ជាការរង និងជានាយសេនាធិការចំរុះ នៃកងយោធពលខេមរភូមិន្ទ ប្រធាន

២- ឯកឧត្តម **នឹម ច័ន្ទតារា** អនុរដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ អនុប្រធាន

៣- ឯកឧត្តម **សៀង ឡាប្រេស្ស** អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ អនុប្រធាន

៤- លោក **ជ័យ សារ៉ុន** ប្រធានគណៈកម្មការស្រាវជ្រាវប្រវត្តិសាស្ត្របក្ស អនុប្រធាន

៥- លោក **ជុំ សុយ៉ាត** អនុប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ ក្រសួងមហាផ្ទៃ សមាជិកអចិន្ត្រៃយ៍

៦- ឯកឧត្តម អភិបាលខេត្ត ក្រុង សមាជិក

៧- ឯកឧត្តម **គាំ សុខុន** ជំនួយការសម្តេចនាយករដ្ឋមន្ត្រី សមាជិក

៨- លោក **គឹម ចាន់នី** ប្រធានការិយាល័យ ( អាំងទែរប៉ូល) ក្រសួងមហាផ្ទៃ សមាជិក

៩- លោក **ខៀវ សាម៉ន** អនុប្រធានមន្ទីរប្រឆាំងគ្រឿងញៀន ក្រសួងមហាផ្ទៃ សមាជិក

១០- តំណាងក្រសួងសុខាភិបាល សមាជិក

១១- តំណាងនាយកដ្ឋានអាមេរិក នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សមាជិក

**មាត្រាពីរ** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ ប្រធានគណៈកម្មការ POW / MIA កម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន អភិបាលខេត្ត ក្រុង ដែលពាក់ព័ន្ធ និងសមាសភាពដូចមានចែងក្នុងមាត្រា១ថ្មី ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែឧសភា ឆ្នាំ២០០៥

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច និងឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ដូចមាត្រាពីរ
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៤៥៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការ ប្រព្រឹត្តិទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

## ស ម្រេ ច

**មាត្រា ១:** ត្រូវបានតែងតាំងលោក **ឡុង ម៉ុនថន** ជាទីប្រឹក្សាក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានឋានៈស្មើ **អគ្គនាយករង** ។

**មាត្រា ២:** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ឆ្នាំ២០០៥

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច និងឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ....៤៥៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

៛

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១** : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន០២រូប ដែលបានបរិច្ចាគធនធានជួយកសាងសមិទ្ធផលផ្សេងៗ នៅវត្តជ្រៃមាសសាគរ ស្ថិតក្នុងឃុំព្រែកដំបង ស្រុកមុខកំពូល ខេត្តកណ្តាល ដូចមានរាយនាមខាងក្រោម :-

១-លោក **សម វណ្ណស៊ី** រស់នៅសហរដ្ឋអាមេរិក ថវិកាចំនួន ១១.៨២៥ ដុល្លារ

២-លោក **ឈិន ឈាង** រស់នៅសហរដ្ឋអាមេរិក ថវិកាចំនួន ១១.១៨៥ ដុល្លារ

**មាត្រា២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច ✓
- ឯកសារ-កាលប្បវត្តិ

B.124

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ....៤៥៨....អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និង ជូនសប្បុរសជន ចំនួន១៥រូប ដែលបានបរិច្ចាគបច្ច័យ និង ថវិកា ចូលរួមជួយកសាងសមិទ្ធផលជាច្រើន លើវិស័យព្រះពុទ្ធសាសនា និង វិស័យអប់រំ នៅសាលាបឋមសិក្សា កំពង់ថ្ម សាលាបឋមសិក្សាស្ទឹងជិនិត សាលាបឋមសិក្សាបន្ទាយយោមរាជ សាលាតំរូបល្លង្គ សាលាបឋមសិក្សាព្រៃក វិទ្យាល័យកំពង់ថ្ម វិទ្យាល័យជាស៊ីម កំពង់ថ្ម និង នៅក្នុងពុទ្ធសីមាវត្តជិនិត ឃុំកំពង់ថ្ម ស្រុកសន្ទុក ខេត្តកំពង់ធំ ដូចមានរាយព្រះនាម និង នាម ខាងក្រោមនេះ :-

**ក-មេដាយមាសស្ថាបនាជាតិ :**

១-ភិក្ខុ **ស៊ិន សោភ័ណ** ព្រះវិន័យធរ អនុគណ សមាជិកអភិបាលកិច្ចសង្ឃ និង ជាព្រះចៅអធិការវត្តជិនិត បច្ច័យចំនួន ៤៥.២០០ ដុល្លារ

២-ភិក្ខុ **អៀម ហ៊ីរ** គ្រូសូត្រស្តាំ វត្តជិនិត បច្ច័យចំនួន ២១.០០០ដុល្លារ

៣-ភិក្ខុ **សោម ខាន** គ្រូសូត្រឆ្វេង វត្តជិនិត បច្ច័យចំនួន ១៨.០០០ដុល្លារ

៤-លោក **ខា ខាតិ** និងអ្នកស្រី **ឯម ម៉ាច** ប្រធានសង្គមកិច្ចខេត្តកំពង់ធំ ថវិកាចំនួន ១២.០០០ ដុល្លារ

៥-ឧបាសក **ស៊ិន សែម** ឧបាសិកា **អ៊ុំ សិត** សប្បុរសជន ថវិកាចំនួន ១០.៥០០ ដុល្លារ

**ខ-មេដាយគ្រាក់ស្ថាបនាជាតិ :**

| | | | |
|---|---|---|---|
| ១-ភិក្ខុ **ម៉ែន ចាន់** | សប្បុរសជន | ថវិកាចំនួន | ៥.០០០ ដុល្លារ |
| ២-ភិក្ខុ **អ៊ុំ អេន** | សប្បុរសជន | ថវិកាចំនួន | ៥.០០០ ដុល្លារ |

**គ-មេដាយសំរិទ្ធស្ថាបនាជាតិ :**

| | | | |
|---|---|---|---|
| ១-ឧបាសក **ចាន់ ឃិន** | សប្បុរសជន | ថវិកាចំនួន | ៣.១០០ ដុល្លារ |
| ២-ឧបាសក **ឈៀង នី** | សប្បុរសជន | ថវិកាចំនួន | ២.៥០០ ដុល្លារ |
| ៣-ឧបាសក **នួន ញឹម** | សប្បុរសជន | ថវិកាចំនួន | ១.៨០០ ដុល្លារ |
| ៤-ឧបាសិកា **ហ៊ឹម ហ៊ុំ** | សប្បុរសជន | ថវិកាចំនួន | ១.៦៥០ ដុល្លារ |
| ៥-ឧបាសិកា **នេខ យ៉ន់** | សប្បុរសជន | ថវិកាចំនួន | ១.៥០០ ដុល្លារ |
| ៦-ឧបាសិកា **លុយ រី** | សប្បុរសជន | ថវិកាចំនួន | ១.២០០ ដុល្លារ |
| ៧-ឧបាសក **ចូយ លី** និងឧបាសិកា **ឆាក់ ម្ញូ** | សប្បុរសជន | ថវិកាចំនួន | ១.២០០ ដុល្លារ |
| ៨-អ្នកគ្រូ **យឹម សីហា** | សប្បុរសជន | ថវិកាចំនួន | ១.១៥០ ដុល្លារ |

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា និង អភិបាលខេត្តកំពង់ធំ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០០៥

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច ✓
- ឯកសារ-កាលប្បវត្តិ

171

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:....៤៤៧...អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១** : ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូន សប្បុរសជន ចំនួន១២រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាងព្រះវិហារថ្មី ០១ខ្នង នៅវត្តឫទ្ធិសែនមានជ័យ ហៅ វត្តសាំងរាំង ឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង ដូចមានរាយនាមខាងក្រោម :-

**ក-មេដាយមាសស្ថាបនាជាតិ :**

១-**អាចារ្យគណៈកម្មការ** វត្តឫទ្ធិសែនមានជ័យ ហៅ វត្តសាំងរាំង ថវិកា ៤៤.៣១៨ ដុល្លារ

២-ឧបាសក **អ៊ុក គិល** និង ឧបាសិកា **សៀង នេង** សប្បុរសជននៅខេត្តបាត់ដំបង ថវិកា ១០.០០០ ដុល្លារ

**ខ-មេដាយប្រាក់ស្ថាបនាជាតិ :**

១-ឧបាសិកា **ម៉ៅ ឡាមុន** សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក ថវិកា ៧.៩៥០ ដុល្លារ

២-លោក **រី នេង** និងលោកស្រី **ចុង នេង** សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក ថវិកា ៧.៤៣១ដុល្លារ

**គ-មេដាយសំរិទ្ធស្ថាបនាជាតិ :**

១-ឧបាសក **ឡើង សុខ** និងឧបាសិកា **ផាង សោន** សប្បុរសជននៅខេត្តបាត់ដំបង ថវិកា ៣.៣០០ ដុល្លារ

២-លោក **ម៉េន ឆឿ** និងលោកស្រី **សួន ហេង** សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក ថវិកា ៣.១០២ដុល្លារ

៣-លោក **ជុំ ឈួន** និងលោកស្រី **ម៉ា អឿន** សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក ថវិកា ២.៧៩៤ដុល្លារ

៤-ឧបាសិកា **ឡុច នៀង** សប្បុរសជននៅខេត្តបាត់ដំបង ថវិកា ២.៦០០ ដុល្លារ
៥-លោក **កៀង សល់** និងលោកស្រី **អ៊ុំ ម៉ែន** សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក ថវិកា ២.៥០០ដុល្លារ
៦-ឧបាសក **ម៉ែត ស៊ុំ** និងឧបាសិកា **ឡេង** សប្បុរសជននៅខេត្តបន្ទាយមានជ័យ ថវិកា ២.១៥០ដុល្លារ
៧-ឧបាសិកា **ចាន់ ម៉ៀន** សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក ថវិកា ១.១៣៧ដុល្លារ
៨-ឧបាសក **សាន ឌុច** និងឧបាសិកា **លឹម ម៉ុន** សប្បុរសជននៅខេត្តបាត់ដំបង ថវិកា ១.០០០ដុល្លារ

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/

រាជធានីភ្នំពេញ ថ្ងៃទី ៧៥ ខែ ឧសភា ឆ្នាំ ២០០៥

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**
- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ដូចក្នុងមាត្រា ១ និង មាត្រា ២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

32-133

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤៦០ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និង ជូនសប្បុរសជន ចំនួន០៦រូប ដែលបានបរិច្ចាគបច្ច័យ និង ថវិកា ចូលរួមជួយកសាង ព្រះវិហារ សាលាឆាន់ របង និង បន្ទប់អនាម័យ នៅក្នុងពុទ្ធសីមា វត្តសុវណ្ណបុប្ផារាម ហៅ វត្តសំរោង ឃុំគ្បឿងរាយ ស្រុកកញ្ជ្រៀច ខេត្តព្រៃវែង ដូចមានរាយព្រះនាមនិងនាមខាងក្រោមនេះ :-

**ក_មេដាយមាសស្ថាបនាជាតិ :**

| | | |
|---|---|---|
| ១-ឧបាសិកា **ឃុន តាំងអ៊ីច** | នៅសហរដ្ឋអាមេរិក | ថវិកា ចំនួន ២២.៥០០ ដុល្លារ |
| ២-លោក **យ៉េង សារឿន** | សប្បុរសជន | ថវិកាចំនួន ១៧.៨៤០ ដុល្លារ |

**ខ_មេដាយប្រាក់ស្ថាបនាជាតិ :**

| | | |
|---|---|---|
| ១-លោក **ប៊ិត ឈីមស៊ុន** | សប្បុរសជន | ថវិកាចំនួន ៨.៩៥០ ដុល្លារ |
| ២-លោក **ឯក ពុធស៊ីម** | សប្បុរសជន | ថវិកាចំនួន ៨.៧៩០ ដុល្លារ |
| ៣-ព្រះតេជគុណ **នូ ខេង** | ព្រះចៅអធិការវត្តសុវណ្ណបុប្ផារាម | បច្ច័យចំនួន ៦.៧០០ ដុល្លារ |
| ៤-លោក **ឈុន អ៊ីន** | សប្បុរសជន | ថវិកាចំនួន ៦.២៥០ ដុល្លារ |

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា និង អភិបាលខេត្តព្រៃវែង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ [illegible] ឆ្នាំ ២០០៥

ហ៊ុន សែន

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

Sb.168

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៤៦១ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមសំណូមពរការងារចាំបាច់

**ស ម្រេ ច**

**មាត្រា ១ :** តែងតាំង :

១_លោក សោម អូន ជាជំនួយការអមទីស្តីការគណៈរដ្ឋមន្ត្រី ទទួលបន្ទុកការងារសហជីព មានឋានៈស្មើ **អគ្គនាយករង** ។

២_លោក ថៅ វាសនា ជាជំនួយការអមទីស្តីការគណៈរដ្ឋមន្ត្រី ទទួលបន្ទុកការងារសង្គមស៊ីវិល អង្គការក្រៅរដ្ឋាភិបាល និងសិទ្ធិមនុស្ស មានឋានៈស្មើ **អគ្គនាយករង** ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ ឧសភា ឆ្នាំ ២០០៥*

**ហ៊ុន សែន**

**កន្លែងទទួល**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *ឯកសារ_កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៤០៧ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ ០៦ / នស / ៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស / រកម / ០១៩៦ / ១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យ លេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

### សម្រេច

**មាត្រា ១ :** ត្រូវបានប្រគល់ភារកិច្ចជូន លោក **សូ ខនឬទ្ធិគុណ** ជាប្រធាននាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច និងឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៤៧៣ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន ០២រូប ដែលបានបរិច្ចាគថវិកា ជួយកសាង ទីតាំងបញ្ជាការកងពលតូច លេខ២១ ដូចមានរាយនាមខាងក្រោម :-

១-ឧត្តមសេនីយ៍ត្រី **អ៊ុន ស៊ីដារ៉ា** មេបញ្ជាការកងពលតូច លេខ២១ ថវិកា ចំនួន ៣៧.៩៧១ ដុល្លារ

២-អនុសេនីយ៍ឯក **អាន ម៉ាឌី** ជំនាញឯកទេសកងពលតូចលេខ២១ ថវិកា ចំនួន ១០.៤០០ ដុល្លារ

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះអោយ ទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០៥

ហ៊ុន សែន

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច ✓
- ឯកសារ-កាលប្បវត្តិ

B.160

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤៧៤ អនក្រ.ធក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន២១រូប ដែលបានបរិច្ចាគថវិកា ចូលរួមជួយកសាងព្រះវិហារ នៅក្នុងពុទ្ធសីមាវត្តទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ដូចមានរាយនាមខាងក្រោមនេះ :-

**ក-មេដាយមាសស្ថាបនាជាតិ :**

| | | | |
|---|---|---|---|
| ១-ឧបាសិកា | **ហេង ឡុងហាន** | ថវិកាចំនួន | ១២.៥០០ ដុល្លារ |
| ២-លោក | **អ៊ួង អ៊ុន** | ថវិកាចំនួន | ១២.៦៥០ ដុល្លារ |
| ៣-លោក | **ញ៉ែម ប៉ូ** | ថវិកាចំនួន | ១២.១៦០ ដុល្លារ |
| ៤-លោក | **លាង គិត** | ថវិកាចំនួន | ១២.០៥០ ដុល្លារ |
| ៥-លោក | **យ៉ោក ម៉ៅ** | ថវិកាចំនួន | ១៣.១៨០ ដុល្លារ |
| ៦-ឧបាសិកា | **នួន ផន** | ថវិកាចំនួន | ១៣.១១០ ដុល្លារ |
| ៧-ឧបាសិកា | **ឯម វណ្ណៈ** | ថវិកាចំនួន | ១២.០០០ ដុល្លារ |
| ៨-អ្នកស្រី | **ព្រុំ នាង** | ថវិកាចំនួន | ១៣.២០០ ដុល្លារ |

**ខ-មេដាយប្រាក់ស្ថាបនាជាតិ :**

| | | | |
|---|---|---|---|
| ១-លោក | **ហ៊ឹម ហៀម** | ថវិកាចំនួន | ៩.១៥០ ដុល្លារ |
| ២-លោក | **អ៊ា ឃីម** | ថវិកាចំនួន | ៨.៥៧០ ដុល្លារ |

| | | | | |
|---|---|---|---|---|
| ៣-លោក | **សំ** | **ផាន** | ថវិកាចំនួន | ៦.៥៥០ ដុល្លារ |
| ៤-អ្នកស្រី | **ឃូ** | **ការលីន** | ថវិកាចំនួន | ៥.២៧០ ដុល្លារ |
| ៥-អ្នកស្រី | **លឹម** | **សូ** | ថវិកាចំនួន | ៥.៧១០ ដុល្លារ |
| ៦-លោក | **ហៀក** | **ទ្រី** | ថវិកាចំនួន | ៥.១៥០ ដុល្លារ |
| ៧-លោក | **ហែម** | **រិន** | ថវិកាចំនួន | ៧.៣២០ ដុល្លារ |
| ៨-ឧបាសិកា | **លី** | **គីមសុខ** | ថវិកាចំនួន | ៥.៧៧០ ដុល្លារ |
| ៩-ឧបាសិកា | **លី** | **គីមសេង** | ថវិកាចំនួន | ៥.៥៥០ ដុល្លារ |
| ១០-ឧបាសិកា | **ឈុន** | **មួយ** | ថវិកាចំនួន | ៥.២៥០ ដុល្លារ |
| ១១-ឧបាសិកា | **អ៊ា** | **ខួន** | ថវិកាចំនួន | ៨.៤០០ ដុល្លារ |
| ១២-ឧបាសិកា | **ជា** | **អ៊ាន់ណូ** | ថវិកាចំនួន | ៦.៧០០ ដុល្លារ |
| ១៣-ឧបាសិកា | **តឹក** | **ហេង** | ថវិកាចំនួន | ៦.៣១០ ដុល្លារ |

**មាត្រា២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា និង អភិបាលរាជធានីភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០៥

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល** :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

Sb.188

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:...៤៦៥...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

&&&&&

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស /រកត /០៧០៤ /១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ១០៩៥ /០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា

**ស ម្រេ ច**

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជនជប៉ុនចំនួន ០១ រូប និង សមាគមជប៉ុនចំនួន ០៤ ដែលបានឧបត្ថម្ភថវិកា ជួយកសាងអគារសិក្សា និង សមិទ្ធផលផ្សេងៗទៀត បំរើអោយវិស័យអប់រំ នៅស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ដូចមានរាយនាមខាងក្រោម ÷

១-លោកស្រី **TOMIE KUWABARA** ប្រធានអង្គការ Happy Apple ជួយកសាងសាលាបឋមសិក្សាល្វៃ ឃុំត្រពាំងឫស្សី អស់ទឹកប្រាក់ចំនួន ៣២.៥០០ USD ។

២-សមាគម **GEDATSU-KAI , JAPAN** ជួយកសាង សាលាបឋមសិក្សាល្វា ភូមិល្វា អស់ទឹកប្រាក់ចំនួន ១៦.៨៦៩ USD ។

៣-សមាគម **SEIKO EPSON LABOR UNION** ជួយកសាង សាលាបឋមសិក្សាព្រៃទប់ ឃុំជ័យ អស់ទឹកប្រាក់ចំនួន ១៦.៨៦៩ USD ។

៤-សមាគម **SECOND HAND ,JAPAN** ជួយកសាង សាលាបឋមសិក្សាកប់ផ្តុក ឃុំដំរីស្លាប់ អស់ទឹកប្រាក់ចំនួន ២៥.២២៥.៩០ USD ។

៥-សមាគម **ICHIKANJI –VOLUNTEER ASSOCIATION** ជួយកសាងសាលាបឋមសិក្សាសង្គម ឃុំដំរីស្លាប់ អស់ទឹកប្រាក់ចំនួន ១៦.៩៣៥.៦៥ USD ។

**មាត្រា២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា និង អភិបាលខេត្តកំពង់ធំ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០៥

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៤៦៦ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ អភិបាលខេត្តកណ្តាល

## សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន ០៧រូប ដែលបានបរិច្ចាគធនធានជួយកសាងសមិទ្ធផលនានា ក្នុងវិស័យព្រះពុទ្ធសាសនា និងសង្គម នៅវត្តច័ន្ទបូរីវង្ស ឃុំសំរោង ស្រុកពញាឮ ខេត្តកណ្តាល ដូចមានរាយនាមខាងក្រោម :-

| | | |
|---|---|---|
| ១-អ្នកស្រី | **អ៊ីវ ស្រ៊ី** | បរិច្ចាគថវិកា ចំនួន ១៣.០០០ ដុល្លារ |
| ២-អ្នកស្រី | **គង ច័ន្ទនី** | បរិច្ចាគថវិកា ចំនួន ១៣.៥០០ ដុល្លារ |
| ៣-លោកជំទាវ | **សុខ ឡេងបូរ៉ា** | បរិច្ចាគថវិកា ចំនួន ១២.០០០ ដុល្លារ |
| ៤-លោកជំទាវ | **ឡូរី សុខា** | បរិច្ចាគថវិកា ចំនួន ១២.៥០០ ដុល្លារ |
| ៥-លោកស្រី | **កែវ ពេជ្រស៊ីថុល** | បរិច្ចាគថវិកា ចំនួន ១២.៥០០ ដុល្លារ |
| ៦-លោក | **ម៉ី ចិន្ត្រា** | បរិច្ចាគថវិកា ចំនួន ១២.៥០០ ដុល្លារ |
| ៧-លោក | **ឡុង ដារ៉ា** | បរិច្ចាគថវិកា ចំនួន ១២.៥០០ ដុល្លារ |

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ.ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០៥

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

Sr.67-68

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ:...៤៦៧......អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

&&&&&

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ១០៩៥ /០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ ប្រធានក្រុមប្រឹក្សាជាតិ ស្តីពីអាហារូបត្ថម្ភជាតិ

## សម្រេច

**មាត្រា ១:** ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនផលិតករអំបិល និង តំណាងពាក់ព័ន្ធ ដែលបានចូលរួមចំណែកលុបបំបាត់បញ្ហាកង្វះជាតិអ៊ីយ៉ូដ នៅកម្ពុជា កង្វះប្រូតេអ៊ីន , ថាមពល , ជីវជាតិអា , ជាតិដែក ព្រមទាំងជួយឧបត្ថម្ភ ទាំងបច្ចេកទេស និង ថវិកា ដល់កម្មវិធីកង្វះជាតិ អ៊ីយ៉ូដ នៅកម្ពុជា ដូចមាននាមខាងក្រោម :

**ក_មេដាយមាសការងារ :**

| | |
|---|---|
| ១-លោកស្រី **ខៀវ ប៊ូរី** | អគ្គនាយករងផែនការ នៃក្រសួងផែនការ |
| ២-លោក **ពឹង ស៊ីវឡាយ** | ប្រធាននាយកដ្ឋានស្តង់ដារ នៃក្រសួងឧស្សាហកម្មរ៉ែ និងថាមពល |
| ៣-លោក **ម៉ម ប៊ុនរ៉ាត់** | អនុប្រធាននាយកដ្ឋានផែនការសង្គមកិច្ច នៃក្រសួងផែនការ |
| ៤-លោក **ទ៉ែន គៀងហាក់** | ប្រធានការិយាល័យ នៃក្រសួងឧស្សាហកម្មរ៉ែ និងថាមពល |
| ៥-លោក **អ៊ុន សំអឿន** | អ្នកជំនួយការផ្នែកសុខភាព និងអាហារូបត្ថម្ភ នៃ UNICEF |
| ៦-លោក **ចាន់ ពន្លឺវឌ្ឍនា** | អនុប្រធានការិយាល័យ ក្រសួងអភិវឌ្ឍន៍ជនបទ |
| ៧-លោក **នួន ម៉ួន** | សហប្រធានសហគមន៍អ្នកផលិតអំបិល ខេត្តកំពត ក្រុងកែប |
| ៨-លោក **ម៉ុន ឈារ៉ាំង** | សហប្រធានគណៈកម្មការប្រតិបត្តិ សហគមន៍ |

**ខ-មេដាយគ្រាក់ការងារ :**

១-លោក **នូច សារា** មន្ត្រីមជ្ឈមណ្ឌលគាំពារមាតានិងទារក នៃក្រសួងសុខាភិបាល

២-លោក **ឯក សុខន** អនុប្រធានការិយាល័យ នៃក្រសួងឧស្សាហកម្មរ៉ែ និងថាមពល

៣-លោក **អ៊ូ កេសវណ្ណា** ប្រធានការិយាល័យ នៃក្រសួងសុខាភិបាល

៤-លោក **ហួយ វណ្ណថា** អនុប្រធានការិយាល័យ កាំកុងត្រូល នៃក្រសួងពាណិជ្ជកម្ម

៥-លោក **ជីវ ហៀយ** សហប្រធានសហគមន៍ អ្នកផលិតអំបិល ខេត្តកំពត ក្រុងកែប

៦-លោក **លី សេង** សហប្រធានគណៈកម្មការប្រតិបត្តិ សហគមន៍

៧-លោក **គុយ យូ** តំណាងសិប្បកម្មផលិតអំបិល អ៊ីយ៉ូដ រាជធានីភ្នំពេញ

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ប្រធានក្រុមប្រឹក្សាជាតិ ស្តីពីអាហារូបត្ថម្ភជាតិ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០៥

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៤៦៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយសហមេត្រី

&&&&&

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ១០៩៥ /០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ ប្រធានក្រុមប្រឹក្សាជាតិ ស្តីពីអាហារូបត្ថម្ភជាតិ

## សម្រេច

**មាត្រា ១** :ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **អស្សឫទ្ធិ** ជូនតំណាងអង្គការចំនួន០២ ដែលមានស្នាដៃល្អ ក្នុងការជំរុញកម្មវិធីលុបបំបាត់បញ្ហាកង្វះជាតិអ៊ីយ៉ូដ នៅកម្ពុជា ដូចមានឈ្មោះខាងក្រោម :

១-លោក **RODNEY HATFIELD** ប្រធានអង្គការ **UNICEF** ប្រចាំកម្ពុជា

២-លោក **JAMES TULLOCH** តំណាងអង្គការ **WHO** ប្រចាំកម្ពុជា

**មាត្រា ២** :រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ប្រធានក្រុមប្រឹក្សាជាតិ ស្តីពីអាហារូបត្ថម្ភជាតិ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០៥

**ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច ✓
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ៤៧៥ អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពីការតម្លើងឋានន្តរស័ក្តិនាយទាហានជាន់ខ្ពស់

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសំរួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គមេបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យ លេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជា

### សម្រេច

**មាត្រា ១:** ត្រូវបានតម្លើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ឯក** ជូននាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ចំនួន ១៥ រូប ដូចមានរាយនាមខាងក្រោម :

| | | | |
|---|---|---|---|
| ១- វរសេនីយ៍ទោ | **ហួន សារឿន** | អត្តលេខ | ០១៩៧០២ |
| ២- វរសេនីយ៍ទោ | **ទ៉េត សំណាង** | អត្តលេខ | ០១១០១៣ |
| ៣- វរសេនីយ៍ទោ | **ជុំ សោភ័ណ្ឌ** | អត្តលេខ | ០១០៩៩៨ |
| ៤- វរសេនីយ៍ទោ | **ឈុន គឹមស្រ៊ុន** | អត្តលេខ | ០០២៧២៦ |
| ៥- វរសេនីយ៍ទោ | **អ៊ុក ដារ៉ា** | អត្តលេខ | ០១១៤៤៦ |
| ៦- វរសេនីយ៍ទោ | **មុំ ស៊ីម៉ែតថា** | អត្តលេខ | ០១១៦១៥ |

| | | | |
|---|---|---|---|
| ៧- វរសេនីយ៍ទោ | **ឡាច ម៉ាន់** | អត្តលេខ | ០០៣៣៨៥ |
| ៨- វរសេនីយ៍ទោ | **អ៊ូរ សុខខា** | អត្តលេខ | ២៣១៤៧៤ |
| ៩- វរសេនីយ៍ទោ | **ស្រី នាយ** | អត្តលេខ | ១៣៨៦៧៧ |
| ១០- វរសេនីយ៍ទោ | **មាស ស៊ីណា** | អត្តលេខ | ០០១៦៦៧ |
| ១១- វរសេនីយ៍ទោ | **សុខ ស៊ីលា** . | អត្តលេខ | ០១១៤៦២ |
| ១២- វរសេនីយ៍ទោ | **លី សុខហេង** | អត្តលេខ | ១៣៨៦៣៥ |
| ១៣- វរសេនីយ៍ទោ | **សុខ សុវណ្ណនិត** | អត្តលេខ | ០១១៦១០ |
| ១៤- វរសេនីយ៍ទោ | **កែម ថន** | អត្តលេខ | ០០៣៧៨៦ |
| ១៥- វរសេនីយ៍ទោ | **ឆេត ចិន្ត្រា** | អត្តលេខ | ០០៣៣៧៥ |

**មាត្រា ២:** រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**<u>កន្លែងទទួល</u> :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច និងឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ ៤៧០ អនក្រ.តត

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១** ៖ ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោកស្រី ***Krista Van Wolfswinkel*** តំណាងអង្គការ អ៊ិចកូ (*ICCO*) នៃប្រទេសហូឡង់ដ៏ ដែលបានផ្តល់ថវិកា ចំនួន ៥២៨.០៨៤ ដុល្លារ ជួយកសាងសមិទ្ធផលជាច្រើន លើវិស័យអប់រំ សង្គមកិច្ច និងវិស័យកសិកម្ម នៅក្នុងខេត្តបាត់ដំបង ។

**មាត្រា២** ៖ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ២០០៥

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល** ៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

B.138

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៤៧៧ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សម្រេច**

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ជូនតំណាងអង្គការសប្បុរសប្រចាំខេត្ត បាត់ដំបង ចំនួន០២រូប ដែលមានស្នាដៃល្អ និង គុណបំណាច់ខ្ពស់ក្នុងការស្វែងរកជំនួយ ជួយកសាង សមិទ្ធផលជាច្រើន លើវិស័យអប់រំ សង្គមកិច្ច និងវិស័យកសិកម្ម នៅក្នុងខេត្តបាត់ដំបង ដូចមានរាយ នាមខាងក្រោមនេះ :-

**ក-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ :**

- លោក **អ៊ុត គង់** នាយកប្រតិបត្តិអង្គការសប្បុរស ប្រចាំខេត្តបាត់ដំបង ខិតខំស្វែងរកជំនួយ បានចំនួន ១.៤៣២.៧៣៣ ដុល្លារ

**ខ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ អស្សឫទ្ធិ :**

- លោក **ស៊ីម សាខន** អ្នកគ្រប់គ្រងអភិវឌ្ឍន៍បុគ្គលិក និង ធនធានមនុស្ស នៃអង្គការសប្បុរស ប្រចាំខេត្តបាត់ដំបង

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ,ថ្ងៃទី ៣១ ខែ ... ឆ្នាំ ២០០៥

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១៧ សសរ

# សេចក្ដីសម្រេច

## ស្ដីពីការបង្កើតគណៈកម្មាធិការសម្របសម្រួល កិច្ចការបញ្ជូន កងកម្លាំងចូលរួមបេសកកម្មរក្សាសន្ដិភាព របស់អង្គការសហប្រជាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## <u>សម្រេច</u>

**ប្រការ ១ :** ត្រូវបានបង្កើតគណៈកម្មាធិការ សម្របសម្រួលកិច្ចការបញ្ជូនកងកម្លាំង ចូលរួមបេសកកម្មរក្សាសន្ដិភាព របស់អង្គការសហប្រជាជាតិ ដែលមានសមាសភាព ដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១_ | ឯកឧត្ដម ប្រាក់ សុខុន | រដ្ឋលេខាធិការ ទីស្ដីការគណៈរដ្ឋមន្ត្រី | ប្រធាន |
| ២_ | ឯកឧត្ដម ម៉ឺង សំផន | រដ្ឋលេខាធិការ ក្រសួងការពារជាតិ | អនុប្រធាន |
| ៣_ | ឯកឧត្ដម អ៊ុច បូររិទ្ធ | រដ្ឋលេខាធិការ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | អនុប្រធាន |
| ៤_ | ឯកឧត្ដម អ៊ុក រ៉ាប៊ុន | រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៥_ | ឯកឧត្ដម ជា តារា | នាយរងសេនាធិការចំរុះ នៃកងយោធពលខេមរភូមិន្ទ | សមាជិក |
| ៦_ | ឯកឧត្ដម សំ ខណ្ឌថន | អគ្គលេខាធិការ អគ្គលេខាធិការដ្ឋាន ក្រសួងការពារជាតិ | សមាជិក |
| ៧_ | ឯកឧត្ដម ស៊ុំ សំណាង | អគ្គនាយក អគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ ក្រសួងការពារជាតិ | សមាជិក |
| ៨_ | ឯកឧត្ដម ចៅ តីរុណ | អគ្គនាយក អគ្គនាយកដ្ឋានសំភារៈ បច្ចេកទេស ក្រសួងការពារជាតិ | សមាជិក |

| | | | |
|---|---|---|---|
| ៩_ ឯកឧត្តម | មាស សាម៉ន | អគ្គនាយក អគ្គនាយកដ្ឋានយោធសេវា ក្រសួងការពារជាតិ | សមាជិក |
| ១០_ ឯកឧត្តម | ណឹម សុវត្ថិ | ទីប្រឹក្សា និងជានាយកខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ទៀ បាញ់ | សមាជិកអចិន្ត្រៃយ៍ |
| ១១_ ឯកឧត្តម | ខ្វាន់ ស៊ាម | មេបញ្ជាការ បញ្ជាការដ្ឋានកងវិស្វកម្ម អគ្គបញ្ជាការ | សមាជិក |
| ១២_ ឯកឧត្តម | ឆែម ពេត | ទីប្រឹក្សា និងជានាយកខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ញ៉ឹក ប៊ុនឆៃ | សមាជិក |
| ១៣_ ឯកឧត្តម | មាស សំអុល | នាយក នាយកដ្ឋានបុគ្គលិក ក្រសួងការពារជាតិ | សមាជិក |
| ១៤_ឯកឧត្តម | សែម សុវណ្ណនី | អគ្គលេខាធិការរង អាជ្ញាធរជាតិកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន | សមាជិក ។ |

**ប្រការ ២** : គណៈកម្មាធិការនេះមានភារកិច្ច :

_សម្របសម្រួលកិច្ចការទាំងឡាយ ដែលមានការពាក់ព័ន្ធនឹងការត្រៀមរៀបចំកងកម្លាំង ទៅចូលរួមប្រតិបត្តិការរក្សាសន្តិភាព របស់អង្គការសហប្រជាជាតិ ជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ។

_តាមដានបូកសរុបរាយការណ៍ និងលើកយោបល់ជូនរាជរដ្ឋាភិបាលជ្រាបនិងសម្រេច រាល់កិច្ចការដែលមានការពាក់ព័ន្ធខាងលើនេះ ។

_ធ្វើកិច្ចការមួយចំនួនទៀត តាមការប្រគល់ភារកិច្ចពីរាជរដ្ឋាភិបាល ។

**ប្រការ ៣** : គណៈកម្មាធិការនេះ ត្រូវចូលរួមប្រជុំ តាមការអញ្ជើញរបស់ប្រធាន ។

**ប្រការ ៤** : គណៈកម្មាធិការនេះ មានសិទ្ធិប្រើប្រាស់ត្រា របស់ទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីបំពេញកិច្ចការរបស់ខ្លួន ។

**ប្រការ ៥** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

_ក្រសួងព្រះបរមរាជវាំង
_អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
_អគ្គលេខាធិការដ្ឋានរដ្ឋសភា
_ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
_ ខុទ្ទកាល័យ សម្តេច និងឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
_ ដូចមាត្រា ៥
_ ឯកសារ_កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ០៣ ស.រ.ណ៧៥

# សារាចរណែនាំ

## ស្តីពី

## ការរៀបចំខួបលើកទី៥៦ "ទិវាកុមារអន្តរជាតិ ១ មិថុនា" និងខួបលើកទី៤ "ទិវាពិភពលោកប្រឆាំងនឹងពលកម្មកុមារ ១២ មិថុនា" ឆ្នាំ២០០៥

ក្នុងអំឡុងឆ្នាំ ១៩៤២-១៩៤៤ នៃសង្គ្រាមលោកលើកទី២ ពួកហ្វាស៊ីស្តអ៊ីត្លែបានបង្កវិនាសកម្មកាប់សម្លាប់ស្ត្រី និងកុមារនៅភូមិលីឌីសែ ប្រទេសឆេក និង ភូមិអូរ៉ាឌូ ប្រទេសបារាំង។ វិនាសកម្មនេះជាបទពិសោធន៍ឈឺចាប់របស់ប្រជាជនលើពិភពលោក ដែលជាហេតុធ្វើឱ្យប្រទេសជាច្រើនលើពិភពលោកកំណត់យកថ្ងៃ ១ មិថុនា នេះ ជាទិវាកុមារអន្តរជាតិ ។ ទន្ទឹមនេះ លើសកលលោកជាពិសេស នៅក្នុងប្រទេសក្រីក្រ ឬប្រទេសអភិវឌ្ឍន៍មួយចំនួននៅតែបន្តប្រើប្រាស់ទម្រង់ពលកម្មធ្ងន់ធ្ងរមកលើកុមារ។ មានកុមារចាប់ពីអាយុ ៥ឆ្នាំ ដល់១៧ឆ្នាំ ប្រមាណ ២៤៦ លាននាក់ កំពុងធ្វើការងារ ក្នុងនោះប្រមាណជាង ១០០លាននាក់ ស្ថិតក្នុងទម្រង់ពលកម្មធ្ងន់ធ្ងរ និង ពុំមានឱកាសបានចូលរៀនសោះឡើយ។ ហេតុនេះហើយអង្គការពលកម្មអន្តរជាតិបានសម្រេចយក ថ្ងៃ១២ មិថុនា ជារៀងរាល់ឆ្នាំ ដើម្បីរំលឹកទិវាពិភពលោកប្រឆាំងនឹងពលកម្មកុមារ។

ថ្ងៃទី២០ ខែ វិច្ឆិកា ១៩៨៩ មហាសន្និបាតរបស់អង្គការសហប្រជាជាតិ បានអនុម័តលើអនុសញ្ញាស្តីពី សិទ្ធិកុមារ ។ ឆ្នាំ១៩៩០ សន្និសិទកំពូលពិភពលោកដើម្បីកុមារ បានប្តេជ្ញាចិត្តស្តីពីបង្កើនសុខុមាលភាពរបស់កុមារឱ្យកាន់តែល្អប្រសើរឡើង ក្នុងគោលដៅលើកស្ទួយសិទ្ធិរបស់កុមារឱ្យរួចផុតពីការកេងប្រវ័ញ្ចគ្រប់រូបភាព ការធ្វើអាជីវកម្មកុមារ ការកេងប្រវ័ញ្ចផ្នែកពលកម្ម និងប្រឆាំងទម្រង់ពលកម្មធ្ងន់ធ្ងររបស់កុមារ។ ទន្ទឹមនឹងនេះ ក៏បានចេញសេចក្តីអំពាវនាវជាសកល ក្នុងគោលបំណងធានានូវអនាគតដ៏ល្អប្រសើរសម្រាប់កុមារទាំងអស់។ នៅខែ ឧសភា ឆ្នាំ២០០២ សម័យប្រជុំពិសេសរបស់អង្គការសហប្រជាជាតិ ស្តីពីកុមារបានឯកភាព ចេញសេចក្តីប្រកាសរួមមួយឈ្មោះ "ពិភពលោកមួយសមស្របសម្រាប់កុមារ" ដែលឯកសារនេះគឺជាក្របខ័ណ្ឌការងារសម្រាប់រដ្ឋាភិបាល និងដៃគូទាំងអស់ ព្រមទាំងកុមារ ប្រើប្រាស់ដើម្បីសម្រេចគោលដៅ និង ដោះស្រាយការលំបាកដែលកំពុងកើតមានចំពោះកុមារ ។ ឯកសារនេះបានកំណត់បញ្ហាអាទិភាពចំនួនបួនគឺ : មួយ ការបង្កើនជីវភាពរស់នៅរបស់ស្ត្រី និងកុមារប្រកបដោយសុខភាពល្អ ពីរ ការបង្កើនគុណភាព

អប់រំ បី ការប្រយុទ្ធប្រឆាំងមេរោគអេដស៍/ជម្ងឺអេដស៍ និងបួន កិច្ចការពារកុមាររួចផុតពីការរំលោភការកេង ប្រវ័ញ្ច និងអំពើហិង្សា។ មកដល់បច្ចុប្បន្ន បណ្តាប្រទេសនៅក្នុងតំបន់អាស៊ីបូព៌ា និង ប៉ាស៊ីហ្វិច បានកោះប្រជុំ ថ្នាក់រដ្ឋមន្ត្រីចំនួន៧លើក ដើម្បីពិគ្រោះយោបល់ និងពិនិត្យឡើងវិញអំពីការរីកចំរើនដែលសម្រេចបាន សម្រាប់ កុមារកន្លងមក ព្រមទាំងចែករំលែកបទពិសោធន៍ល្អៗ និងអនុសាសន៍ថ្មីៗសំរាប់កំណត់គោលដៅនាពេល អនាគត ដើម្បីកុមារ។ លទ្ធផលនៃកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីលើកទី ៧ ស្តីពីកុមារ ដែលបានប្រារព្ធឡើងនៅ ខេត្តសៀមរាប ព្រះរាជាណាចក្រកម្ពុជា នាដើមឆ្នាំ ២០០៥ បានអនុម័តសេចក្តីប្រកាសសៀមរាប-អង្គរ ដែល គូសបញ្ជាក់ ពីការប្តេជ្ញាចិត្តរបស់បណ្តាប្រទេសក្នុងតំបន់ ដើម្បីបោះជំហានទៅមុខ និងធ្វើឱ្យសកម្មសំដៅលើក ស្ទួយឱ្យ បានប្រសើរឡើងនូវការរស់រានមានជីវិត ការលូតលាស់ និងការអភិវឌ្ឍរបស់កុមារនិងកុមារវ័យ ជំទង់។

ព្រះរាជាណាចក្រកម្ពុជាធ្លាប់បានជួបប្រទះ និងទទួលរងមហាវិនាសកម្មដ៏ធ្ងន់ធ្ងរ បង្កឡើងដោយរបប ប្រល័យពូជសាសន៍ប៉ុលពត ដែលបានធ្វើឱ្យប្រជាជន យុវជន កុមារ បាត់បង់សិទ្ធិជាមនុស្ស បង្ខំឱ្យធ្វើការជា ទម្ងន់ រស់នៅយ៉ាងសែនវេទនា ក្លាយជាទាសករ រងនូវទារុណកម្ម និងការកាប់សម្លាប់ដោយអយុត្តិធម៌អស់ រាប់លាននាក់។ ក្រោយថ្ងៃ៧ មករា ១៩៧៩ សិទ្ធិរបស់ប្រជាពលរដ្ឋ និងជាពិសេសសិទ្ធិរបស់កុមារនៅកម្ពុជា ត្រូវបានយកចិត្តទុកដាក់ ដោយថែមទាំងបានចែងច្បាស់ក្នុងរដ្ឋធម្មនុញ្ញ និង កម្មវិធីគោលនយោបាយរបស់ រាជរដ្ឋាភិបាល ស្របទៅតាមអនុសញ្ញាអន្តរជាតិផ្សេងៗដែលពាក់ព័ន្ធកុមារ។ ព្រះរាជាណាចក្រកម្ពុជា បានផ្តល់ សច្ចាប័នលើអនុសញ្ញាស្តីពី សិទ្ធិកុមារ នៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២ ហើយនៅឆ្នាំ២០០២ បានផ្តល់ សច្ចាប័នលើពិធីសារពីរគឺ : មួយ ការចូលរួមរបស់កុមារក្នុងជម្លោះប្រដាប់អាវុធ ពីរ ការជួញដូរកុមារការធ្វើ ពេស្យាកម្មកុមារ និងការផ្សព្វផ្សាយរូបភាពអាសអាភាសរបស់កុមារ។ នៅដើមឆ្នាំ២០០៥ ព្រះរាជាណាចក្រ កម្ពុជា បាន និង កំពុងដំណើរការផ្តល់សច្ចាប័នអនុសញ្ញាលេខ១៨២ ស្តីពីការហាមប្រាម និងសកម្មភាពបន្ទាន់ សម្រាប់ការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ។

ក្នុងគោលដៅដើម្បីអនុវត្តឱ្យបានរឹតតែល្អថែមទៀតនូវ សិទ្ធិកុមាររាជរដ្ឋាភិបាលណែនាំចាត់តាំងទិវា កុមារអន្តរជាតិ ១ មិថុនា និង ទិវាពិភពលោកប្រឆាំងនឹងពលកម្ម កុមារ ១២ មិថុនា ឆ្នាំ ២០០៥ ដូចខាង ក្រោម :

១- គ្រប់ក្រសួង ស្ថាប័ន ខេត្ត ក្រុង និង អាជ្ញាធរមានសមត្ថកិច្ចគ្រប់ថ្នាក់ ត្រូវធ្វើកិច្ចសហការគ្នា ជាមួយអង្គការជាតិ អន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល ផ្នែកឯកជន និង ប្រជាពលរដ្ឋដើម្បីឧបត្ថម្ភគាំទ្រ និង ផ្សព្វផ្សាយជូនដល់អង្គភាពក្រោមឱវាទ និងសង្គមជាតិទាំងមូលឱ្យបានជ្រួតជ្រាបអំពីប្រវត្តិនៃទិវាកុមារអន្តរ ជាតិ ១ មិថុនា និង ទិវាពិភពលោកប្រឆាំងនឹងពលកម្មកុមារ ១២ មិថុនា ។

២- ត្រូវរៀបចំពិធីមិទ្ទិញ ឬពិធីជួបជុំសំណេះសំណាលជាមួយកុមារ និង មានកម្មវិធីចាត់តាំងកំសាន្ត សប្បាយរបស់កុមារនៅក្នុងមូលដ្ឋានរបស់ខ្លួន តាមលទ្ធភាពជាក់ស្តែង។

៣- ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងព័ត៌មាន ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ សាលាក្រុងភ្នំពេញ និងស្ថាប័នពាក់ព័ន្ធ ត្រូវសហការរៀបចំមិទ្ទិញ និង មានកម្មវិធីកំសាន្តផ្សេងៗសម្រាប់កុមារអោយបានឱឡារិក អធិកអធម ។

ទទួលបានសារាចរណែនាំនេះ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និង អាជ្ញាធរដែនដីគ្រប់ខេត្ត ក្រុង ត្រូវរៀបចំចាត់តាំងអនុវត្តឱ្យបានប្រកបដោយស្មារតីទទួលខុសត្រូវ និងមានប្រសិទ្ធភាពខ្ពស់ ។

*រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០០៥*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- គ្រប់ក្រសួង - ស្ថាប័ន
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ៧៤២ សហវ.ប្រក

# ប្រកាស

## ស្តីពី

## ការកែសំរួលខ្លឹមសារប្រកាសលេខ ៩៦៨ សហវ.ប្រក

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់រដ្ឋធម្មនុញ្ញបន្ថែមសំដៅធានាន្ទដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីអំពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ១៩៩៣ដែលប្រកាសឱ្យប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ហើយត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ១០/នស/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និងត្រូវបានកែប្រែដោយច្បាប់ ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រាទី២៦នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស/រកម ១២០២/០២០ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ៤៦៨ សហវ.ប្រក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការគ្រប់គ្រងអាជីវកម្មឆ្នោត-ឡូតូ
- បានឃើញលទ្ធផលប្រជុំពិភាក្សាថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០០៥
- ផ្អែកតាមការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សំរេច

**ប្រការ១:** ត្រូវបានកែសំរួលនូវខ្លឹមសារក្នុងប្រកាសលេខ ៤៦៨ សហវ.ប្រក ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការគ្រប់គ្រងអាជីវកម្មឆ្នោត-ឡូតូ ត្រង់ប្រការ ៥ ស្តីពីរបបពន្ធ និងហិរញ្ញវត្ថុដូចខាងក្រោម :

**-ចំណុច១** ក្រុមហ៊ុនឆ្នោត-ឡូតូត្រូវតំកល់ប្រាក់កិតសាធនភាពរបស់ខ្លួននៅរតនាគារជាតិដើម្បីប្រើប្រាស់បើកប្រាក់រង្វាន់ក្នុងករណី ដែលក្រុមហ៊ុនមានបញ្ហាហិរញ្ញវត្ថុ មិនអាចដោះស្រាយបាន ឬ ក្រុមហ៊ុនក្ស័យធន ។ សាច់ប្រាក់កិតសាធនភាពនេះ

គឺស្មើនឹង ៥០% នៃផលរបរដុល ដោយត្រូវបានកំណត់អប្បបរមាចំនួន ២០០.០០០.០០០ រៀល (ពីររយលានរៀល) ទឹកប្រាក់តំកល់នេះអាចដកវិញបាន នៅពេលដែលក្រុមហ៊ុនឆ្នោត-ឡូតូ ឈប់ធ្វើអាជីវកម្ម។

កែជា: ក្រុមហ៊ុនឆ្នោត-ឡូតូ ត្រូវតំកល់ប្រាក់កិរិតសាធនភាពរបស់ខ្លួននៅរតនាគារជាតិ ដើម្បីប្រើប្រាស់បើកប្រាក់រង្វាន់ ក្នុងករណីដែលក្រុមហ៊ុនមានបញ្ហាហិរញ្ញវត្ថុមិនអាចដោះស្រាយបាន ឬក្រុមហ៊ុនក្ស័យធន។ សាច់ប្រាក់កិរិតសាធនភាពនេះ គឺស្មើនឹង ៥០%នៃផលរបរដុល ដោយត្រូវបានកំណត់អប្បបរមាចំនួន ៨០.០០០.០០០ រៀល (ប៉ែតសិបលានរៀល)។ ទឹកប្រាក់តំកល់នេះ អាចដកវិញបាន នៅពេលដែលក្រុមហ៊ុនឆ្នោត-ឡូតូ ឈប់ធ្វើអាជីវកម្ម។

**-ចំណុច៦** ក្រុមហ៊ុនឆ្នោត-ឡូតូត្រូវបង់ថ្លៃអាជ្ញាប័ណ្ណប្រកបអាជីវកម្មឆ្នោត-ឡូតូ សំរាប់រយ:ពេល ០៣ ឆ្នាំ ចំនួន ១២០.០០០.០០០ រៀល (មួយរយម្ភៃលានរៀល)។

កែជា: ក្រុមហ៊ុនឆ្នោត-ឡូតូត្រូវបង់ថ្លៃអាជ្ញាប័ណ្ណប្រកបអាជីវកម្មឆ្នោត-ឡូតូសំរាប់រយ:ពេល០៣ ឆ្នាំចំនួន ៩០.០០០.០០០ រៀល (កៅសិបលានរៀល)តែក្រុមហ៊ុនត្រូវបង់ ០១ ឆ្នាំម្តងចំនួន ៣០.០០០.០០០រៀល (សាមសិបលានរៀល)។

**-ចំណុច៩** ក្រុមហ៊ុនឆ្នោត-ឡូតូ ត្រូវបង់ចំណូលទៅរតនាគារជាតិឱ្យបានមុនថ្ងៃទី ១០ នៃខែបន្ទាប់នូវកាតព្វកិច្ចដែលបានមកពីការធ្វើអាជីវកម្មតាមករណីដូចខាងក្រោម:

-សំរាប់អាជីវកម្មឆ្នោត-ឡូតូ ១ ប្រភេទ (មួយ)

- -ចេញ ១ លើក/ថ្ងៃ ត្រូវបង់គិតជាអប្បបរមា ៤០.០០០.០០០ រៀល/ខែ (សែសិបលានរៀល)
- -ចេញ ២ លើក/ថ្ងៃ ត្រូវបង់គិតជាអប្បបរមា ៦០.០០០.០០០ រៀល/ខែ (ហុកសិបលានរៀល)
- -ចេញ ៣ លើក/ថ្ងៃ ត្រូវបង់គិតជាអប្បបរមា ១០០.០០០.០០០ រៀល/ខែ (មួយរយលានរៀល)

កែជា: ក្រុមហ៊ុនឆ្នោត-ឡូតូ ត្រូវបង់ចំណូលទៅរតនាគារជាតិ ឱ្យបានមុនថ្ងៃទី ១០ នៃខែបន្ទាប់ នូវកាតព្វកិច្ចដែលបានមកពីការធ្វើអាជីវកម្ម តាមករណីដូចខាងក្រោម:

-សំរាប់អាជីវកម្មឆ្នោត-ឡូតូ ១ ប្រភេទ (មួយ) ក្រុមហ៊ុនត្រូវបង់ចំណូលជារបៀបម៉ៅការដោយអនុគ្រោះអោយរួចផុតពីកាតព្វកិច្ចពន្ធដារដូចខាងក្រោម

- -ចេញ ១ លើក/ថ្ងៃ ត្រូវបង់គិតជាអប្បបរមា ២០.០០០.០០០ រៀល/ខែ (ម្ភៃលានរៀល)
- -ចេញ ២ លើក/ថ្ងៃ ត្រូវបង់គិតជាអប្បបរមា ៤០.០០០.០០០ រៀល/ខែ (សែសិបលានរៀល)
- -ចេញ ៣ លើក/ថ្ងៃ ត្រូវបង់គិតជាអប្បបរមា ៦០.០០០.០០០ រៀល/ខែ (ហុកសិបលានរៀល)

**ប្រការ ២ :** ចំពោះប្រភេទឆ្នោតគោស ត្រូវបង់គិតជាអប្បបរមាចំនួន ១០.០០០.០០០ រៀល/ខែ (ដប់លានរៀល)។

**ប្រការ ៣ :** រាល់លិខិតបទដ្ឋានទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីសេចក្តីប្រកាសនេះ ត្រូវចាត់ទុកជានិរាកណ៍។

**ប្រការ ៤ :** អគ្គលេខាធិការ នាយខុទ្ទកាល័យ ប្រធាននាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានពន្ធដារ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុក ប្រធានរតនាគារជាតិ ប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមហ៊ុនឆ្នោត-ឡូតូ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធិភាពខ្ពស់តាមភារកិច្ចរៀង១ខ្លួន។

ប្រកាសនេះមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែឧសភា ឆ្នាំ ២០០៥

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**ចម្លងជូន**

- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ទីស្តីការគណ:រដ្ឋមន្ត្រី
- -ក្រសួងមហាផ្ទៃ "ដើម្បីជូនជ្រាប"
- -ដូចប្រការ ៤ "ដើម្បីអនុវត្ត"
- -ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE
ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៧៤៣ សហវ.ប្រក

# ប្រកាស
# ស្តីពី
# ការគ្រប់គ្រងអាជីវកម្មល្បែងកំសាន្តស្លតម៉ាស៊ីន ល្បែងអេឡិចត្រូនិច និងមេកានិចគ្រប់ប្រភេទ

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១ន.ស. ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ហើយមានការកែប្រែក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ដែលត្រូវបានប្រកាសអោយប្រើដោយព្រះរាជក្រមលេខ១១នស/៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤ និងមានការកែប្រែក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់គ្រប់គ្រងឆ្នាំ២០០០ ដែលត្រូវបានប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៩៩

- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០០០
- បានឃើញអនុក្រឹត្យលេខ ០៤អនក្រ/បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងប្រព្រឹត្តិទៅ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញសេចក្តីណែនាំលេខ ០១ សណន ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០០៥ របស់រាជរដ្ឋាភិបាល
- យោងចំណាររបស់សម្តេចនាយករដ្ឋមន្ត្រី ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៥

## សម្រេច

**ប្រការ ១ :** ផ្តល់អាជ្ញាប័ណ្ណអាជីវកម្មល្បែងកំសាន្តស្លុតម៉ាស៊ីន ល្បែងអេឡិចត្រូនិច និងមេកានិចគ្រប់ប្រភេទ ដល់ក្រុមហ៊ុនដែលទទួលបានការអនុញ្ញាតជាគោលការណ៍ពីរាជរដ្ឋាភិបាល។

**ប្រការ ២ :** កម្មវត្ថុ នៃប្រកាសនេះ គឺបង្កើតឡើង ដើម្បីអោយមានប្រព័ន្ធមួយក្នុងការចេញអាជ្ញាប័ណ្ណ ការគ្រប់គ្រង និងការត្រួតពិនិត្យអាជីវកម្មល្បែងកំសាន្តស្លុតម៉ាស៊ីន ល្បែងអេឡិចត្រូនិច និងមេកានិចគ្រប់ប្រភេទ សំដៅអនុវត្តអោយមានប្រសិទ្ធភាពខ្ពស់ក្នុងការគ្រប់គ្រង និងធានាអោយបាននូវការបង្កើនប្រាក់ចំណូលក្នុងថវិកាជាតិ។

**ប្រការ ៣ :** ក្រុមហ៊ុនទាំងអស់ដែលទទួលបានការអនុញ្ញាតធ្វើអាជីវកម្មល្បែងកំសាន្តស្លុតម៉ាស៊ីន ល្បែងអេឡិចត្រូនិច និងមេកានិចគ្រប់ប្រភេទពីរាជរដ្ឋាភិបាល ត្រូវរួសរាន់មកដាក់ពាក្យ និងបំពេញបែបបទស្នើសុំអាជ្ញាប័ណ្ណពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ ៤ :** ពាក្យសុំអាជ្ញាប័ណ្ណ និងឯកសារពាក់ព័ន្ធផ្សេងៗ ត្រូវស្នើឡើងដោយអ្នកចាត់ការទូទៅ ឬបុគ្គលដែលបានទទួលសិទ្ធិជាលាយល័ក្ខអក្សររបស់ក្រុមហ៊ុន។ ចំពោះឯកសារពាក់ព័ន្ធនឹងការស្នើសុំអាជ្ញាប័ណ្ណនេះ មានកំណត់នៅក្នុងសលាកប័ត្រ-ពត៌មានចុះបញ្ជីអាជីវកម្មល្បែងកំសាន្តស្លុតម៉ាស៊ីន ល្បែងអេឡិចត្រូនិច និងមេកានិចគ្រប់ប្រភេទ។

**ប្រការ ៥ :** ការផ្តល់អាជ្ញាប័ណ្ណគឺជាការផ្តល់ទិដ្ឋាការប្រកបអាជីវកម្មល្បែងកំសាន្តស្លុតម៉ាស៊ីន ល្បែងអេឡិចត្រូនិច និង មេកានិចគ្រប់ប្រភេទ។ ក្រុមហ៊ុនទាំងអស់ដែលបានទទួលអាជ្ញាប័ណ្ណពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញ-វត្ថុ ទើបមានសិទ្ធិតាមផ្លូវច្បាប់ក្នុងការប្រកបអាជីវកម្មរបស់ខ្លួន។ ការចាត់ចែងការលេងល្បែងកំសាន្ត

តាមស្លុតម៉ាស៊ីន ល្បែងអេឡិចត្រូនិច និងមេកានិចគ្រប់ប្រភេទ ដែលគ្មានអាជ្ញាប័ណ្ណត្រូវហាមឃាត់ និងត្រូវទទួលទោសតាមច្បាប់ជាធរមាន។

**ប្រការ ៦ :** អាជ្ញាប័ណ្ណសំរាប់អាជីវកម្មល្បែងកំសាន្តស្លុតម៉ាស៊ីន ល្បែងអេឡិចត្រូនិច និងមេកានិចគ្រប់ប្រភេទត្រូវបានផ្តល់អោយនៅពេលដែលបុគ្គលស្នើសុំអាជ្ញាប័ណ្ណបំពេញ នូវរាល់ល័ក្ខខ័ណ្ឌដូចខាងក្រោម :

ក- អ្នកស្នើសុំជាម្ចាស់ក្រុមហ៊ុន

ខ- ពាក្យស្នើសុំអាជ្ញាប័ណ្ណត្រូវធ្វើជាលាយល័ក្ខអក្សរ មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយមានភ្ជាប់មកជាមួយនូវសេចក្តីសំរេចជាគោលការណ៍អោយធ្វើអាជីវកម្មរបស់រាជរដ្ឋាភិបាល។

គ- ល័ក្ខខ័ណ្ឌដូចមានចែងក្នុងសៀវភៅបន្ទុក និងសេចក្តីណែនាំផ្សេងទៀតរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពាក់ព័ន្ធនឹងល័ក្ខខ័ណ្ឌអាជ្ញាប័ណ្ណ អាជីវកម្មល្បែងកំសាន្តស្លុតម៉ាស៊ីន ល្បែងអេឡិចត្រូ-និច និង មេកានិចគ្រប់ប្រភេទ។

**ប្រការ ៧ :** អ្នកកាន់កាប់អាជ្ញាប័ណ្ណមិនត្រូវបង្កើតសាខាបន្ថែម ឬធ្វើអាជីវកម្មខុសពីទីតាំងដែលបានកំណត់ក្នុងប្រការ ១ (ក) នៃសៀវភៅបន្ទុកស្តីពីល័ក្ខខ័ណ្ឌអនុវត្តអាជ្ញាប័ណ្ណអាជីវកម្មល្បែងកំសាន្តស្លុតម៉ាស៊ីន ល្បែងអេឡិចត្រូនិច និងមេកានិចគ្រប់ប្រភេទ ដោយគ្មានការអនុញ្ញាតជាមុនពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ ៨ :** អ្នកកាន់កាប់អាជ្ញាប័ណ្ណ ត្រូវគោរពតាមល័ក្ខខ័ណ្ឌនៃអាជ្ញាប័ណ្ណ ព្រមទាំងបទបញ្ញត្តិផ្សេងទៀតដែលមានជាធរមានស្រាប់ រួមទាំងសេចក្តីជូនដំណឹង សារាចរណែនាំ ប្រកាស ដែលនឹងចេញដោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុជាបន្តបន្ទាប់ទៅតាមស្ថានភាពជាក់ស្តែង។

**ប្រការ ៩ :** អាជ្ញាប័ណ្ណមានសុពលភាព០១ឆ្នាំ (មួយឆ្នាំ) គិតចាប់ពីថ្ងៃចុះហត្ថលេខា លើអាជ្ញាប័ណ្ណតទៅ។ អាជ្ញា-ប័ណ្ណ នឹងត្រូវបានបន្តសុពលភាពសំរាប់ឆ្នាំបន្តបន្ទាប់ អាស្រ័យលើប្រសិទ្ធភាព នៃការអនុវត្តន៍ និងការបំពេញកាតព្វកិច្ចដូចមានចែងក្នុងប្រការ ១៦ នៃប្រកាសនេះ និងការណែនាំព្រមទាំងបទប្បញ្ញត្តិផ្សេងៗទៀតរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងបទបញ្ញត្តិនានាដែលមានជាធរមាន ហើយអ្នកកាន់អាជ្ញាប័ណ្ណត្រូវដាក់ពាក្យសុំការអនុញ្ញាតពីក្រសួង មិនអោយលើសពីរយៈពេល៣០ថ្ងៃ (សាមសិបថ្ងៃ) មុនពេលផុតសុពល ភាពនៃអាជ្ញាប័ណ្ណដែលកំពុងប្រើប្រាស់។

**ប្រការ ១០ :** អ្នកកាន់កាប់អាជ្ញាប័ណ្ណអាចផ្ទេរ ឬ លក់សិទ្ធិកាន់កាប់អាជ្ញាប័ណ្ណទៅអោយបុគ្គល ឬភាគីណាមួយផ្សេងទៀតបាន លុះត្រាតែមានការឯកភាពជាលាយល័ក្ខអក្សរជាមុនពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងត្រូវបង់ប្រាក់ ចំនួន ៨០.០០០.០០០ រៀល (ប៉ែតសិបលានរៀល) ចូលក្នុងថវិកាជាតិ។ ក្នុងករណីផ្អាក ឬ បញ្ឈប់សកម្មភាពអាជីវកម្ម អ្នកទទួលអាជ្ញាប័ណ្ណត្រូវដាក់សំណើជាលាយល័ក្ខអក្សរ ដោយភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធ ព្រមទាំងបញ្ជាក់មូលហេតុត្រឹមត្រូវក្នុងរយៈពេល៣០ថ្ងៃមុន (សាមសិបថ្ងៃ) ដើម្បីសុំសេចក្ដីសំរេចពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ ១១ :** ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានសិទ្ធិដកហូតអាជ្ញាប័ណ្ណយកមកវិញ ក្នុងករណីអ្នកកាន់កាប់អាជ្ញាប័ណ្ណមិនបានបំពេញនូវល័ក្ខខ័ណ្ឌ និងកាតព្វកិច្ច ដូចខាងក្រោម :

ក- អ្នកកាន់កាប់អាជ្ញាប័ណ្ណ មិនបានធ្វើសកម្មភាពអាជីវកម្មរបស់ខ្លួនក្នុងរយៈពេល៩០ថ្ងៃ (កៅសិបថ្ងៃ) ដំបូង បន្ទាប់ពីបានទទួលអាជ្ញាប័ណ្ណ ។

ខ- អ្នកកាន់កាប់អាជ្ញាប័ណ្ណផ្អាកសកម្មភាពអាជីវកម្មរបស់ខ្លួនលើសពី ៩០ថ្ងៃ (កៅសិបថ្ងៃ) ដោយពុំមានការអនុញ្ញាតពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

គ- អ្នកកាន់កាប់អាជ្ញាប័ណ្ណ មិនបានផ្ដល់បញ្ជីវិភាគគណនី និងឯកសារផ្សេងៗពាក់ព័ន្ធនឹងសកម្មភាពអាជីវកម្មរបស់ខ្លួន តាមតំរូវការរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដូចចែងក្នុងចំណុច (ក) ប្រការ២០ នៃប្រកាសនេះ។

ឃ- អ្នកកាន់កាប់អាជ្ញាប័ណ្ណមិនបានបំពេញតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងប្រការ១៦ នៃប្រកាសនេះ។

ង- អ្នកកាន់កាប់អាជ្ញាប័ណ្ណ មានបញ្ហាក្នុងការទូទាត់រង្វាន់ជ័យលាភីញឹកញាប់ ឬក្ស័យធន។

ច- អ្នកកាន់កាប់អាជ្ញាប័ណ្ណ មិនសហការល្អជាមួយមន្ត្រីត្រួតពិនិត្យរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងពេលបំពេញការងារជាផ្លូវការ។

ឆ- អ្នកកាន់កាប់អាជ្ញាប័ណ្ណ មិនបានអនុវត្តទៅតាមការណែនាំជាលាយល័ក្ខអក្សររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ជ- អ្នកកាន់កាប់អាជ្ញាប័ណ្ណ បានប្រព្រឹត្តិសកម្មភាពផ្សេងៗទៀតដែលផ្ទុយនឹងច្បាប់រដ្ឋ។

**ប្រការ ១២ :** ក្រោយពីទទួលបាននូវអាជ្ញាប័ណ្ណរួចហើយ ក្រុមហ៊ុនត្រូវស្នើសុំមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងការនាំចូលឧបករណ៍ល្បែងស្លុតម៉ាស៊ីន ល្បែងអេឡិចត្រូនិច និងមេកានិចគ្រប់ប្រភេទ សំរាប់ធ្វើអាជីវកម្ម ដោយភ្ជាប់ មកជាមួយនូវនីតិវិធី និងបច្ចេកទេសនៃការលេងល្បែងគ្រប់ប្រភេទ ព្រមទាំងបែបបទនៃការទូទាត់រង្វាន់ជ័យលាភី។ ឧបករណ៍លេងល្បែង ដែលអាចធ្វើអាជីវកម្មបានលុះត្រាតែមានការត្រួត

ពិនិត្យកិរិតបច្ចេកទេស និងមានបិទប័ណ្ណបញ្ជាក់ (Sticker) ថាត្រឹមត្រូវ ព្រមទាំងមានការអនុញ្ញាត ជាលាយល័ក្ខអក្សរ ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ ១៣** : ឧបករណ៍ល្បែងស្លុតម៉ាស៊ីន ល្បែងស៊ីសងអេឡិចត្រូនិច និងមេកានិចគ្រប់ប្រភេទត្រូវបានអនុញ្ញាតឱ្យធ្វើអាជីវកម្មសំរាប់តែភ្ញៀវជាជនបរទេសតែប៉ុណ្ណោះ។

**ប្រការ ១៤** : ការរៀបចំឧបករណ៍ល្បែងកំសាន្តស្លុតម៉ាស៊ីន ល្បែងអេឡិចត្រូនិច និង មេកានិចគ្រប់ប្រភេទ សំរាប់ធ្វើអាជីវកម្ម ត្រូវដាក់ក្នុងទីតាំងដែល មិនបើកចំហរជាសាធារណៈ ដូចជានៅជិតសាលារៀន និងមិនប៉ះ-ពាល់ដល់មន្ទីរពេទ្យ ឬទីវត្តអារ៉ាមជាដើម។

**ប្រការ ១៥** : ក្រុមហ៊ុនទាំងអស់ ត្រូវរៀបចំបំពាក់កាមេរ៉ាសំងាត់ (Camera Surveillance / CCTV ) ជាប្រព័ន្ធត្រួតពិនិត្យនៅគ្រប់ទីតាំងលេងល្បែងកំសាន្ត និងគ្រប់កន្លែងចាំបាច់ផ្សេងទៀត ដោយមានការត្រួតពិនិត្យ និង បញ្ជាក់ពីភាពត្រឹមត្រូវអាចធានាសុវត្ថិភាពបានពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ ១៦** : ថ្លៃអាជ្ញាប័ណ្ណ និងការបង់ចំណូលកាតព្វកិច្ច :

ក- អ្នកទទួលអាជ្ញាប័ណ្ណត្រូវបង់ថ្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំចំនួន ៨០,០០០,០០០ រៀល (ប៉ែតសិបលានរៀល)។

ខ- អ្នកទទួលអាជ្ញាប័ណ្ណ ត្រូវបង់ចំណូលកាតព្វកិច្ចប្រចាំខែទៅតាមចំនួនស្លុតម៉ាស៊ីន ល្បែងអេឡិចត្រូនិច និងមេកានិច និងទំហំទីតាំង ដែលកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុយ៉ាងយូរត្រឹមថ្ងៃទី ០៧ នៃខែ បន្ទាប់។

គ- អ្នកទទួលអាជ្ញាប័ណ្ណ ត្រូវបង់ចំណូលដូចបានចែងក្នុងចំណុច (ក)និង(ខ)ខាងលើ ចូលក្នុងគណនីថវិកាជាតិលេខ**02-35-1211-T023** នៅធនាគារជាតិនៃកម្ពុជា ។

**ប្រការ ១៧** : អ្នកទទួលអាជ្ញាប័ណ្ណ ត្រូវតំកល់សាច់ប្រាក់ សំរាប់ធានាដល់ការទូទាត់រង្វាន់ជ័យលាភី ដល់អតិថិជន ដោយត្រូវដាក់តំកល់ប្រាក់ចំនួន ១,០០០,០០០រៀល (មួយលានរៀល) ក្នុងឧបករណ៍ល្បែងស្លុតម៉ាស៊ីន ល្បែង អេឡិចត្រូនិច ឬមេកានិច ០១គ្រឿង (មួយគ្រឿង)។ ប្រាក់តំកល់នេះ ត្រូវដាក់នៅធនាគារជាតិនៃកម្ពុជា និងមិនអាចដកហូតវិញបានឡើយ លុះត្រាតែអ្នកកាន់កាប់អាជ្ញាប័ណ្ណពុំមានលទ្ធភាពទូទាត់

រង្វាន់ធំ ឬក្ស័យធន ឬបញ្ឈប់សកម្មភាព អាជីវកម្មជាស្ថាពរ ដោយមានលិខិតជាផ្លូវការរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ ១៨ :** អ្នកទទួលអាជ្ញាប័ណ្ណ ត្រូវរក្សាទុកអោយបានត្រឹមត្រូវនូវឯកសារផ្សេងៗ ដែលពាក់ព័ន្ធទៅនឹងការធ្វើអាជីវកម្ម ហើយត្រូវផ្តល់របាយការណ៍លំអិតប្រចាំត្រីមាស ដោយបញ្ជាក់ពីប្រាក់ចំណូលដុល ប្រាក់រង្វាន់ដែលបាន បើកផ្តល់ចំពោះអតិថិជនឈ្នះរង្វាន់ ព្រមទាំងភ្ជាប់ជាមួយនូវឯកសារពាក់ព័ន្ធថតចំលងផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុយ៉ាងយូរ៣០ថ្ងៃ (សាមសិបថ្ងៃ) នៃត្រីមាសបន្ទាប់។ម្យ៉ាងទៀត របាយ-ការណ៍នេះត្រូវបញ្ជាក់ការពិត និងត្រឹមត្រូវដែលចុះហត្ថលេខាដោយនាយកក្រុមហ៊ុន ឬតំណាងមានសិទ្ធិជាលាយល័ក្ខអក្សរ។

**ប្រការ ១៩ :** ក្នុងរយះពេល ៩០ថ្ងៃ (កៅសិបថ្ងៃ) ក្រោយពីបញ្ចប់ឆ្នាំនីមួយៗ អ្នកកាន់កាប់អាជ្ញាប័ណ្ណត្រូវផ្តល់ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នូវបញ្ជីគណនេយ្យនៃឆ្នាំសារពើពន្ធ ដែលបានធ្វើសវនកម្មដោយក្រុមហ៊ុនសវនកម្មឯករាជ្យ ទទួលស្គាល់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**ប្រការ ២០ :** ការត្រួតពិនិត្យរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ :

ក- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានសិទ្ធិចាត់មន្ត្រីជំនាញ ដើម្បីចុះត្រួតពិនិត្យបញ្ជីគណនេយ្យលិខិតស្នាម និង ឯកសារផ្សេងៗ ដែលពាក់ព័ន្ធនឹងការធ្វើអាជីវកម្មគ្រប់ពេលវេលា។ ក្រុមហ៊ុនធ្វើអាជីវកម្មល្បែងកំសាន្តស្លុតម៉ាស៊ីន ល្បែងអេឡិចត្រូនិច និងមេកានិចគ្រប់ប្រភេទត្រូវបង្កលក្ខណៈងាយស្រួល និងសហការល្អជាមួយមន្ត្រីជំនាញរបស់ក្រសួងដើម្បីត្រួតពិនិត្យបញ្ជីស្នាមនិងឯកសារផ្សេងៗរបស់អ្នកកាន់កាប់អាជ្ញាប័ណ្ណ។ ក្នុងករណីចាំបាច់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានសិទ្ធិជួលគណនេយ្យករ ឬអ្នកឯកទេសអោយចូលរួមក្នុងកិច្ចការនេះ និងមានសិទ្ធិថតចំលងរាល់ឯក-សារផ្សេងៗ តាមតំរូវការនៃការត្រួតពិនិត្យ។ រាល់ការចំណាយក្នុងការជួលគណនេយ្យករ ឬអ្នកឯកទេសនេះ ជាបន្ទុករបស់ក្រុមហ៊ុន។

ខ- ក្នុងពេលធ្វើអាជីវកម្ម មន្ត្រីជំនាញក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានសិទ្ធិត្រួតពិនិត្យប្រព័ន្ធត្រួតពិនិត្យកាមេរ៉ាសំងាត់ (Camera surveillance /CCTV) របស់ក្រុមហ៊ុន។

គ- មន្ត្រីជំនាញក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានសិទ្ធិចុះត្រួតពិនិត្យលើទីតាំងដាក់ឧបករណ៍ ល្បែងកំសាន្តស្លុតម៉ាស៊ីន ល្បែងអេឡិចត្រូនិច និងមេកានិចគ្រប់ប្រភេទរបស់ក្រុមហ៊ុន និង មានសិទ្ធិត្រួតពិនិត្យ ផ្សេងៗទៀត ទៅតាមតំរូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ ២១ :** ការផាកពិន័យក្នុងការធ្វើអាជីវកម្ម :

ក- អ្នកកាន់កាប់អាជ្ញាប័ណ្ណមានការធ្វេសប្រហែសបណ្តាលអោយមានការបង់ចំណូលប្រចាំខែខ្វះ ត្រូវរងការផាក ពិន័យចំនួន១០% (ដប់ភាគរយ) នៃចំនួនទឹកប្រាក់ដែលបង់ខ្វះ បូកបន្ថែមការប្រាក់ ២% (ពីរភាគរយ) នៃចំនួនទឹកប្រាក់ដែលបង់ខ្វះសំរាប់ខែនីមួយៗ ។

ខ- អ្នកកាន់កាប់អាជ្ញាប័ណ្ណមានការយឺតយ៉ាវក្នុងការបំពេញកាតព្វកិច្ចបង់ចំណូលជូនរដ្ឋប្រចាំខែ ដូចមានចែងក្នុង ប្រការ ១៦ នៃប្រកាសនេះ នឹងត្រូវរងការផាកពិន័យដូចខាងក្រោម :

ខ-១. យឺតយ៉ាវ ០១ខែ (មួយខែ) ត្រូវរងការផាកពិន័យចំនួន ១០% (ដប់ភាគរយ) បូកការប្រាក់ ២% (ពីរភាគរយ) នៃចំនួនទឹកប្រាក់ដែលបង់យឺតសំរាប់ខែនីមួយៗ ។

ខ-២. យឺតយ៉ាវចាប់ពី ០២ខែ (ពីរខែ) ត្រូវរងការផាកពិន័យ ២៥% បូកនឹងការប្រាក់ ២% (ពីរភាគរយ) នៃចំនួនទឹកប្រាក់ដែលបង់យឺតសំរាប់ខែនីមួយៗ ។

គ- អ្នកកាន់កាប់អាជ្ញាប័ណ្ណ ផ្តល់របាយការណ៍ប្រចាំត្រីមាស ក្រោយកាលកំណត់ ដូចមានចែងក្នុងប្រការ១៨ នៃប្រកាសនេះ នឹងត្រូវរងការផាកពិន័យចំនួន ១.០០០.០០០រៀល (មួយលានរៀល) ក្នុង១ថ្ងៃ និងផ្តល់របាយការណ៍ប្រចាំឆ្នាំ ក្រោយកាលកំណត់ ដូចមានចែងក្នុងប្រការ១៩ នៃប្រកាសនេះនឹងរងការផាកពិន័យចំនួន៥.០០០.០០០រៀល (ប្រាំលានរៀល) ក្នុង១សប្តាហ៍។

ឃ- អ្នកកាន់កាប់អាជ្ញាប័ណ្ណ បន្តធ្វើសកម្មភាពអាជីវកម្ម ដោយប្រើប្រាស់អាជ្ញាប័ណ្ណផុតសុពលភាព ត្រូវរងការ ផាកពិន័យជាប្រាក់ចំនួន ២.០០០.០០០រៀល (ពីរលានរៀល) ក្នុងមួយថ្ងៃ។

ង- ក្នុងករណីអ្នកកាន់កាប់អាជ្ញាប័ណ្ណ ធ្វើអាជីវកម្មប្រភេទល្បែងគ្មានការអនុញ្ញាតពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវរងការផាកពិន័យជាប្រាក់ចំនួន ៤០.០០០.០០០រៀល (សែសិបលាន រៀល) ក្នុងល្បែងមួយប្រភេទ និងត្រូវបញ្ឈប់អាជីវកម្មរបស់ខ្លួនភ្លាម រហូតដល់មានការអនុញ្ញាតពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ក្នុងករណីនៅតែបន្តធ្វើអាជីវកម្ម ដោយគ្មានការអនុញ្ញាតពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងនឹងចាត់វិធានការតាមផ្លូវច្បាប់ ព្រមទាំងប្តឹងទៅតុលាការតាមច្បាប់ជាធរមាន។

ច- ក្នុងករណីល្មើសទៅនឹង ចំណុច (ក) ប្រការ ១០ ត្រូវរងការផាកពិន័យ ជាប្រាក់ ចំនួន ៨០.០០០.០០០រៀល (ប៉ែតសិបលានរៀល) បន្ថែមលើតំលៃផ្ទេរ ឬ លក់សិទ្ធិកាន់កាប់អាជ្ញា-ប័ណ្ណ ហើយត្រូវបំពេញបែបបទតាម នីតិវិធីជាធរមាន។

ឆ- ក្នុងករណីល្មើសទៅនឹង ចំណុច (ខ) ប្រការ ១០ ត្រូវរងការផាកពិន័យ ជាប្រាក់ចំនួន ៥.០០០.០០០រៀល (ប្រាំលានរៀល) ហើយត្រូវបំពេញបែបបទតាមនីតិវិធីជាធរមាន។

ជ- ក្នុងករណីមិនគោរពតាមការណែនាំពាក់ព័ន្ធនឹងប្រការ ១៤ ឬ ប្រការ ១៥ នៃប្រកាសនេះ ត្រូវរងការផាកពិន័យជាប្រាក់ចំនួន ១០.០០០.០០០រៀល (ដប់លានរៀល) និង បញ្ឈប់សកម្មភាព

អាជីវកម្មជាបន្ទាន់។ ក្នុងករណីនៅតែបន្តធ្វើអាជីវកម្ម ដោយគ្មានការអនុញ្ញាតពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងនឹង ដកហូតអាជ្ញាប័ណ្ណជាស្ថាពរ ព្រមទាំងចាត់វិធានការតាមផ្លូវច្បាប់ ព្រមទាំងប្តឹងទៅតុលាការតាមច្បាប់ជា ធរមាន។

**ប្រការ ២២** : ប្រកាស ឬលិខិតបទដ្ឋានទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ២៣** : អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានពន្ធដារ គ្រប់នាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមហ៊ុនទាំងអស់ដែលធ្វើអាជីវកម្មល្បែងកំសាន្តស្លុតម៉ាស៊ីន ល្បែងអេឡិចត្រូនិច និងមេកានិចគ្រប់ប្រភេទ ត្រូវអនុវត្តតាមខ្លឹមសារ នៃប្រកាសនេះអោយមានប្រសិទ្ធភាពខ្ពស់។

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០៥

**គាត ឈន់**

**ចំលងជូន** :

- លេខាធិការដ្ឋានព្រឹទ្ធសភា
- លេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី

  "ដើម្បីជូនជ្រាប"
- ក្រសួងមហាផ្ទៃ
- ក្រសួងទេសចរណ៍
- សាលាខេត្ត-ក្រុងពាក់ព័ន្ធ
- ស្ថាប័នពាក់ព័ន្ធ

  "ដើម្បីសហការ"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ...សហវ.ប្រក

# ប្រកាស

## ស្ដីពី

## ការរៀបចំ និង ការប្រព្រឹត្តទៅនៃនាយកដ្ឋានពន្ធដារ

## ទេសរដ្ឋមន្ត្រី

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យលេខ ០៤ អនក្រ/បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យលេខ ៧៨ អនក្រ/បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៤ ស្ដីពីការបំពេញបន្ថែម និង កែសំរួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញ ការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

**ប្រការ១.-**

នាយកដ្ឋានពន្ធដារមានបេសកកម្ម ដូចតទៅ :

- ប្រមូលចំណូលពន្ធតាមការអនុវត្តន៍ច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីសារពើពន្ធ
- ផ្តល់នូវសេវាដល់អ្នកជាប់ពន្ធរួមមាន ការផ្តល់ព័ត៌មាន អប់រំ ពន្យល់ណែនាំ ដើម្បីឱ្យអ្នកជាប់ពន្ធប្រតិបត្តិត្រឹមត្រូវតាមច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីសារពើពន្ធ
- អនុវត្តកម្មវិធីចាប់បង្ខំដោយការធ្វើសវនកម្ម ការអនុវត្តន៍វិធានការតឹងទារ និងការស៊ើបអង្កេតចំពោះអ្នកជាប់ពន្ធដែលមិនបានប្រតិបត្តិត្រឹមត្រូវតាមច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីសារពើពន្ធ ។

**ប្រការ២.-**

ចក្ខុវិស័យរបស់នាយកដ្ឋានពន្ធដារនាពេលអនាគត គឺធ្វើឱ្យមានការទទួលស្គាល់ និងការគោរពពីសំណាក់អ្នកជាប់ពន្ធចំពោះភាពត្រឹមត្រូវ និងគុណភាពនៃការគ្រប់គ្រង ។ ដើម្បីសំរេចឱ្យបាននូវចក្ខុវិស័យនេះ នាយកដ្ឋានពន្ធដារបានកំណត់គោលដៅដូចខាងក្រោម :

- ធ្វើឱ្យសំរេចនូវការអនុវត្តន៍ច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីសារពើពន្ធ
- បង្កើនចំណូលសារពើពន្ធ សំរាប់ធានាឱ្យការកើនឡើងនៃការចំណាយថវិកាជាតិ
- ផ្តល់សេវា និងការអប់រំ ដល់អ្នកជាប់ពន្ធឱ្យទាន់ពេលវេលា និងអាចទុកចិត្តបានជាមួយនឹងការបន្ថយចំណាយរបស់អ្នកជាប់ពន្ធ ដើម្បីធានាឱ្យការអនុវត្តន៍តាមច្បាប់សារពើពន្ធបានត្រឹមត្រូវ
- អនុវត្តកម្មវិធីចាប់បង្ខំ ប្រកបដោយប្រសិទ្ធភាព មានការទទួលខុសត្រូវខ្ពស់ និងស្មើភាពគ្នា
- អនុវត្តគោលការណ៍យុត្តិធម៌ក្នុងកម្មវិធីរបស់នាយកដ្ឋានពន្ធដារ ដើម្បីបង្កើនការជឿទុកចិត្ត និងធានាការអនុវត្តន៍តាមច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីសារពើពន្ធ
- បន្ថយការចំណាយរបស់នាយកដ្ឋានពន្ធដារ និងធ្វើឱ្យមានភាពសាមញ្ញចំពោះតម្រូវការផ្សេងៗ ចំពោះអ្នកជាប់ពន្ធក៏ដូចជាក្នុងការរៀបចំកម្មវិធី និងកិច្ចដំណើរការរបស់ខ្លួន
- បង្កើនសមត្ថភាព ចំណេះដឹងដល់មន្ត្រីពន្ធដារជាប្រចាំ ដើម្បីធ្វើកិច្ចការឱ្យមានប្រសិទ្ធភាព
- បង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រង តាមរយៈគោលនយោបាយ កិច្ចដំណើការការងារ និងប្រព័ន្ធការងារដែលមានភាពច្បាស់លាស់ ទំនើប និងមានការទទួលខុសត្រូវខ្ពស់ចំពោះការងាររបស់ខ្លួន ។

**ប្រការ៣.-**

នាយកដ្ឋានពន្ធដារមានតួនាទី និងភារកិច្ច ដូចមានចែងនៅក្នុងមាត្រា ៨ នៃអនុក្រឹត្យលេខ ០៤ អនក្រ/បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ដែលមានខ្លឹមសារជាអាទិ៍ដូចតទៅ :

- លើកគោលនយោបាយសារពើពន្ធ និងការប្រមូលពន្ធគ្រប់ប្រភេទបង់ចូលថវិកាជាតិ
- រៀបចំគោលនយោបាយ សេចក្តីព្រាងច្បាប់ លិខិតបទដ្ឋានសារពើពន្ធ កំណត់បញ្ជីឯកសារចាំបាច់នានា និងលិខិតយុត្តិការដែលអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកត្រូវកាន់កាប់រក្សាទុក និងផ្តល់ជូនរដ្ឋបាលសារពើពន្ធ
- កំណត់មូលដ្ឋានគិតពន្ធលើអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកដោយផ្អែកលើការអង្កេត និងផ្តុំព័ត៌មាន
- គណនា និងប្រមូលប្រាក់ពន្ធ ប្រាក់ពន្ធបន្ថែម ពន្ធប្រថាប់ត្រា ការប្រាក់ និងចំណូលផ្សេងៗ

- កសាងកម្មវិធី និងអនុវត្តការងារត្រួតពិនិត្យសារពើពន្ធលើលិខិតស្នាម និងពិនិត្យបញ្ជីគណនេយ្យសហគ្រាស
- ទទួលបន្ទុកសហប្រតិបត្តិការជាតិ និងអន្តរជាតិក្នុងផ្នែកពន្ធដារ
- អនុវត្តវិធានការពិន័យតាមច្បាប់ ចំពោះអ្នកជាប់ពន្ធ និងភ្នាក់ងារកាត់ទុក
- ចូលរួមរៀបចំគំរោងថវិកាជាតិប្រចាំឆ្នាំ ដើម្បីបញ្ចូលទៅក្នុងសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំនីមួយៗ ។

**ប្រការ៤.-**

នាយកដ្ឋានពន្ធដារមានប្រព័ន្ធចាត់តាំង គ្រប់គ្រងឯកភាពទូទាំងប្រទេស ទទួលខុសត្រូវគ្រប់គ្រង និងត្រួតពិនិត្យការអនុវត្តន៍បទប្បញ្ញត្តិស្តីពីពន្ធដារ តាមការកំណត់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**ប្រការ៥.-**

នាយកដ្ឋានពន្ធដារ ដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការ ។

**ប្រការ៦.-**

នាយកដ្ឋានពន្ធដារមានរចនាសម្ព័ន្ធ ចែកចេញជាពីរថ្នាក់គឺ ថ្នាក់កណ្តាល និងថ្នាក់ប្រតិបត្តិ :

### ក-ថ្នាក់កណ្តាល :

១- ការិយាល័យបុគ្គលិក និងបណ្តុះបណ្តាល
២- ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ
៣- ការិយាល័យគោលនយោបាយ និងនីតិកម្មសារពើពន្ធ
៤- ការិយាល័យសេវាអ្នកជាប់ពន្ធ
៥- ការិយាល័យគណនេយ្យ ស្ថិតិ និងផែនការ
៦- ការិយាល័យគ្រប់គ្រងកម្មវិធីសវនកម្ម
៧- ការិយាល័យប្រមូលបំណុលសារពើពន្ធ
៨- ការិយាល័យវិវាទ
៩- ការិយាល័យព័ត៌មានវិទ្យា

### ខ-ថ្នាក់ប្រតិបត្តិ :

១- ការិយាល័យគ្រប់គ្រងអ្នកជាប់ពន្ធធំ និងមធ្យម
២- ការិយាល័យអង្កេត និងផ្តុំព័ត៌មាន
៣- ការិយាល័យសវនកម្មសារពើពន្ធសហគ្រាស
៤- សាខាពន្ធដារខេត្ត-ក្រុង

**ប្រការ៧.-**

ការិយាល័យ និងសាខាពន្ធដារខេត្ត-ក្រុង នីមួយៗ ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការ និងមានតួនាទី និងភារកិច្ច ដូចខាងក្រោម :

## ក-ថ្នាក់កណ្ដាល

### ក.១-ការិយាល័យបុគ្គលិក និងបណ្ដុះបណ្ដាល

ការិយាល័យនេះមានតួនាទី និងភារកិច្ច ដូចខាងក្រោម :

**១-ផ្នែកបៀវត្ស និងសំណុំឯកសារមន្ត្រីពន្ធដារ**

- រៀបចំ និងអនុវត្តគោលនយោបាយ និងនីតិវិធីតាមស្តង់ដារដើម្បីថែរក្សាសំណុំឯកសារមន្ត្រីពន្ធដារ និងតាមដានការងាររបស់មន្ត្រីទាំងនោះ
- រៀបចំប្រាក់បៀវត្ស និងក្របខណ្ឌប្រាក់កំរៃ និងរបបឧបត្ថម្ភបន្ទុកគ្រួសារ គោលនយោបាយធានារ៉ាប់រងសង្គម របបសំរាកលំហែ និងធ្វើការតម្លើងកាំប្រាក់បៀវត្សប្រចាំឆ្នាំ ជូនមន្ត្រីពន្ធដារ
- គ្រប់គ្រងស្ថិតិ និងឥណទានបៀវត្សមន្ត្រីប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ
- តាមដានអតីតភាពការងារ ការសុំផ្អាកការងារមួយរយៈដោយគ្មានប្រាក់បៀវត្ស ។

**២-ផ្នែកជ្រើសរើស និង ចាត់ចែងបុគ្គលិក**

- រៀបចំគោលនយោបាយ និងនីតិវិធីជ្រើសរើស និងចាត់ចែងមន្ត្រីពន្ធដារ
- ធ្វើផែនការក្របខណ្ឌ ជ្រើសរើស និងចាត់ចែងមន្ត្រីពន្ធដារប្រចាំឆ្នាំ
- ធ្វើការស៊ើបអង្កេត សរសើរ ដាក់ពិន័យ និងគាំពារមន្ត្រីពន្ធដារ
- រៀបចំសំណើទៅថ្នាក់ដឹកនាំនាយកដ្ឋាន ដើម្បីដាក់ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពិនិត្យ និងសំរេច ស្តីពីការតែងតាំង ផ្លាស់ប្តូរ លុបឈ្មោះចេញពីក្របខណ្ឌ សុំឈប់ពីការងារ និងដាក់ឱ្យចូលនិវត្តន៍របស់មន្ត្រីពន្ធដារ
- ធ្វើបញ្ជីរាយនាមមន្ត្រីពន្ធដារក្នុងក្របខណ្ឌ តាមឋានៈ និងតួនាទី ។

**៣-ផ្នែកបណ្ដុះបណ្ដាលមន្ត្រីពន្ធដារ**

- រៀបចំគោលនយោបាយ និងនីតិវិធីបណ្ដុះបណ្ដាលមន្ត្រីពន្ធដារ
- រៀបចំផែនការ និងផ្តល់ការបណ្ដុះបណ្ដាលប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ដោយយោងតាមប្រវត្តិនៃការបណ្ដុះបណ្ដាលកន្លងមក និងតំរូវការរបស់ថ្នាក់កណ្ដាល និងថ្នាក់ប្រតិបត្តិ ព្រមទាំងចេញនូវវិញ្ញាបនប័ត្របញ្ជាក់ការសិក្សា ។

### ក.២-ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ

ការិយាល័យនេះមានតួនាទី និងភារកិច្ច ដូចខាងក្រោម :

**១-ផ្នែករដ្ឋបាល**

- ជំនួយផ្នែករដ្ឋបាលប្រចាំថ្ងៃដោយផ្ទាល់ ទៅលោកប្រធាននាយកដ្ឋានពន្ធដារ និងលោកអនុប្រធាននាយកដ្ឋានពន្ធដារទាំងអស់
- រៀបចំគោលនយោបាយ នីតិវិធី និងសេចក្តីណែនាំដែលចាំបាច់ក្នុងផ្នែករដ្ឋបាល
- បង្កើតប្រព័ន្ធដើម្បីបែងចែក និងប្រគល់រាល់ឯកសារ លិខិតស្នាមទាំងអស់ដែលមានប្រភពពីក្នុង និងក្រៅនាយកដ្ឋានពន្ធដារ

- រៀបចំ គ្រប់គ្រងបណ្ណាល័យរបស់នាយកដ្ឋានពន្ធដារ
- គ្រប់គ្រង ថែរក្សា ការពារ ជួសជុល ទ្រព្យសម្បត្តិរបស់នាយកដ្ឋានពន្ធដារឱ្យបានល្អ ។

**២-ផ្នែកហិរញ្ញវត្ថុ**

- រៀបចំគោលនយោបាយ នីតិវិធី និងសេចក្ដីណែនាំនានាដែលចាំបាច់ក្នុងផ្នែកហិរញ្ញវត្ថុ
- ស្នើសុំ និងបើកផ្ដល់ថវិកា សំរាប់ផ្គត់ផ្គង់រាល់មធ្យោបាយ និងសម្ភារៈចាំបាច់សំរាប់បំពេញការងារ ដល់គ្រប់ការិយាល័យ និងសាខាពន្ធដារខេត្ត-ក្រុង
- បោះពុម្ព និងគ្រប់គ្រងរាល់ឯកសារ លិខិតស្នាមដែលទាក់ទងនឹងការងារជំនាញ និងការងាររដ្ឋបាលពន្ធដារ
- ត្រួតពិនិត្យការប្រើប្រាស់មូលនិធិ និងសម្ភារៈដែលទទួលបានពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងប្រភពផ្សេងៗ ដើម្បីធានាឱ្យការប្រើប្រាស់មូលនិធិ និងសម្ភារៈទាំងនោះបានត្រឹមត្រូវ និងចំទិសដៅ
- កត់ត្រា និងរក្សាទុកបញ្ជីគណនេយ្យ និងលិខិតយុត្តិការផ្សេងៗដែលទាក់ទងនឹងចំណូល-ចំណាយ ឱ្យបានត្រឹមត្រូវ គ្រប់គ្រាន់ និងទាន់ពេលវេលា ។

## ក.៣-ការិយាល័យគោលនយោបាយ និងនីតិកម្មសារពើពន្ធ

ការិយាល័យនេះមានតួនាទី និងភារកិច្ច ដូចខាងក្រោម :

- រៀបចំសេចក្ដីព្រាងបទប្បញ្ញត្តិទាក់ទងនឹងបញ្ហាសារពើពន្ធ
- រៀបចំ និងលើកសំណើកែប្រែបំពេញបន្ថែមចំណុចខ្វះខាតក្នុងច្បាប់ អនុក្រឹត្យ ប្រកាស សារាចរ ស្ដីពីពន្ធដារ
- រៀបចំឆ្លើយតបនឹងបញ្ហាទាំងឡាយទាក់ទងនឹងគោលនយោបាយ និងនីតិកម្មសារពើពន្ធ
- ចងក្រងច្បាប់ និងលិខិតបទដ្ឋានសារពើពន្ធ ជាភាសាជាតិ និងភាសាបរទេស
- រៀបចំ និងចូលរួមចរចាកិច្ចព្រមព្រៀង ដើម្បីជៀសវាងការយកពន្ធត្រួតគ្នាជាមួយបណ្ដាប្រទេសនានា
- រៀបចំគោលនយោបាយយុទ្ធសាស្ត្រសារពើពន្ធ និងធ្វើការព្យាករណ៍ចំណូលសារពើពន្ធ សំរាប់រយៈពេលខ្លី មធ្យម និងវែង
- រៀបចំកិច្ចសហប្រតិបត្តិការសារពើពន្ធជាមួយអង្គការអន្តរជាតិ និងបណ្ដាប្រទេសផ្សេងៗ ។

## ក.៤-ការិយាល័យសេវាអ្នកជាប់ពន្ធ

ការិយាល័យនេះមានតួនាទី និង ភារកិច្ច ដូចខាងក្រោម :

**១-ផ្នែកគោលនយោបាយ និងនីតិវិធី**

- រៀបចំគោលនយោបាយ និងកម្មវិធី ដើម្បីគាំទ្រដំណើរការសេវាជូនអ្នកជាប់ពន្ធ
- កសាងគោលនយោបាយ និងនីតិវិធីដែលពាក់ព័ន្ធទៅនឹងការប្រាស្រ័យទាក់ទងដោយប្រើប្រាស់ទំរង់បែបបទ និងភាសា នៅពេលផ្ដល់សេវាសារពើពន្ធជូនអ្នកជាប់ពន្ធ
- កសាងយុទ្ធសាស្ត្រសេវាអ្នកជាប់ពន្ធ ដើម្បីធានាឱ្យអ្នកជាប់ពន្ធយល់អំពីកាតព្វកិច្ចសារពើពន្ធ និងការគោរពប្រតិបត្តិ បទប្បញ្ញត្តិនៃច្បាប់ស្ដីពីសារពើពន្ធ

- ធ្វើការស្រាវជ្រាវដោយរួមបញ្ចូលការស្ទង់មតិលើបណ្តាបញ្ហាដែលពាក់ព័ន្ធទៅនឹងការផ្តល់សេវាអ្នកជាប់ពន្ធ ដើម្បីកំណត់នូវតម្រូវការព័ត៌មាន និងធ្វើការជ្រើសរើសសេវាកម្មល្អៗ ជូនអ្នកជាប់ពន្ធតាមផ្នែកនីមួយៗ
- រៀបចំ និងថែរក្សាសៀវភៅពន្យល់អំពីនីតិវិធីផ្ទៃក្នុងសំរាប់ការផ្តល់សេវាអ្នកជាប់ពន្ធ
- រៀបចំសិក្ខាសាលា អប់រំ ផ្សព្វផ្សាយ និងវគ្គបណ្តុះបណ្តាលជាសាធារណៈ ស្តីពីប្រភេទពន្ធនីមួយៗដោយរួមបញ្ចូលទាំងការដាក់លិខិតប្រកាស ការបង់ប្រាក់ពន្ធ ការបំពេញសំណុំបែបបទ
- រៀបចំ និងផ្សព្វផ្សាយសៀវភៅមគ្គុទេសក៍ព័ត៌មានផ្សេងៗ ដូចជា ប័ណ្ណពន្យល់ណែនាំ កូនសៀវភៅណែនាំ សំរាប់អ្នកជាប់ពន្ធប្រើប្រាស់
- ពិនិត្យឡើងវិញ និងធ្វើអោយមានលក្ខណៈបច្ចុប្បន្នភាពនូវបណ្តាឯកសារព័ត៌មានដែលបានបោះពុម្ពផ្សព្វផ្សាយ ដើម្បីធានាថាព័ត៌មានទាំងនោះថ្មីៗ និងទាក់ទងគ្នា
- បង្កើតឡើងនូវគំរូលិខិតឆ្លើយតបជាលាយល័ក្ខអក្សរ និងតាមទូរស័ព្ទ ទូរសារ ក្នុងការឆ្លើយតបទៅនឹងសំណួររបស់អ្នកជាប់ពន្ធ ដើម្បីធានានូវសង្គតភាព
- ចងក្រង និងបង្កើតតារាងទិន្នន័យអំពីបញ្ជីសំណួរដែលត្រូវបានលើកឡើងជារឿយៗ ដើម្បីជួយមន្ត្រីសេវាអ្នកជាប់ពន្ធក្នុងការរក្សានូវសង្គតភាព និងគុណភាពនៅទូទាំងប្រទេសពេលដែលឆ្លើយតបទៅនឹងសំណួររបស់អ្នកជាប់ពន្ធ
- រៀបចំកម្មវិធី និងបណ្តុះបណ្តាលជូនមន្ត្រីសេវាអ្នកជាប់ពន្ធ ។

**២-ផ្នែកប្រតិបត្តិ**

- រៀបចំផែនការសេវាអ្នកជាប់ពន្ធប្រចាំឆ្នាំ
- អនុវត្តគោលនយោបាយ និងកម្មវិធីដែលមានក្នុងផែនការសេវាអ្នកជាប់ពន្ធ
- ត្រួតពិនិត្យការអនុវត្តន៍គោលនយោបាយ និងលទ្ធផលសំរេចបានពីកម្មវិធីសេវាអ្នកជាប់ពន្ធ
- កំណត់ចេញការអនុវត្តន៍សេវាអ្នកជាប់ពន្ធថ្មីដែលដំណើរការបានល្អ ហើយធានាឱ្យការអនុវត្តន៍នេះត្រូវបានចែករំលែកដល់ផ្នែកសេវាអ្នកជាប់ពន្ធដ៏ទៃទៀត
- បង្កើតឡើងនូវភាពជាដៃគូជាមួយក្រុមអ្នកជាប់ពន្ធ និងស្ថាប័នពាក់ព័ន្ធនានា ។

**៣-ផ្នែកស្ថិតិ និងប្រព័ន្ធព័ត៌មាន**

- ប្រមូលផ្តុំព័ត៌មានដែលពាក់ព័ន្ធនឹងប្រតិបត្តិការនៅថ្នាក់ប្រតិបត្តិ ដើម្បីកំណត់នូវការអនុវត្តន៍កម្មវិធី
- រៀបចំរបាយការណ៍ព័ត៌មានស្ថិតិសម្រាប់ការងារគ្រប់គ្រង ដើម្បីជួយក្នុងការបែងចែកប្រភពធនធាន និងវាយតម្លៃប្រសិទ្ធភាពនៃកម្មវិធី
- អភិវឌ្ឍន៍នូវភាពជាក់លាក់តាមប្រព័ន្ធកុំព្យូទ័រ ដែលទាក់ទងនិងសកម្មភាពសេវាអ្នកជាប់ពន្ធ
- បង្ហាញអោយឃើញនូវនិន្នាការនៃតម្រូវការរបស់អ្នកជាប់ពន្ធ តាមរយៈការចងក្រងការស្ទង់មតិ និងទិន្នន័យស្ថិតិ ។

## ក.៥-ការិយាល័យគណនេយ្យ ស្ថិតិ និងផែនការ

ការិយាល័យនេះមានតួនាទី និងភារកិច្ច ដូចខាងក្រោម :

- រៀបចំគោលនយោបាយ យុទ្ធសាស្ត្រ និងបែបបទ សំរាប់ធ្វើគណនេយ្យកម្មចំណូលសារពើពន្ធ
- រៀបចំគោលនយោបាយ យុទ្ធសាស្ត្រ និងបែបបទ ឬសេចក្តីណែនាំនានាទាក់ទងនឹងការចាត់ចែងលិខិតប្រកាស

- តាមដានស្ថិតិអ្នកជាប់ពន្ធ ប្រមូលព័ត៌មានពីគណនេយ្យសារពើពន្ធ និងការចាត់ចែងលិខិតប្រកាសរបស់អ្នកជាប់ពន្ធក្នុងរបបស្វ័យប្រកាស និងរបបម៉ៅការ
- កសាងផែនការចំណូលប្រចាំឆ្នាំតាមពេលកំណត់
- តាមដានលទ្ធផលអនុវត្តបាន ប្រៀបធៀបនឹងផែនការចំណូលប្រចាំឆ្នាំ
- រៀបចំរបាយការណ៍ព័ត៌មានស្តីពីការគ្រប់គ្រង
- រៀបចំ និងគ្រប់គ្រងឯកសារបោះពុម្ព
- រៀបចំ និងកំណត់តម្រូវការជាក់លាក់នានា សំរាប់ប្រព័ន្ធកុំព្យូទ័រ
- អនុវត្តជាមួយថ្នាក់ប្រតិបត្តិ ស្តីពីប្រព័ន្ធគណនេយ្យ ស្ថិតិ និងផែនការ
- រៀបចំកម្មវិធី និងបណ្តុះបណ្តាលគណនេយ្យ ស្ថិតិ និងផែនការ ដល់មន្ត្រីពន្ធដារ ។

## ក.៦-ការិយាល័យគ្រប់គ្រងកម្មវិធីសវនកម្ម

ការិយាល័យនេះមានតួនាទី និងភារកិច្ច ដូចខាងក្រោម :

### ១-ផ្នែកគោលនយោបាយ និងនីតិវិធី

- ចូលរួមធ្វើការសិក្សាស្រាវជ្រាវ ស្តីពីបញ្ហាសារពើពន្ធ និងការអនុវត្តន៍របស់សហគ្រាស តាមប្រភេទអាជីវកម្មនីមួយៗ
- កសាងគោលនយោបាយ អភិវឌ្ឍន៍យុទ្ធសាស្ត្រ នីតិវិធីសវនកម្ម រៀបចំសារាចរ និងទំរង់បែបបទស្តីពីសវនកម្មលើអ្នកជាប់ពន្ធ តាមរបបស្វ័យប្រកាស និងរបបម៉ៅការ
- កសាងគោលនយោបាយ និងនីតិវិធីដែលទាក់ទងនឹងសវនកម្មអន្តរជាតិ ការគេចពន្ធ ការបន្លំពន្ធ ការផ្ទេរតំលៃ និងការកត់ត្រាបញ្ជីគណនេយ្យ ដោយប្រព័ន្ធអេឡិចត្រូនិច
- កសាងគោលនយោបាយ និងនីតិវិធីត្រួតពិនិត្យឡើងវិញ លើការធ្វើសវនកម្មដើម្បីធានាគុណភាព
- រៀបចំកម្មវិធី និងកំណត់ពីតំរូវការបណ្តុះបណ្តាល ស្តីពីបច្ចេកទេសសវនកម្មជាក់លាក់លើសហគ្រាស ដោយផ្អែកលើព័ត៌មានពីផ្នែកប្រតិបត្តិ និងផ្នែកស្ថិតិ ។

### ២-ផ្នែកប្រតិបត្តិ

- រៀបចំ កសាងផែនការសវនកម្មថ្នាក់ជាតិ ប្រចាំត្រីមាស ឆមាស ឆ្នាំ និងតាមដានការអនុវត្តន៍គោលនយោបាយ និងលទ្ធផលដែលសំរេចបានពីការដាក់កម្មវិធីសវនកម្ម
- ជ្រើសរើសសំណុំឯកសារធ្វើសវនកម្ម សំរាប់ថ្នាក់ប្រតិបត្តិ ដោយផ្អែកលើកំរិតហានិភ័យ ភាពមិនប្រក្រតី និងហេតុការណ៍ជាក់លាក់នៃការបន្លំ និងគេចវេសពន្ធ ...
- ជួយណែនាំថ្នាក់ប្រតិបត្តិលើសំណុំឯកសារដែលស្មុគស្មាញរបស់អ្នកជាប់ពន្ធ ។

### ៣-ផ្នែកស្ថិតិ និងប្រព័ន្ធព័ត៌មាន

- ចងក្រង និងគ្រប់គ្រងព័ត៌មានដែលទទួលបានពីថ្នាក់ប្រតិបត្តិ
- រៀបចំរបាយការណ៍ព័ត៌មានសំរាប់ការគ្រប់គ្រង និងបង្កើតបទដ្ឋានសំរាប់តាមដានការអនុវត្តន៍ ដើម្បីវាយតំលៃនូវប្រសិទ្ធភាពនៃប្រតិបត្តិការសវនកម្ម

- កសាងភាពជាក់លាក់តាមមុខងារចំពោះប្រព័ន្ធកុំព្យូទ័រដែលទាក់ទងដល់សកម្មភាពនានានៃការគ្រប់គ្រងកម្មវិធីសវនកម្ម ។

## ក.៧ -ការិយាល័យប្រមូលបំណុលសារពើពន្ធ

ការិយាល័យនេះមានតួនាទី និងភារកិច្ច ដូចខាងក្រោម :

### ១-ផ្នែកគោលនយោបាយ និងនីតិវិធី

- ធ្វើការសិក្សាស្រាវជ្រាវ ស្តីពីការគោរពប្រតិបត្តិរបស់អ្នកជាប់ពន្ធចំពោះការប្រមូលបំណុលពន្ធ និងបញ្ហាតឹងទារ
- ធ្វើការសិក្សាស្រាវជ្រាវ ស្តីពីការអនុវត្តន៍ការប្រមូលបំណុលពន្ធ
- កសាងគោលនយោបាយ និងនីតិវិធីប្រមូលបំណុលសារពើពន្ធ និងវិធានការតឹងទារចំពោះអ្នកជាប់ពន្ធដែលមិនគោរពច្បាប់
- បង្កើនប្រសិទ្ធភាពនៃយុទ្ធសាស្ត្រប្រមូលបំណុលពន្ធ
- រៀបចំនីតិវិធី សេចក្តីណែនាំ និងគំរូលិខិតស្តីពីការប្រមូលបំណុលពន្ធ
- រៀបចំកម្មវិធី និងបណ្តុះបណ្តាល ស្តីពីការប្រមូលបំណុលពន្ធ ។

### ២-ផ្នែកប្រតិបត្តិ

- កសាងផែនការប្រមូលបំណុលពន្ធប្រចាំឆ្នាំ
- កំណត់ និងជ្រើសរើសអ្នកជាប់បំណុលពន្ធជាអាទិភាព ដោយផ្អែកលើហានិភ័យ
- ដាក់ឱ្យអនុវត្តនូវគោលនយោបាយ និងកម្មវិធី ស្តីពីការប្រមូលបំណុលពន្ធ
- តាមដានលទ្ធផលនៃការអនុវត្តន៍នូវគោលនយោបាយ និងកម្មវិធី ស្តីពីការប្រមូលបំណុលពន្ធ
- ជួយការិយាល័យថ្នាក់ប្រតិបត្តិក្នុងការប្រមូលបំណុលពន្ធ ចំពោះអ្នកជាប់ពន្ធដែលមានភាពស្មុគស្មាញ ឬមានទ្រង់ទ្រាយធំ
- កំណត់ចេញការអនុវត្តន៍ក្នុងការប្រមូលបំណុលពន្ធថ្មីដែលដំណើរការបានល្អ ហើយធានាឱ្យការអនុវត្តន៍នេះត្រូវបានចែករំលែកដល់ផ្នែកប្រមូលបំណុលពន្ធដ៏ទៃទៀត ។

### ៣-ផ្នែកស្ថិតិ និងប្រព័ន្ធព័ត៌មាន

- ចងក្រងព័ត៌មានប្រតិបត្តិ ដែលទទួលបានពីថ្នាក់ប្រតិបត្តិ
- រៀបចំរបាយការណ៍ព័ត៌មានអំពីការគ្រប់គ្រងបំណុលពន្ធ ដោយផ្អែកលើផែនការ និងការអនុវត្តន៍បាន
- អភិវឌ្ឍន៍នូវភាពជាក់លាក់តាមប្រព័ន្ធកុំព្យូទ័រដែលទាក់ទងនឹងមុខងារ និងសកម្មភាពប្រមូលបំណុលពន្ធ
- កំណត់និន្នាការនៃការប្រមូលបំណុលពន្ធ ឥណទេយ្យ និងបំណុលរ៉ាំរ៉ៃ ។

## ក.៨ -ការិយាល័យវិវាទ

ការិយាល័យនេះមានតួនាទី និង ភារកិច្ច ដូចខាងក្រោម :

- រៀបចំ គោលនយោបាយ យុទ្ធសាស្ត្រ កម្មវិធី និងនីតិវិធីដោះស្រាយការតវ៉ា
- រៀបចំ សេចក្តីណែនាំ ទំរង់លិខិតស្នាម និងព័ត៌មានផ្សេងៗ ស្តីពីការតវ៉ាសំរាប់អ្នកជាប់ពន្ធ
- កសាងផែនការប្រចាំឆ្នាំ ស្តីពីការដោះស្រាយការតវ៉ា

- តាមដានការអនុវត្តនូវគោលនយោបាយ និងលទ្ធផលពីកម្មវិធីដោះស្រាយការតវ៉ា
- ជួយក្នុងការកំណត់ការខ្វះខាត និងចំណុចខ្សោយនៃច្បាប់ស្តីពីសារពើពន្ធ
- គ្រប់គ្រងការតវ៉ាដែលកើតមានឡើងរវាងអ្នកជាប់ពន្ធ និងនាយកដ្ឋានពន្ធដារ
- រៀបចំសេចក្តីសំរេចរបស់លោកប្រធាននាយកដ្ឋាន ឬសេចក្តីសំរេចទាំងឡាយសំរាប់ដាក់ជូនរដ្ឋមន្ត្រីទៅតាមសមត្ថកិច្ច
- ធានាទំនាក់ទំនងជាមួយនឹងតុលាការ
- ចងក្រងស្ថិតិ និងព័ត៌មានពីការដោះស្រាយការតវ៉ា ដើម្បីកំណត់លទ្ធផលពីការអនុវត្តនូវកម្មវិធី
- រៀបចំរបាយការណ៍ព័ត៌មានស្តីពីការគ្រប់គ្រង
- កំណត់និន្នាការនៃការតវ៉ារបស់អ្នកជាប់ពន្ធ និងលទ្ធផលនៃការស្ទង់មតិ
- ប្រមូលផ្តុំរាល់ស្ថិតិតវ៉ាពាក់ព័ន្ធដល់មូលដ្ឋានកំណត់ពន្ធ
- រៀបចំកម្មវិធី និងបណ្តុះបណ្តាលមន្ត្រីវិវាទ ។

### ក.៩-ការិយាល័យព័ត៌មានវិទ្យា

ការិយាល័យនេះមានតួនាទី និងភារកិច្ច ដូចខាងក្រោម :

- អភិវឌ្ឍន៍យុទ្ធសាស្រ្ត ព័ត៌មានវិទ្យារបស់នាយកដ្ឋានពន្ធដារ
- កសាងផែនការព័ត៌មានវិទ្យា
- កសាងគោលនយោបាយ និងនីតិវិធីព័ត៌មានវិទ្យារបស់នាយកដ្ឋាន
- រៀបចំសេចក្តីណែនាំ បទដ្ឋាន និងទំរង់លិខិតស្នាម ស្តីពីព័ត៌មានវិទ្យា
- រៀបចំ និងថែរក្សាប្រព័ន្ធត្រួតពិនិត្យ និងប្រព័ន្ធសុវត្ថិភាព ផ្នែកព័ត៌មានវិទ្យា
- ថែរក្សាប្រតិបត្តិការ នៃប្រព័ន្ធព័ត៌មានវិទ្យារួមបញ្ចូលគ្នា ទាំងក្នុងរបបស្វ័យប្រកាស និង របបម៉ៅការ
- តាមដានការអនុវត្តនូវកម្មវិធីស្តីពីព័ត៌មានវិទ្យា
- បង្កើតកម្មវិធីថ្មីសំរាប់ផ្លាស់ប្តូរ
- រៀបចំរបាយការណ៍ស្តីពីការគ្រប់គ្រងព័ត៌មានវិទ្យា
- ជួយអភិវឌ្ឍន៍នូវការកំណត់មុខងារឱ្យបានច្បាស់លាស់ សំរាប់ប្រើប្រាស់ក្នុងប្រព័ន្ធព័ត៌មានវិទ្យា ចំពោះគ្រប់កម្មវិធីដែលបានដាក់ចុះ
- រៀបចំកម្មវិធី និងបណ្តុះបណ្តាលព័ត៌មានវិទ្យា ។

## ខ-ថ្នាក់ប្រតិបត្តិ

### ខ.១-ការិយាល័យគ្រប់គ្រងអ្នកជាប់ពន្ធធំ និងមធ្យម

ការិយាល័យនេះ ទទួលខុសត្រូវក្នុងការគ្រប់គ្រងអ្នកជាប់ពន្ធធំ និងមធ្យម ដែលស្ថិតក្នុងប្រព័ន្ធប្រមូលពន្ធតាមរបបពិតដែលជាប្រព័ន្ធឆ្លើយប្រកាសដោយអ្នកជាប់ពន្ធខ្លួនឯង ។ ការិយាល័យនេះត្រូវបានបែងចែកជាអង្គភាព គ្រប់គ្រងអ្នកជាប់ពន្ធធំ និង អង្គភាពគ្រប់គ្រងអ្នកជាប់ពន្ធមធ្យម ។ អង្គភាពនីមួយៗ មាន ០៤ ផ្នែក : ផ្នែកសេវាអ្នកជាប់ពន្ធ ផ្នែកចាត់ចែងលិខិតប្រកាស ផ្នែកសវនកម្ម ផ្នែកប្រមូលបំណុលសារពើពន្ធ ដែលមានតួនាទី និងភារកិច្ច ដូចខាងក្រោម :

**ខ.១.១ ផ្នែកសេវាអ្នកជាប់ពន្ធ**

- រៀបចំរចនាសម្ព័ន្ធសំរាប់គាំទ្រផែនការ យុទ្ធសាស្ត្រ អាទិភាព និងគោលដៅនានា នៃសេវាអ្នកជាប់ពន្ធ
- កំណត់ចេញនូវលទ្ធផលសំរេចបានដោយផ្នែកលើកម្មវិធី និងថវិកាដែលបានផ្តល់ឱ្យ
- ចុះបញ្ជីអ្នកជាប់ពន្ធ និងចេញវិញ្ញាបនបត្រចុះបញ្ជីតាមប្រភេទពន្ធនានាដែលតម្រូវដោយច្បាប់ ចេញប័ណ្ណប៉ាតង់ កាន់កាប់ថែរក្សាបញ្ជីអ្នកជាប់ពន្ធ និងកត់ត្រារាល់ការផ្លាស់ប្តូរព័ត៌មានអ្នកជាប់ពន្ធក្នុងប្រព័ន្ធកុំព្យូទ័រ
- ផ្តល់សេវាជូនអ្នកជាប់ពន្ធ រួមមាន ការផ្តល់ប្រឹក្សា ការដោះស្រាយចម្ងល់ផ្សេងៗ ការផ្តល់ទំរង់លិខិតប្រកាសសារពើពន្ធ និងលិខិតបទដ្ឋាននានាទាក់ទងនឹងពន្ធដារ
- អនុវត្តកម្មវិធីអប់រំ បណ្តុះបណ្តាល ដើម្បីជួយអ្នកជាប់ពន្ធឱ្យយល់នូវកាតព្វកិច្ចសារពើពន្ធ
- ចូលរួម រៀបចំសិក្ខាសាលាផ្សព្វផ្សាយព័ត៌មានដែលពាក់ព័ន្ធនឹងបទប្បញ្ញត្តិស្តីពីសារពើពន្ធ
- រៀបចំជាក្រុមពិភាក្សាជាមួយអ្នកជាប់ពន្ធក្នុងវិស័យសំខាន់ ដើម្បីក្តាប់បាននូវសំណូមពរនិងសេចក្តីត្រូវការរបស់អ្នកជាប់ពន្ធ
- អនុវត្តនូវកម្មវិធីគ្រប់គ្រងគុណភាពសរុប ដើម្បីសំរេចបាននូវលទ្ធផល និងគុណភាពនៃការងារ រួមទាំងការវាស់ស្ទង់មតិរបស់អ្នកជាប់ពន្ធ ទាក់ទងនឹងគុណភាពសេវាកម្មដែលបានផ្តល់ឱ្យអ្នកជាប់ពន្ធ
- កំណត់កាលានុវត្តភាព ដើម្បីធ្វើឱ្យប្រសើរនូវការអនុវត្តន៍កម្មវិធី ឬ ពង្រីកសេវាកម្មជូនអ្នកជាប់ពន្ធ
- ពង្រឹងការបញ្ចូលទិន្នន័យក្នុងប្រព័ន្ធព័ត៌មានវិទ្យា ដើម្បីធានាការប្រើប្រាស់ព័ត៌មានរបស់អ្នកជាប់ពន្ធ ។

**ខ.១.២ ផ្នែកចាត់ចែងលិខិតប្រកាស**

ទទួលខុសត្រូវលើប្រតិបត្តិការចាត់ចែងលិខិតប្រកាស និងគណនេយ្យចំណូលសារពើពន្ធ រួមមាន :

- អនុវត្តគោលនយោបាយ និងកម្មវិធីចាត់ចែងលិខិតប្រកាស
- ទទួល និងពិនិត្យភាពត្រឹមត្រូវនៃលិខិតប្រកាសសារពើពន្ធ ដើម្បីធានាថាលិខិតប្រកាសត្រូវបានបំពេញគ្រប់ខ្ទង់គ្រប់និទ្ទេស និងការគណនាឱ្យបានត្រឹមត្រូវ
- រៀបចំ និងរក្សាទុកសំណុំឯកសារលិខិតប្រកាសរបស់អ្នកជាប់ពន្ធ និងពិនិត្យលើភាពមិនប្រក្រតីនៃលិខិតប្រកាសដើម្បីធ្វើសវនកម្មលើលិខិតស្នាម ឬលើកសំណើធ្វើសវនកម្ម
- ផ្ទៀងផ្ទាត់ការបង់ប្រាក់ពន្ធជាមួយនឹងប្រកាសឥណទាន ប្រកាសឥណពន្ធ និងរបាយការណ៍សមតុល្យគណនីដែលទទួលបានពីធនាគារជាតិ
- បញ្ចូលទិន្នន័យនៃការប្រមូលចំណូលទៅក្នុងប្រព័ន្ធកុំព្យូទ័រ ដើម្បីធ្វើគណនេយ្យកម្មចំណូលសារពើពន្ធ រួមមានការធ្វើសលាកបត្របង់ប្រាក់ចូលថវិកាជាតិ និងធ្វើរបាយការណ៍ជូនការិយាល័យ និងនាយកដ្ឋានពន្ធដារ
- ស្រង់ឈ្មោះ :
    ១. អ្នកស្នើសុំបង្វិលសងអាករលើតម្លៃបន្ថែម ដើម្បីបញ្ជូនទៅផ្នែកសវនកម្ម
    ២. អ្នកដាក់លិខិតប្រកាសយឺតយ៉ាវ ឬអ្នកដាក់លិខិតប្រកាសមិនបង់ប្រាក់ពន្ធ ដើម្បីកំណត់ពន្ធបន្ថែម ការប្រាក់ ឬ/និងធ្វើតារាងឥណទេយ្យបញ្ជូនទៅផ្នែកប្រមូលបំណុលសារពើពន្ធ

៣- អ្នកមិនដាក់លិខិតប្រកាស ដើម្បីធ្វើលិខិតជូនដំណឹងរំលឹកឱ្យអ្នកជាប់ពន្ធមកដាក់លិខិតប្រកាស និងបង់ប្រាក់ពន្ធ ។

**ខ.១.៣ ផ្នែកសវនកម្ម**

- រៀបចំរចនាសម្ព័ន្ធសំរាប់គាំទ្រផែនការ យុទ្ធសាស្ត្រ អាទិភាព និងគោលដៅនានា នៃសវនកម្មជាតិ
- កំណត់ចេញនូវលទ្ធផលសំរេចបានដោយផ្អែកលើកម្មវិធី និងថវិកាដែលបានផ្តល់ឱ្យ
- កំណត់ចេញនូវលទ្ធផលដែលនឹងត្រូវសំរេច ដោយផ្អែកលើកម្មវិធីសវនកម្ម និងការបែងចែកសវនករ ។ កម្មវិធីសវនកម្មនេះរួមមានៈ សវនកម្មតាមប្រភេទពន្ធ តាមប្រភេទសវនកម្ម តាមវិស័យ និងតាមទីតាំងរបស់អ្នកជាប់ពន្ធ
- ចូលរួមកសាង និងអនុវត្តកម្មវិធីសវនកម្ម ដើម្បីឱ្យអ្នកជាប់ពន្ធគោរពប្រតិបត្តិតាមច្បាប់ស្តីពីសារពើពន្ធ
- រៀបចំផែនការសវនកម្មលើសំណុំឯកសារនីមួយៗ និងពិនិត្យសំណុំឯកសារឡើងវិញ ដើម្បីរកឱ្យឃើញបញ្ហាដែលពាក់ព័ន្ធនឹងសំណុំឯកសារទាំងនោះ
- ធ្វើសវនកម្មអ្នកជាប់ពន្ធឱ្យបានត្រឹមត្រូវនិងទាន់ពេលវេលា ស្របតាមគោលនយោបាយរបស់នាយកដ្ឋានពន្ធដារ
- ធ្វើសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរដល់អ្នកជាប់ពន្ធស្តីពីលទ្ធផល ឬការផ្លាស់ប្តូរលទ្ធផលសវនកម្ម
- ធ្វើរបាយការណ៍បញ្ចប់ស្តីពីលទ្ធផលសវនកម្មលើអ្នកជាប់ពន្ធនីមួយៗ និងបញ្ជូនសំណុំឯកសារសវនកម្មទៅក្រុមពិនិត្យការងារសវនកម្មឡើងវិញ ។ ក្រុមនេះមានភារកិច្ច ពិនិត្យឡើងវិញរាល់ការងារសវនកម្ម ស្របតាមនីតិវិធីសវនកម្ម ដើម្បីធានានូវគុណភាព និងភាពត្រឹមត្រូវនៃការកំណត់ពន្ធឡើងវិញ និងស្របតាមគោលនយោបាយសវនកម្ម និងវាយតំលៃលទ្ធផលការងាររបស់សវនករ ព្រមទាំងរៀបចំតម្រូវការបណ្តុះបណ្តាលសវនករ
- ផ្តល់លទ្ធផលនៃការកំណត់ពន្ធឡើងវិញលើអ្នកជាប់ពន្ធទៅផ្នែកប្រមូលបំណុលពន្ធ និងផ្នែកចាត់ចែងលិខិតប្រកាស
- គ្រប់គ្រងព័ត៌មាន និងតាមដានការងាររបស់ក្រុមសវនករនីមួយៗ
- ផ្តល់ព័ត៌មានស្តីពីលទ្ធផលនៃកម្មវិធីសវនកម្មប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ដល់ថ្នាក់កណ្តាល
- កំណត់បញ្ហាដើម្បីកែលំអគោលនយោបាយ ផែនការ កម្មវិធីសវនកម្ម និងការជ្រើសរើសអ្នកជាប់ពន្ធ
- កំណត់តម្រូវការលើការបណ្តុះបណ្តាលទូទៅ និងលើការលំបាកក្នុងការធ្វើសវនកម្ម ។

**ខ.១.៤ ផ្នែកប្រមូលបំណុលពន្ធ**

- អនុវត្តគោលនយោបាយ និងកម្មវិធីក្នុងការប្រមូលបំណុលពន្ធ និងអនុវត្តវិធានការតឹងទារបំណុលពន្ធ
- រៀបចំបញ្ជីឈ្មោះអ្នកជំពាក់បំណុលពន្ធតាមប្រព័ន្ធកុំព្យូទ័រដោយមានការផ្ទៀងផ្ទាត់ជាមួយផ្នែកចាត់ចែងលិខិតប្រកាស និងផ្នែកសវនកម្ម
- បង្កើត និងរៀបចំសំណុំឯកសារអ្នកជាប់ពន្ធដែលជំពាក់បំណុលពន្ធ
- ធ្វើលិខិតជូនដំណឹងទារបំណុលពន្ធ និងលិខិតរំលឹកការទារបំណុលពន្ធទៅឱ្យអ្នកជាប់ពន្ធ
- រៀបចំផែនការសកម្មភាព និងវិធានការប្រមូលបំណុលពន្ធប្រចាំឆ្នាំរបស់ខ្លួន
- ជ្រើសរើសអ្នកជំពាក់បំណុលពន្ធ ដើម្បីអនុវត្តវិធានការតឹងទារដោយផ្អែកលើហានិភ័យ
- ធ្វើលិខិតចុងក្រោយដល់អ្នកជាប់ពន្ធដែលខកខានមិនបានទូទាត់បំណុលពន្ធ
- ទាក់ទងតាមទូរស័ព្ទដើម្បីទទួលព័ត៌មានពីអ្នកជំពាក់បំណុលពន្ធ

- ពិនិត្យឡើងវិញលើឯកសារនានានៅក្នុងសំណុំឯកសាររបស់អ្នកជំពាក់បំណុលពន្ធ ដើម្បីអនុវត្តការតឹងទារបំណុលពន្ធ
- ចុះជួប និងជូនដំណឹងដល់អ្នកជាប់ពន្ធអំពីវិធានការតឹងទារដែលត្រូវអនុវត្ត
- កត់ត្រាតាមដានការវិវត្តន៍នៃការអនុវត្តន៍វិធានការតឹងទារបំណុលពន្ធ និងរក្សាទុកក្នុងសំណុំឯកសារអ្នកជំពាក់បំណុលពន្ធ
- ស្វែងរក និងទទួលព័ត៌មានហិរញ្ញវត្ថុថ្មីៗ ពីការិយាល័យនានា ពីអ្នកជាប់ពន្ធ និងពីតតីយជន ដើម្បីវិភាគអំពីលទ្ធភាពរបស់អ្នកជាប់ពន្ធក្នុងការទូទាត់បំណុលពន្ធ
- រៀបចំលិខិតសំរាប់ផ្ញើជូនក្រសួង ស្ថាប័នរដ្ឋ និងឯកជន ដែលពាក់ព័ន្ធ ដើម្បីអនុវត្តវិធានការតឹងទារបំណុលពន្ធ
- រៀបចំសេចក្តីជូនដំណឹងជាលាយល័ក្ខអក្សរជូនទៅអ្នកជាប់ពន្ធបញ្ជាក់អំពីការតំរូវឱ្យអតិថិជនសំខាន់ៗរបស់អ្នកជាប់ពន្ធទូទាត់បំណុលរបស់អ្នកជាប់ពន្ធដោយផ្ទាល់ជូននាយកដ្ឋានពន្ធដារ
- ប្រមូលទិន្នន័យពីគ្រប់ប្រភព ដើម្បីវាស់ស្ទង់អោយបានល្អនូវប្រសិទ្ធភាព និងគុណភាពនៃការអនុវត្តន៍វិធានការតឹងទារបំណុលពន្ធ
- អនុវត្តការលើកលែងការឃុំគ្រង ឬបញ្ចេញទ្រព្យសម្បត្តិដែលបានរឹបអូស ស្របទៅតាមនីតិវិធី និងគោលនយោបាយរបស់នាយកដ្ឋានពន្ធដារ ។

## ៩.២-ការិយាល័យអង្កេត និងផ្តល់ព័ត៌មាន

ការិយាល័យអង្កេត និងផ្តល់ព័ត៌មាន មានតួនាទី និងការកិច្ច ដូចខាងក្រោម :

### ៩.២.១-ផ្នែកជំរឿនអ្នកជាប់ពន្ធ

- កំណត់នីតិវិធី និងធ្វើយុទ្ធនាការជំរឿន ព្រមទាំងធ្វើជំរឿនជាប្រចាំនូវសកម្មភាពអ្នកជាប់ពន្ធ ដោយបែងចែកតាមសកម្មភាពមុខរបរអាជីវកម្ម រួចបញ្ជូនទៅថ្នាក់ប្រតិបត្តិ ដើម្បីអនុវត្តកិច្ចចុះបញ្ជី និងកាតព្វកិច្ចតាមច្បាប់ និងបទប្បញ្ញត្តិស្តីពីសារពើពន្ធ
- ស្រាវជ្រាវរកការធ្វើសកម្មភាពអាជីវកម្មលួចលាក់របស់អ្នកជាប់ពន្ធ និងរាល់សកម្មភាពបន្លំ គេចវេសពន្ធ ។

### ៩.២.២-ផ្នែកអង្កេត និងផ្តល់ព័ត៌មាន

- រៀបចំផែនការការងារអង្កេត និងផ្តល់ព័ត៌មានប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ
- រៀបចំសារាចរ លិខិតបទដ្ឋាន និងនីតិវិធី ទាក់ទងទៅនឹងការអង្កេត និងផ្តល់ព័ត៌មាន
- ស្វែងរក និងផ្តល់ព័ត៌មានរបស់អ្នកជាប់ពន្ធពីក្រសួង ស្ថាប័នរដ្ឋ ស្ថាប័នឯកជន និងតតីយជនដែលពាក់ព័ន្ធ ដើម្បីរកចំណុចខ្វះខាតក្នុងសំណុំឯកសារអ្នកជាប់ពន្ធដែលបានធ្វើប្រកាសលាក់លៀម ឬធ្វើប្រកាសគួរឱ្យមន្ទិល
- ផ្តល់ព័ត៌មានពីការចុះបញ្ជីរបស់អ្នកជាប់ពន្ធនៅក្រសួង ស្ថាប័នពាក់ព័ន្ធ សំរាប់ផ្ទៀងផ្ទាត់ការចុះបញ្ជីនៅនាយកដ្ឋានពន្ធដារ
- បង្កើតតារាងទិន្នន័យផ្តល់ព័ត៌មានសំរាប់គាំទ្រកម្មវិធីសវនកម្ម និងការងារសវនកម្មក្នុងផ្នែកប្រតិបត្តិ
- អង្កេតដល់ទីកន្លែងអ្នកជាប់ពន្ធ ទាក់ទងកាតព្វកិច្ចសារពើពន្ធសំខាន់ៗ: ក-ការចុះបញ្ជី ខ-ការធ្វើប្រកាស គ-ការធ្វើវិក្កយបត្រ ឃ-ការកាន់បញ្ជីគណនេយ្យ ង-ការថែរក្សាសំណុំឯកសារ... ។ ក្នុងករណីរកឃើញការមិនអនុវត្តន៍កាតព្វកិច្ចសារពើពន្ធខាងលើ ត្រូវធ្វើរបាយការណ៍ទៅថ្នាក់ប្រតិបត្តិ ដើម្បីអនុវត្តពន្ធបន្ថែម

- អង្កេត និងត្រួតពិនិត្យផលរបរអ្នកជាប់ពន្ធរបបម៉ៅការ ផ្ទេរចូលរបបស្វ័យប្រកាស
- អង្កេតអ្នកជាប់ពន្ធដែលមិនដាក់លិខិតប្រកាស ដាក់លិខិតប្រកាសយឺតយ៉ាវ គ្មានសកម្មភាពអាជីវកម្ម
- ស្រាវជ្រាវអ្នកជាប់ពន្ធដែលបាត់ខ្លួន ដើម្បីធ្វើសំណើសុំលុបឈ្មោះចេញពីបញ្ជី
- អនុវត្តរួមគ្នាការអង្កេត និងការផ្តល់ព័ត៌មាន ដើម្បីប្រមូលព័ត៌មានអ្នកជាប់ពន្ធសំរាប់គាំទ្រកម្មវិធីសវនកម្ម
- រៀបចំការប្រើប្រាស់វិក្កយបត្រឱ្យមានប្រសិទ្ធភាព
- រៀបចំកម្មវិធី និងបណ្តុះបណ្តាលមន្ត្រីអង្កេត និងផ្តល់ព័ត៌មាន ។

### ខ.២.៣-ផ្នែកគាំទ្រការងារសវនកម្ម

- ចូលរួមធ្វើកម្មវិធីសវនកម្ម
- ចូលរួមជាមួយសវនករ តាមការសំរេចរបស់ប្រធាននាយកដ្ឋានពន្ធដារ ក្នុងការអនុវត្តន៍ការងារសវនកម្មក្នុងករណីចាំបាច់ ដោយផ្អែកលើទិន្នន័យព័ត៌មានដែលប្រមូលបាន ។

## ខ.៣-ការិយាល័យសវនកម្មសហគ្រាសធំ

ការិយាល័យនេះ មានតួនាទី និងភារកិច្ច ដូចខាងក្រោម :

- ធ្វើសវនកម្មទូទៅរួមមាន សវនកម្មពេញលេញ សវនកម្មលំអិត និងសវនកម្មមានកំរិត លើគ្រប់ប្រភេទពន្ធ និងគ្រប់អ្នកជាប់ពន្ធ ក្នុងទូទាំងប្រទេស
- រៀបចំរចនាសម្ព័ន្ធសំរាប់គាំទ្រ កម្មវិធី យុទ្ធសាស្ត្រ អាទិភាព និង គោលដៅនានា នៃសវនកម្មជាតិ
- ចូលរួមកសាង កំណត់គោលដៅអាទិភាព និងអនុវត្តកម្មវិធីសវនកម្ម
- កំណត់ចេញនូវលទ្ធផលដែលនឹងត្រូវសំរេច ដោយផ្អែកលើកម្មវិធីសវនកម្ម និងការបែងចែកសវនករ
- សំរបសំរួលជាមួយថ្នាក់ប្រតិបត្តិ ដែលទាក់ទងនឹងការគ្រប់គ្រងព័ត៌មានរបស់សហគ្រាសដែលត្រូវធ្វើសវនកម្ម
- គ្រប់គ្រងករណីសើបជាមួយនឹងថ្នាក់កណ្តាល
- កំណត់បញ្ហាដើម្បីកែលំអការអភិវឌ្ឍន៍នូវគោលនយោបាយសវនកម្ម កម្មវិធីសវនកម្ម និងប្រព័ន្ធសវនកម្ម
- គ្រប់គ្រងព័ត៌មាន និងតាមដានការងាររបស់ក្រុមសវនករនីមួយៗ
- ធ្វើសវនកម្មអ្នកជាប់ពន្ធឱ្យបានត្រឹមត្រូវ និងទាន់ពេលវេលា
- ផ្តល់ព័ត៌មានស្តីពីលទ្ធផលនៃកម្មវិធីសវនកម្មប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ដល់ថ្នាក់កណ្តាល
- រៀបចំផែនការសវនកម្មលើសំណុំឯកសារនីមួយៗ និងពិនិត្យសំណុំឯកសារឡើងវិញ ដើម្បីរកឱ្យឃើញបញ្ហាដែលពាក់ព័ន្ធនឹងសំណុំឯកសារទាំងនោះ
- ធ្វើសេចក្តីជូនដំណឹងជាលំអិតដល់អ្នកជាប់ពន្ធស្តីពីលទ្ធផល ឬការផ្លាស់ប្តូរលទ្ធផលសវនកម្ម
- ធ្វើរបាយការណ៍បញ្ចប់ស្តីពីលទ្ធផលសវនកម្មលើអ្នកជាប់ពន្ធនីមួយៗ និងបញ្ជូនសំណុំឯកសារសវនកម្មទៅផ្នែកពិនិត្យការងារសវនកម្មឡើងវិញ
- ផ្តល់លទ្ធផលនៃការកំណត់ពន្ធឡើងវិញលើអ្នកជាប់ពន្ធទៅថ្នាក់ប្រតិបត្តិដែលពាក់ព័ន្ធ
- រៀបចំកម្មវិធី និងបណ្តុះបណ្តាលសវនករ ។

របនាសម្ព័ន្ធរបស់ការិយាល័យសវនកម្មសារពើពន្ធសហគ្រាស ចែកចេញជា ០៤ ផ្នែក រួមមាន : ១-ផ្នែកសវនកម្មលើអ្នកជាប់ពន្ធធំ ២-ផ្នែកសវនកម្មលើអ្នកជាប់ពន្ធមធ្យម ៣-ផ្នែកសវនកម្មពិសេស និងអន្តរជាតិ ៤-ផ្នែកពិនិត្យការងារសវនកម្មឡើងវិញ ដែលមានភារកិច្ចពិនិត្យឡើងវិញរាល់ការងារសវនកម្មស្របតាមនីតិវិធីសវនកម្ម ដើម្បីធានានូវគុណភាព និងភាពត្រឹមត្រូវនៃការកំណត់ពន្ធឡើងវិញ ស្របតាមគោលនយោបាយសវនកម្ម និងវាយតំលៃលទ្ធផលការងាររបស់សវនករ ព្រមទាំងរៀបចំតម្រូវការបណ្តុះបណ្តាលសវនករ ។

### ខ.៤-សាខាពន្ធដារខេត្ត-ក្រុង

សាខាពន្ធដារខេត្ត-ក្រុង ចែកចេញជា ០៦ ផ្នែក មានតួនាទី និងភារកិច្ច ដូចខាងក្រោម :

#### ខ.៤.១-ផ្នែកបុគ្គលិក និង រដ្ឋបាល ហិរញ្ញវត្ថុ

- អនុវត្តគោលនយោបាយ និងនីតិវិធីតាមស្តង់ដារដើម្បីថែរក្សាសំណុំឯកសារ និងតាមដានការងាររបស់មន្ត្រី
- រៀបចំបៀវត្ស និងក្របខណ្ឌប្រាក់កំរៃ និងរបបឧបត្ថម្ភបន្ទុកគ្រួសារ គោលនយោបាយធានារ៉ាប់រងសង្គម របបសំរាកលំហែ និងធ្វើការស្នើតម្លើងកាំប្រាក់បៀវត្សប្រចាំឆ្នាំ របស់មន្ត្រីពន្ធដារ
- ធ្វើការស៊ើបអង្កេត សរសើរ ដាក់ពិន័យ និងគាំពារមន្ត្រីពន្ធដារ
- រៀបចំសំណើទៅថ្នាក់ដឹកនាំនាយកដ្ឋានដើម្បីដាក់ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពិនិត្យ និងសំរេចស្តីពីការតែងតាំង ផ្លាស់ប្តូរ លុបឈ្មោះចេញពីក្របខណ្ឌ សុំឈប់ពីការងារ និងដាក់ឱ្យចូលនិវត្តន៍
- គ្រប់គ្រង និងបែងចែករាល់ឯកសារ លិខិតស្នាមទាំងអស់ ដែលមានប្រភពពីក្នុង និងក្រៅសាខាពន្ធដារ
- ស្នើសុំ និងបើកផ្តល់ថវិកា សំរាប់ផ្គត់ផ្គង់រាល់មធ្យោបាយ និងសម្ភារៈចាំបាច់សំរាប់បំពេញការងារ
- គ្រប់គ្រងរាល់ឯកសារ លិខិតស្នាមដែលទទួលពីថ្នាក់កណ្តាល
- កត់ត្រា និងរក្សាទុកនូវបញ្ជីគណនេយ្យ និងលិខិតយុត្តិការផ្សេងៗ ដែលទាក់ទងនិងចំណូល-ចំណាយ ឱ្យបានត្រឹមត្រូវ គ្រប់គ្រាន់ និងទាន់ពេលវេលា ។

#### ខ.៤.២-ផ្នែកវិវាទ

- អនុវត្តគោលនយោបាយ និងកម្មវិធី ដើម្បីដោះស្រាយការតវ៉ា
- ចងក្រងស្ថិតិ និងព័ត៌មានពីការដោះស្រាយការតវ៉ា ដើម្បីកំណត់លទ្ធផលពីការអនុវត្តន៏កម្មវិធី
- រៀបចំរបាយការណ៏ព័ត៌មានស្តីពីការគ្រប់គ្រង
- កំណត់និន្នាការនៃការតវ៉ារបស់អ្នកជាប់ពន្ធ និងលទ្ធផលនៃការស្ទង់មតិ ។

#### ខ.៤.៣-ផ្នែកចុះបញ្ជី

- ទទួលបន្ទុក និងគ្រប់គ្រងប្រមូលពន្ធប្រថាប់ត្រា ពន្ធតែមប្រ៊ី ពន្ធលើឈ្នួលផ្ទះនិងដី ពន្ធលើដីធ្លីមិនបានប្រើប្រាស់ ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ និងអាករបំភ្លឺសាធារណៈ . . . ។

#### ខ.៤.៤-ផ្នែកប្រមូលពន្ធតាមរបបស្វ័យប្រកាស(គ្រប់គ្រងអ្នកជាប់ពន្ធមធ្យម)

ផ្នែកនេះទទួលបន្ទុកកំណត់ពន្ធ ប្រមូលពន្ធ និងត្រួតពិនិត្យ ចំពោះអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសដែលស្ថិតក្នុងភូមិសាស្ត្ររបស់ខេត្ត-ក្រុង ហើយចែកចេញជា ០៤ ក្រុម រួមមាន : ក្រុមសេវាអ្នកជាប់ពន្ធ ក្រុមចាត់ចែងលិខិតប្រកាស

ក្រុមសវនកម្ម និងក្រុមប្រមូលបំណុលសារពើពន្ធ ។ ក្រុមនីមួយៗ មានតួនាទី និងភារកិច្ច ដូចមានចែងក្នុងប្រការ ៧ ពីចំណុច ខ.១.១ ដល់ ខ.១.៤ នៃប្រកាសនេះ ។

**ខ.៤.៥-ប៉ុស្តិ៍គណនេយ្យដើមខ្សែ**

- ទទួលបន្ទុកធ្វើបេឡានិច្ច័យ និងធ្វើគណនេយ្យកម្មប្រាក់ពន្ធ
- ទទួលខុសត្រូវនូវការផ្ទេរប្រាក់ ដែលបានធ្វើបេឡានិច្ច័យបង់ចូលរតនាគារខេត្ត-ក្រុង
- ធ្វើការអនុវត្តន៍វិធានការតឹងទារប្រាក់ពន្ធអាករ ប្រាក់ពន្ធបន្ថែម និងការប្រាក់ ដែលបានកំណត់ដោយ ផ្នែកកំណត់ពន្ធណាមួយ ។

**ខ.៤.៦-ស្នាក់ការពន្ធដារស្រុក-ខណ្ឌ**

ស្នាក់ការពន្ធដារស្រុក-ខណ្ឌ មានភារកិច្ចធ្វើជំរឿនអ្នកជាប់ពន្ធ កំណត់ពន្ធ ប្រមូលពន្ធ និងចំណូលផ្សេងៗ តាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីសារពើពន្ធ និងចែកចេញជាពីរក្រុម :

- ក្រុមទី១ ទទួលបន្ទុកធ្វើជំរឿនអ្នកជាប់ពន្ធ និងកំណត់ពន្ធ
- ក្រុមទី២ ទទួលបន្ទុកដោយគណនេយ្យកររង មានភារកិច្ចធ្វើបេឡានិច្ច័យ និងធ្វើគណនេយ្យកម្មប្រាក់ពន្ធ គណនេយ្យកររង ទទួលខុសត្រូវនូវការផ្ទេរប្រាក់ដែលបានធ្វើឡើងនូវបេឡានិច្ច័យ បង់ចូលរតនាគារខេត្ត-ក្រុង ។

**ប្រការ៨.-**

អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានពន្ធដារ និងអង្គភាពពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០០៥

**គាត ឈន់**

**ចម្លងជូន:**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
  " ដើម្បីជូនជ្រាប "
- ដូចប្រការ ៨
- កាលប្បវត្តិ-ឯកសារ

# ព្រះរាជាណាចក្រកម្ពុជា

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការក្រសួងយុត្តិធម៌**

**លេខ:** ២៤......គស.ប្រក/០៥

ភ្នំពេញ, ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០០៥

# ប្រកាស

## ស្តីពីតួនាទី និងភារកិច្ចរបស់ខុទ្ទកាល័យ

## រដ្ឋមន្ត្រី ក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌
- បានឃើញក្រឹត្យលេខ ០៦.ក្រ ចុះថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- យោងតាមការចាំបាច់របស់ក្រសួងយុត្តិធម៌

## សំរេច

**ប្រការ ១ :** ខុទ្ទកាល័យក្រសួងយុត្តិធម៌ មានតួនាទី និងភារកិច្ច ដូចតទៅ :

- ទទួលបញ្ជា និងអនុវត្តតាមសេចក្តីណែនាំផ្ទាល់ពីឯកឧត្តមរដ្ឋមន្ត្រី
- ទទួលពិនិត្យ និងរៀបចំរាល់សំណុំលិខិត ឯកសារនានា ដាក់ជូនឯកឧត្តមរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងសំរេច
- លើកសំណើ និងយោបល់ ចំពោះកិច្ចការទូទៅរបស់ក្រសួង ជូនឯកឧត្តមរដ្ឋមន្ត្រី
- ទំនាក់ទំនង និងសំរបសំរួលការងារជាមួយអង្គភាពចំណុះ និងនាយកដ្ឋានទាំងឡាយក្រោមឱវាទក្រសួង ។
- ទំនាក់ទំនងជាមួយខុទ្ទកាល័យ និងអគ្គលេខាធិការដ្ឋាន នៃក្រសួង-ស្ថាប័នជាតិនានា ព្រមទាំងអង្គការជាតិ អន្តរជាតិ និងប្រព័ន្ធឃោសនាផ្សេងៗ ។
- រៀបចំកាលវិភាគជូនឯកឧត្តមរដ្ឋមន្ត្រី ឱ្យមានដំណើរការល្អប្រសើរ ។

- ចូលរួមក្នុងរាល់កិច្ចប្រជុំនានា សន្និបាត សន្និសីទ សិក្ខាសាលា និងពិធីផ្សេងៗ ដើម្បីប្រមូលពត៌មានជូនឯកឧត្តមរដ្ឋមន្ត្រី ។
- បញ្ជូន និងផ្សព្វផ្សាយ បទបញ្ជា ការណែនាំ របស់ឯកឧត្តមរដ្ឋមន្ត្រី ដល់អង្គភាពចំណុះ និងនាយកដ្ឋានទាំងឡាយក្រោមឱវាទក្រសួង ព្រមទាំងតាមដានការអនុវត្តន៍បទបញ្ជា និងការណែនាំទាំងនោះ ដើម្បីជំរុញការងារឱ្យមានប្រសិទ្ធភាព ។
- បំពេញការងារផ្សេងៗទៀត តាមការប្រគល់ភារកិច្ចពី ឯកឧត្តមរដ្ឋមន្ត្រី ។

**ប្រការ ២ :** នាយកខុទ្ទកាល័យដឹកនាំរួម និងមាននាយខុទ្ទកាល័យ ជំនួយការ និងលេខាធិការមួយចំនួនតាមការចាំបាច់ជាជំនួយ ។

**ប្រការ ៣ :** ខុទ្ទកាល័យរដ្ឋមន្ត្រី អគ្គាធិការដ្ឋានកិច្ចការតុលាការ, គ្រប់នាយកដ្ឋានចំណុះក្រសួងយុត្តិធម៌, តុលាការ និងអយ្យការអម តុលាការខេត្ត ក្រុង និងសាមីខ្លួន មានភារកិច្ចអនុវត្តនូវសេចក្តីប្រកាសនេះ ឱ្យមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខា នេះតទៅ ។

រដ្ឋមន្ត្រី

អង្គ.វង្សវឌ្ឍនា

ចម្លងជូន :
ទីស្តីការគណៈរដ្ឋមន្ត្រី
រាជកិច្ច
ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
ដូចប្រការ ៣
"ដើម្បីជូនជ្រាប និងអនុវត្ត"
ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ១៧៧១ ពណ.នគក

ភ្នំពេញថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០០៥

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

### សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **និកទ័រ**

NECTAR Co., Ltd.

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 2377/05E ចុះថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០០៥

មានទ្រង់ទ្រាយជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក MARTIN JAMES LEIGHFIELD

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ៨៤ Eo ផ្លូវលេខ១០ ភូមិក្រចេះ ស្រុកក្រចេះ ខេត្តក្រចេះ

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរណ៍ អាហរណ៍ទំនិញគ្រប់ប្រភេទ នាំចូល ឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ

-ការជួលដាក់ឃ្លាំងទុកផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ

-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ

-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ

-បើកសាលារៀន

-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម

-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម

-សេវាផ្សាយពាណិជ្ជកម្ម

-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្ត វីដេអូ

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស សេវាបញ្ជូននិងចែកចាយទំនិញ

-សាងសង់ ជួសជុល អាគារ ស្ពាន ផ្លូវ

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម

៦- ចិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
រដ្ឋលេខាធិការ
ង៉ិក-ប៊ុនណ

**ចំលងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលាខេត្តក្រចេះ
- មន្ទីរពាណិជ្ជកម្មខេត្តក្រចេះ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ១៧៤៦ ពណ.នគក

ភ្នំពេញថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ២០០៥

# ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ខេមបូឌាន ហ្គាឡាក់ស៊ី រីខ្លេម រីសសស៍**
**CAMBODIAN GALAXY RECLAIM RESOURCES Co.,Ltd.**
អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : **Co. 2376/05E** ចុះថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០០៥
មានទ្រង់ទ្រាយជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក **LIU JINGNONG**

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ៦០ E1 បន្ទប់លេខ ២០២ ផ្លូវលេខ ២២៥ សង្កាត់ផ្សារដេប៉ូទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូល ឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ
-បើកសាលារៀន
-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស សេវាបញ្ជូននិងចែកចាយទំនិញ
-សាងសង់ ជួសជុល អាគារ ស្ពាន ផ្លូវ

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម

៦- ចិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចំលងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

**ជួរលេខាធិការ**

**ចម_ប៉ុន**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ១០៤៧ ពណ.នគក

ភ្នំពេញថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០០៥

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

### សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ហេង គាង អ៊ីមផត អិចផត**

**HENG KEANG IMPORT EXPORT Co.,Ltd.**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 7708/05P ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០០៥

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក **ម៉ាន់ ហាក់ហេង** ប្រធានក្រុមប្រឹក្សាភិបាល

លោក **ង៉ូវ ឆេងងួន** អភិបាល

លោកស្រី **ង៉ូវ មួយគាង** អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ៣៧ ផ្លូវលេខ ៧៥ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញ នាំចូល ឱសថ និងសំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ

-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ

-ទិញ លក់ ជួល បញ្ចាំមូលនីធិពាណិជ្ជកម្ម-ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង

-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ

-មន្ទីរពេទ្យពិគ្រោះ និងព្យាបាលជំងឺ

-បើកសាលារៀន

-សេវាយកសំបុត្រជើងហោះ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម

-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ និងពាណិជ្ជកម្ម

-សេវាផ្សាយពាណិជ្ជកម្ម

-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្តវីដេអូ CD

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូនទំនិញ និងចែកចាយទំនិញ

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម

៦- ថិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។/.

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**រដ្ឋលេខាធិការ**

**ង៉ុក-ម៉ុង**

**ចំលងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ១០៧៩ ពណ.នតក

ភ្នំពេញថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ២០០៥

## នេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

### សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ហេង គីមសាន គ្រុប**
**HENG KIM SAN GROUP Co.,Ltd.**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 7707/05P ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០០៥

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក **ហេង គីមសាន** ប្រធានក្រុមប្រឹក្សាភិបាល
លោក **តាំង គីមសាំង** អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : លេខ ៥ ផ្លូវលេខ ២៨០ សង្កាត់បឹងកេងកងទី២ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម :
-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញ
-នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈទំនិញគ្រប់ប្រភេទ
-ទិញ លក់ ជួល បញ្ចាំមូលនិធិពាណិជ្ជកម្ម -ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង
-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ
-បើកសាលារៀន
-សេវាយកក់រៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាចម្រុះនិងចែកចាយទំនិញ
-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម

៦- ចិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**រដ្ឋលេខាធិការ**

**ចំ៉ក-ប៊ុន**

**ចំលងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច នឹង សេវាកុំព្យូទ័រ
- សាលា ក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មក្រុងភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ១៥៤១ ពណ.នគក

ភ្នំពេញថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០០៥

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **គូលឺរ (កាំបូដហ្ស៍ )**
**COULEURS ( CAMBODGE ) Co., Ltd.**
អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 2381/05E ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៥
មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក **ខៀវ ថានទិចារ** ប្រធានក្រុមប្រឹក្សាភិបាល
លោក SERGE RÉMI PACILLY "តតិយជន" អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ១៩ ផ្លូវលេខ ៥៤៤ សង្កាត់បឹងកក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូល ឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការដួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ
-បើកសាលារៀន
-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន [illegible]

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម

៦- ថិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។៚

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គលេខាធិការ

ចំ ឈុន — ម៉ុច

ចម្លងជូន

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ១០៤១ ពណ.នតក

ភ្នំពេញថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ២០០៥

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **អង្គរ ឌ្រីមីង**

**ANGKOR DREAMING Co.,Ltd.**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 7709/05P ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០០៥

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោកស្រី **ឡាយ សុគន្ធា** ប្រធានក្រុមប្រឹក្សាភិបាល

លោក **លី ខាសនា** អភិបាល

លោក **លឹម សម្តស** អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ១៣G ផ្លូវលេខ ១៦៧ សង្កាត់ទួលទំពូងទី២ ខណ្ឌចំការមន រាជធានីភ្នំពេញ

៥- កម្មវត្ថុអាជីវកម្ម : -ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន អភិវឌ្ឍន៍មណ្ឌលកំសាន្ត ទីភ្នាក់ងារទេសចរណ៍

-ផលិតទឹកស្អាត នាំចូលសំភារៈឧបករណ៍ផលិតទឹកស្អាតនិងទឹកបរិភោគ

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់ មជ្ឈមណ្ឌលពាណិជ្ជកម្ម

-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ

-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ

-ទិញ លក់ ជួល បញ្ចាំមូលនីធិពាណិជ្ជកម្ម-ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង

-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ

-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ

-បើកសាលារៀន

-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម-តំណាងពាណិជ្ជកម្ម

-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុពាណិជ្ជកម្ម

-សេវាផ្សាយពាណិជ្ជកម្ម

-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្តវីដេអូ CD VCD DVD

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូននិងចែកចាយទំនិញ

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ចិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**រដ្ឋលេខាធិការ**

**ង៉ុក ម៉ុង**

**ចំលងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
